**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Universite Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# តុងទីន

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយនិស្សិត

និស្សិតឈ្មោះ **វណ្ណា ឌីណា**

**ឃុត កែវរតនៈ**

សាស្ត្រាចារ្យណែនាំ

**លោក ញឹក ឧត្តី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **វណ្ណា ឌីណា** និង **ឃុត កែវរតនៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៧-២០២១។

**សូមលំឱនកាយវាចាចិត្ត ដើម្បីសម្តែងនូវការគោរពដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ**

| | |
|---|---|
| លោកឪពុក **វណ្ណា វ៉េត** | លោកឪពុក **ឃុត កែវសុត្ថា** |
| អ្នកម្តាយ **ខ៉េត សុខលី** | អ្នកម្តាយ **ឌុច សោភ័ណ្ឌ** |

សូមអរគុណដល់ លោកអ្នកមានគុណ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀបប្រដៅណែនាំ ផ្តល់ដំបូន្មាន ព្រមទាំងផ្គត់ផ្គង់ជាថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សា ផ្តល់ឱ្យគ្រប់យ៉ាងនូវកម្លាំងកាយ កម្លាំងចិត្ត ទាំងផ្នែកបញ្ញា និងស្មារតី លើកទឹកចិត្ត ក្នុងការខិតខំសិក្សារៀនសូត្រ ក្រេបយកនូវចំណេះដឹងតាំងពីតូចក្រូចឆ្មាររហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ គុណូបការៈ និងព្រហ្មវិហារធម៌របស់លោកអ្នកមានគុណចំពោះយើងខ្ញុំពិតជាមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ទាំងនេះហើយដែលធ្វើឱ្យកូនមិនអាចបំភ្លេចបាន ហើយគុណធម៌ និងព្រហ្មវិហារធម៌ទាំងនោះនឹងស្ថិតនៅក្នុងចិត្តកូនជានិច្ចដរាប។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ **លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងអំឡុងពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានទទួលនូវការអប់រំណែនាំ បង្ហាត់បង្រៀន និងការផ្តល់នូវចំណេះដឹងជាច្រើន ជាពិសេសលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិនខ្លាចការនឿយហត់ ពោលមានតែដាស់តឿនស្មារតី និស្សិតឱ្យខិតខំសិក្សា ដើម្បីពង្រឹងសមត្ថភាពឱ្យពេញលេញតាមតម្រូវការរបស់សង្គមជាតិ និងស្រាវជ្រាវថ្មីៗ ដើម្បីជួយដល់ការសិក្សាឱ្យកាន់តែមានភាពរីកចម្រើន។ ទាំងនេះគឺជាគុណ ដែលលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បានផ្តល់នូវពុទ្ធិ បទពិសោធន៍សិក្សា ការងារ និងការរស់នៅផងដែរ។

ជាពិសេសជាងនេះទៅទៀត ខ្ញុំបាទទាំងពីរនាក់សូមថ្លែងនូវគារវកិច្ច និងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូ សាស្ត្រាចារ្យ **ញឹក វុឌ្ឍី** ដែលជាសាស្ត្រាចារ្យណែនាំខ្ញុំបាទទាំងពីរនាក់ ដែលលោកតែងតែផ្តល់នូវមតិអប់រំ ណែនាំ ចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត ចែករំលែកចំណេះដឹងទាំងឡាយ ជាមួយការដឹកនាំ កែលម្អ ចង្អុលបង្ហាញ និងតម្រង់ទិស ព្រមទាំងពន្យល់វិធីសាស្ត្រល្អៗ លើប្រធានបទខ្ញុំបាទយ៉ាងយកចិត្តទុកដាក់ ដើម្បីឈានទៅដល់ការទទួលបានភាពជោគជ័យ។

សូមថ្លែងអំណរគុណជូនចំពោះ **លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី លោកពូ អ្នកមីង បងប្អូន សិស្សច្បង និងមិត្តភក្តិទាំងអស់** ដែលបានផ្តល់ជាគំនិត និងតែងតែលើកទឹកចិត្តដល់យើងខ្ញុំក្នុងការសរសេរសារណាមួយនេះ និងឈានចាប់ក្តីស្រមៃនាពេលអនាគត។

ជាទីចុងបញ្ចប់ យើងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុសក្តិសិទ្ធិទាំងឡាយទាំងពួង ដែលមានបារមីនៅលើលោកយើងនេះ សូមមេត្តាតាមបីបាច់ថែរក្សា **អ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូ អ្នកមីង បងប្អូន និងមិត្តភក្តិទាំងអស់** ជាពិសេសលោកគ្រូសាស្ត្រាចារ្យ **ញឹក វុទ្ធី** សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាជំនាញនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំមក ខ្ញុំបាទទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយមែនទែន ដែលសាកលវិទ្យាល័យបានផ្តល់ឱកាសដល់រូបខ្ញុំបាទទាំងពីរបញ្ចេញសមត្ថភាពក្នុងការស្រាវជ្រាវចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះឡើង។ បន្ទាប់ពីបានក្រេបជញ្ជក់យកចំណេះវិជ្ជាពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យក្នុងរយៈពេលនេះ និងសង្កេតមើលស្ថានភាពជាប្រត្យក្សក្នុងសង្គមខ្មែរ ខ្ញុំបាទទាំងពីរយល់ឃើញថាការលេងតុងទីនមិនទាន់មានច្បាប់ ដែលបានបញ្ញត្តគ្រប់គ្រងទៅលើការលេងនេះច្បាស់លាស់ដូចច្បាប់ស្តីពីតុងទីន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ៨៦៥នស ចុះថ្ងៃទី២៧ ឧសភា ១៩៥៤ ពោលអ្នកច្បាប់យកបញ្ញត្តិនៃក្រម និងច្បាប់ពិសេសមួយចំនួនទៀត ដើម្បីយកទៅអនុវត្តនៅពេលដែលមានការមិនអនុវត្តកាតព្វកិច្ច ឬរត់ចោលស្រុកជាដើម។

ដើម្បីចូលរួមចំណែកក្នុងការជួយសង្គម ខ្ញុំបាទទាំងពីរនាក់ក៏បានស្រាវជ្រាវសារណាមួយ ដែលមានប្រធានបទស្តីពី **តុងទីន** មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវ។ ក្នុងន័យនេះ យើងខ្ញុំមានគោលបំណងក្នុងការបំផុសឡើងនូវបទដ្ឋានគតិយុត្តដែលទាក់ទងទៅនឹងតុងទីន ដើម្បីឱ្យមជ្ឈដ្ឋានសាធារណៈកាន់តែជ្រាបច្បាស់អំពីបញ្ហានេះផងដែរ។ ដូចដែលយើងបានដឹងរួចមកហើយថា ប្រទេសកម្ពុជាយើងបច្ចុប្បន្នពុំទាន់មានលិខិតបទដ្ឋានគតិយុត្តដែលចែងអំពីច្បាប់តុងទីននៅឡើយទេ លើកលែងតែក្នុងសម័យសង្គមរាស្ត្រនិយម ដែលជាព្រះរាជក្រមលេខ ៨៦៥នស ចុះថ្ងៃទី២៧ ឧសភា ១៩៥៤ ស្តីពីតុងទីន។ ចំណែកឯសម័យបច្ចុប្បន្ននេះវិញ មានតែយកបញ្ញត្តិផ្សេងៗនៅក្រម និងច្បាប់ដោយឡែកមកបកស្រាយអំពីកិច្ចគតិយុត្តនៅក្នុងតុងទីន។ កាលណាប្រជាជន លោកបានយល់អំពីបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងតុងទីន លោកនឹងមានភាពងាយស្រួល ក៏ដូចជាលេងតុងទីនដោយមានភាពស្រណុកក្នុងចិត្ត ដោយហេតុថា ច្បាប់បានការពារសិទ្ធិ និងកាតព្វកិច្ចរបស់គាត់នៅក្នុងការលេងតុងទីននោះផងដែរ។ ខ្ញុំបាទទាំងពីរនាក់ជឿជាក់ថា សារណាមួយនេះនឹងក្លាយជាឯកសារមួយដ៏សំខាន់មួយ សម្រាប់អ្នកចង់សិក្សាស្វែងយល់អំពីតុងទីន និងការទទួលខុសត្រូវរបស់ភាគី ដែលមាននៅក្នុងនោះ។

ជាទីបញ្ចប់ ខ្ញុំបាទទាំងពីរនាក់ សូមធ្វើការអភ័យទោសជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ពាក្យពេចន៍ ការបកស្រាយ ឬកង្វះនូវបទដ្ឋានគតិយុត្ត ដើម្បីឱ្យសារណានេះមានភាពប្រសើរឡើង។ យើងខ្ញុំសូមទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តអ្នកអានសារណានេះទាំងអស់គ្នា ដើម្បីធ្វើការកែលម្អឱ្យកាន់តែមានភាពប្រសើរឡើង និងគ្រប់ជ្រុងជ្រោយ។ ជាពិសេស ខ្ញុំបាទទាំងពីរសង្ឃឹមថានឹងទទួលបានការយោគយល់ និងអធ្យាស្រ័យពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដោយក្តីអនុគ្រោះ។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖**

**ទិដ្ឋភាពទូទៅរបស់តុងទីន**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃតុងទីន** ........ ៣

**កថាភាគទី១៖ ដំណើរការនៃការលេង** ........ ៤

**១. ការចាប់ផ្តើមលេងតុងទីន** ........ ៤

**២. ការដេញថ្លៃតុងទីន** ........ ៥

**៣. ការបញ្ចប់តុងទីន** ........ ៦

៣.១. ការបញ្ចប់តុងទីនដោយការមកដល់នៃរយៈពេលតុងទីន ........ ៦

៣.២. ការបញ្ចប់តុងទីនដោយរំលាយតុងទីនមុនពេលកំណត់ ........ ៧

**កថាភាគទី២៖ សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី** ........ ៨

**១. សិទ្ធិ និងកាតព្វកិច្ចរបស់មេតុងទីន** ........ ៩

១.១. សិទ្ធិរបស់មេតុងទីន ........ ៩

១.២. កាតព្វកិច្ចរបស់មេតុងទីន ........ ៩

**២. សិទ្ធិ និងកាតព្វកិច្ចរបស់កូនតុងទីន** ........ ១០

២.១. សិទ្ធិរបស់កូនតុងទីន ........ ១០

២.២. កាតព្វកិច្ចរបស់កូនតុងទីន ........ ១១

**កថាភាគទី១៖ កិច្ចសន្យាខ្ចីបរិភោគ** ........ ១៣

**កថាភាគទី២៖ កិច្ចសន្យាអាណាព្យាបាល** ........ ១៤

**កថាភាគទី៣៖ កិច្ចសន្យាលក់ទិញ** ........ ១៦

# ជំពូកទី២៖

# ការទទួលខុសត្រូវក្នុងគុងទីន

**ផ្នែកទី១៖ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី** ........................................................................១៨

**កថាភាគទី១៖ លក្ខខណ្ឌនៃការទទួលខុសត្រូវ** ........................................................................១៩

**១. ការមិនអនុវត្តកាតព្វកិច្ច ដែលចាត់ទុកជាកំហុស**........................................................ ១៩

១.១. ការអនុវត្តកាតព្វកិច្ចមិនទាន់ពេលកំណត់ ........................................................................២០

១.២. អលទ្ធភាពក្នុងការអនុវត្ត ........................................................................................................២១

១.៣. អនុវត្តកាតព្វកិច្ចមិនបានពេញលេញ ........................................................................................២១

១.៤. ករណីផ្សេងទៀត ដែលមិនអនុវត្តទៅតាមលក្ខន្តិកៈគុងទីន ........................................ ២២

**២.ព្យសនកម្ម** ........................................................................................................................ ២២

**៣. ទំនាក់ទំនងរវាងអំពើ (ការមិនអនុវត្តកាតព្វកិច្ច) និងព្យសនកម្ម** ......... ២៣

**កថាភាគទី២៖ ដំណោះស្រាយចំពោះការមិនអនុវត្តកាតព្វកិច្ច** .......................... ២៤

**១. ការអនុវត្តកាតព្វកិច្ចដោយបង្ខំ** ........................................................................................ ២៤

**២. សំណងនៃការខូចខាត**.......................................................................................................... ២៥

២.១. ការទាមទារសំណងការខូចខាតនាពេលបច្ចុប្បន្ន ....................................................................២៦

២.២. ការទាមទារសំណងការខូចខាតនាពេលអនាគត ................................................ ២៧

**៣. ការផ្ទេរវេនសមាជិកភាពនៃគុងទីន** ........................................................................ ២៧

**៤. ការរំលាយគុងទីនមុនកំណត់**................................................................................................ ២៨

**ផ្នែកទី២៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ** ........................................................................ ២៩

**កថាភាគទី១៖ បទរំលោភលើទំនុកចិត្ត**................................................................ ៣០

**១. ធាតុនីត្យានុកូល** ................................................................................................................ ៣០

**២. ធាតុសត្យានុម័ត** ................................................................................................................ ៣១

៣. ធាតុអត្តនោម័ត ........................................ ៣២

កថាភាគទី២៖ បទឆបោក ........................................ ៣៣

១. ធាតុនីត្យានុកូល ........................................ ៣៤

២. ធាតុសត្យានុម័ត ........................................ ៣៤

៣. ធាតុអត្តនោម័ត ........................................ ៣៥

## ជំពូកទី៣៖

## ករណីសិក្សាក្នុងរឿងតុំទាវ

ផ្នែកទី១៖ ករណីសិក្សាក្នុងរឿងក្តីរដ្ឋប្បវេណី ........................................ ៣៧

ផ្នែកទី២៖ ករណីសិក្សាក្នុងរឿងព្រហ្មទណ្ឌ ........................................ ៣៩

កថាភាគទី១៖ បទរំលោភលើទំនុកចិត្ត ........................................ ៣៩

កថាភាគទី២៖ បទឆបោក ........................................ ៤០

សេចក្តីសន្និដ្ឋាន ........................................ ៤៣

អនុសាសន៍ ........................................ ៤៤

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

បច្ចុប្បន្ននេះប្រជាជនកម្ពុជានិយមប្រើប្រាស់កម្ចីសាច់ប្រាក់ពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កម្ចីអ្នកស្គាល់គ្នា ឬក៏អាចចងការអ្នកដទៃទៅតាមស្ថានភាពជាក់ស្តែង នៅពេលមានតម្រូវការហិរញ្ញវត្ថុ។ មធ្យោបាយកម្ចីសាច់ប្រាក់ទាំងនេះមានលក្ខខណ្ឌផ្សេងៗគ្នា ដោយខ្លះមានភាពងាយស្រួលក្នុងការទទួលបានកម្ចី តែបែរជាមានអត្រាការប្រាក់ខ្ពស់ ហើយខ្លះទៀតមានអត្រាការប្រាក់ទាប តែបែរជាមានភាពលំបាកក្នុងការទទួលបានប្រាក់កម្ចីទៅវិញ។ ដោយឃើញការលំបាកនេះបែបនេះហើយ ទើបមនុស្សមួយចំនួនបានងាកមកលេងតុងទីន ដែលជាមធ្យោបាយមួយក្នុងការប្រមូលប្រាក់នៅពេលដែលមានតម្រូវការប្រាក់បន្ទាន់។ ការលេងតុងទីន ជាការសន្សំប្រាក់ និងអាចចាត់ទុកថាជាការរកស៊ី ឬការចងការប្រាក់ ដែលចំណេញ ហើយមិនចាំបាច់ដាក់ទ្រព្យបញ្ចាំអ្វីឡើយ ផ្ទុយទៅវិញការលេងតុងទីននេះត្រូវការទំនុកចិត្តរវាងគ្នា និងគ្នាយ៉ាងខ្លាំង។

នៅប្រទេសបារាំង ពាក្យថាតុងទីនបានមកការកម្លាយឈ្មោះរបស់លោក ឡូរ៉ង់ស្សូ ទុងទី (**Lorenzo Tonti**) ជនជាតិអ៊ីតាលី សញ្ជាតិបារាំង។[1] បើយោងតាមវចនានុក្រម Oxford Dictionary of English ពាក្យតុងទីន (Tontine) នេះមានប្រភពតាំងពីពាក់កណ្តាលសតវត្សទី១៨ ដោយ ឈ្មោះ **Lorenzo Tonti** ជាធនាគារិកម្នាក់ដែលបានចាប់ផ្តើមបង្កើតគម្រោងប្រមូលប្រាក់កម្ចីជូនរដ្ឋាភិបាលបារាំង។ ចំណែកឯក្នុងវចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត វិញ បានឱ្យនិយមន័យថា តុងទីន គឺជាសមាគមប្រមូលប្រាក់ ក្រុមហ៊ុនសន្សំដើមទុន ដើម្បីជួយគ្នាទៅវិញទៅមក។[2] ក្នុងនោះដែរ ច្បាប់តុងទីនសម័យសង្គមរាស្ត្រនិយមបានបញ្ញត្តថា តុងទីនជាកិច្ចសន្យាមួយ ដែលចងមេតុងទីន និងសមាជិកតុងទីនពី២រូបឡើងទៅ មេតុងទីន និងកូនតុងទីនម្នាក់ៗត្រូវមានហ៊ុន ឬចំណែកយ៉ាងតិចមួយហ៊ុនម្នាក់។[3] ប្រាក់សម្រាប់បោះទុន ឬប្រាក់ដើម ដែលកូនតុងទីនម្នាក់ៗបានដាក់ទៅក្នុងមូលនិធិតុងទីន នឹងអាចជាផលចំណេញខ្ពស់សម្រាប់កូនតុងទីនណា ដែលលេងមិនចង់ដេញ ហើយទុករហូតដល់នៅសល់ចុងក្រោយគេ ព្រោះអ្នកដែលនៅចុងក្រោយគេនឹងប្រមូលបានទុនទាំងមូល ដោយមិនចាំបាច់ដេញថ្លៃតុងទីនឡើយ។ ពាក្យថាតុងទីនត្រូវបានមនុស្សទូទៅហៅថា ការសន្សំប្រាក់ជាក្រុម ដោយបានអត្រាការប្រាក់ខ្ពស់ជាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយពុំតម្រូវឱ្យមានកិច្ចសន្យា លិខិតស្នាមជាលាយលក្ខណ៍អក្សរ និងវត្ថុបញ្ចាំត្រឹមត្រូវឡើយ។[4] បើទោះបីជាតុងទីនមានរឿងអាស្រូវជាច្រើនពាក់ព័ន្ធនឹងការបោកប្រាស់របស់មេតុងទីន ឬកូនតុងទីនយ៉ាងណាក្តី ក៏ប៉ុន្តែវានៅតែជាមធ្យោបាយប្រមូលសាច់ប្រាក់មួយដ៏ល្អ និងពេញនិយម ដែលអ្នកគួរពិចារណាជាជាងជម្រើសកម្ចីប្រាក់ពីស្ថាប័ន

---

[1] លី រ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី១។

[2] សម្តេចព្រះសង្ឃរាជ ជួនណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៨។

[3] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា៣។

[4] https://khmerpostasia.com/archives/3246 (ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១)។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ព្រោះវាមិនទាមទារឱ្យអ្នកមានទ្រព្យតម្កល់ ឬឯកសារបញ្ជាក់ប្រាក់ចំណូលព្រមទាំងឯកសារស្មុគស្មាញនោះទេ ព្រោះអ្នកចូលរួមលេងភាគច្រើនជាមួយមនុស្ស ដែលស្គាល់ និងទុកចិត្តគ្នាទៅវិញទៅមក។

ប្រជាជនមួយចំនួនបានហៅ ការលេងតុងទីនថាជាល្បែងខុសច្បាប់ ដោយសារពួកគាត់យល់ឃើញថាមិនមានច្បាប់ណាមួយចែងអំពីការលេងតុងទីននេះទេ។ ការលើកយកប្រធានបទនេះឡើងក្នុងគោលបំណងជាបច្ច័យដល់អ្នកសិក្សាស្រាវជ្រាវ និងប្រជាជនឱ្យមានការយល់ដឹងពីមូលដ្ឋានគតិយុត្តកម្ពុជាមួយចំនួនក្នុងការការពារខ្លួន មុននឹងសម្រេចចិត្តបង្កើតក្រុមតុងទីនឡើង។ ក្នុងន័យនេះ យើងខ្ញុំមានគោលបំណងក្នុងការបំផុសឡើងនូវបទដ្ឋានគតិយុត្តដែលទាក់ទងទៅនឹងការលេងតុងទីន និងការទទួលខុសត្រូវរបស់ភាគី ដើម្បីឱ្យមជ្ឈដ្ឋានសាធារណៈកាន់តែជ្រាបអំពីបញ្ហានេះ។ កាលណាប្រជាជនលោកបានយល់អំពីបទដ្ឋានគតិយុត្តដែលទាក់ទងនឹងតុងទីន លោកនឹងមានភាពងាយស្រួល ក៏ដូចជាលេងតុងទីនដោយមានភាពស្រណុកក្នុងចិត្ត ដោយហេតុថាច្បាប់បានការពារសិទ្ធិ និងកាតព្វកិច្ចរបស់គាត់នៅក្នុងការលេងតុងទីននោះផងដែរ។

ការលេងតុងទីនពិតជាមានប្រជាប្រិយភាពណាស់នៅពេលបច្ចុប្បន្ននេះ ប៉ុន្តែបុគ្គលមួយចំនួនតូចហាក់មិនទាន់យល់ច្បាស់ពីតុងទីននោះទេ ដូច្នេះថាតើតុងទីនមានទិដ្ឋភាពទូទៅដូចម្ដេចខ្លះ? ហើយភាគីត្រូវទទួលខុសត្រូវយ៉ាងណាដែរ ចំពោះការលេងតុងទីននេះ?

ក្នុងសារណានេះ យើងនឹងលើកឡើងអំពីលើទិដ្ឋភាពទូទៅអំពីការលេងតុងទីន នៅជំពូកទី១ ដែលនឹងបកស្រាយអំពីការចាប់ផ្ដើមលេងរហូតដល់ការបញ្ចប់តុងទីន ព្រមទាំងកិច្ចសន្យាប្រហាក់ប្រហែលនឹងកិច្ចសន្យាលេងតុងទីនតាមរយៈក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ រីឯជំពូកទី២ បង្ហាញពីការទទួលខុសត្រូវក្នុងតុងទីន ដោយបង្ហាញទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌផង។ ចំណែកឯជំពូកទី៣ ដែលជាជំពូកចុងក្រោយនៃសារណានេះ យើងនឹងរំលេចឡើងនូវករណីសិក្សាក្នុងរឿងតុងទីនសម្រាប់ជាការស្វែងយល់បន្ថែម ដែលមានទាំងក្នុងរឿងក្ដីរដ្ឋប្បវេណី ទាំងក្នុងរឿងក្ដីព្រហ្មទណ្ឌផងដែរ។ ជាបន្តទៅទៀតនេះ យើងខ្ញុំសូមធ្វើការបកស្រាយដូចតទៅ៖

# ជំពូកទី១

# ទិដ្ឋភាពទូទៅរបស់តុខទីន

# ជំពូកទី១៖
# ទិដ្ឋភាពទូទៅរបស់តុងទីន

ការលេងតុងទីននៅកម្ពុជា មានទម្រង់ជាការដេញថ្លៃ ដែលយកលំនាំតាមជនជាតិចិន។ នៅក្នុងប្រទេសចិន គេហៅថា **ឈូ ហួយ (CHO HUI)** ជាគំនិតរបស់ជនជាតិចិនម្នាក់ឈ្មោះ **ផាង** (**PHANG**) ហើយឥទ្ធិពលនៃតុងទីនតាមរបៀបចិននេះបានរីកសាយភាយពាសពេញតំបន់អាស៊ីអាគ្នេយ៍ទាំងមូល រួមទាំងកម្ពុជាផងដែរ។ ពួកជនជាតិចិនដែលមករស់នៅតំបន់អាស៊ីអាគ្នេយ៍និយមប្រើប្រាស់ **ឈូ ហួយ** នេះ ដើម្បីផ្គត់ផ្គង់ពាណិជ្ជកម្មរបស់ពួកគេ។[5]

តុងទីនត្រូវបានគេចាត់ទុកថាជាកិច្ចសន្យាដែលយកបុគ្គលជាធំ។ ការយកបុគ្គលជាធំ ជាគំនិតដ៏សំខាន់មួយដែលមានទំនាក់ទំនងជាមួយការទុកចិត្តគ្នារវាងសមាជិកទាំងអស់។[6] បើនិយាយពីការលេងតុងទីនវិញ តុងទីនមួយចំនួនក៏ជោគជ័យ ខណៈតុងទីនមួយចំនួនបានបរាជ័យ ព្រោះត្រូវបានមេតុងទីន ឬកូនតុងទីន ដែលប្រមូលប្រាក់បានហើយក៏រត់ចោលស្រុកជាដើម។ ដូច្នេះ ក្នុងការលេងតុងទីន សមាជិកនីមួយៗផ្តល់ទំនុកចិត្តចំពោះគ្នាទៅវិញទៅមកយ៉ាងខ្លាំង ជាពិសេសទំនុកចិត្តទៅលើមេតុងទីនតែម្តង ដែលជាអ្នកដឹកនាំ និងសម្របសម្រួលតុងទីនទាំងមូល។

ការលេងតុងទីនមិនមានចែងនៅក្នុងច្បាប់ណាមួយបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជាឡើយ។ បើការលេងតុងទីនមានធ្វើជាឯកសារ ឬកិច្ចសន្យានិយាយពីសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួននោះប្រាកដជាអ្នកលេងតុងទីនទាំងអស់មានអារម្មណ៍កក់ក្តៅ និងកាន់តែទុកចិត្តគ្នាខ្លាំងឡើងៗ។ មេតុងទីន និងកូនតុងទីនអាចចងជាកិច្ចសន្យាមុននឹងចាប់ផ្តើមលេង ដែលចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់មេតុងទីន និងកូនតុងទីនជាដើម។

ជាបន្តទៅទៀត យើងនឹងបានសិក្សាទៅលើសញ្ញាណទូទៅនៃតុងទីន (ផ្នែកទី១) និងកិច្ចសន្យាប្រហាក់ប្រហែលនឹងកិច្ចសន្យាលេងតុងទីន តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ (ផ្នែកទី២)។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃតុងទីន

តុងទីនត្រូវបានមនុស្សជាច្រើនស្គាល់ និងបន្តលេងរហូតមកដល់បច្ចុប្បន្ននេះ។ អ្នកដែលលេងតុងទីនទាំងអស់ ប្រាកដជាដឹងពីរបៀបលេងរបស់វាហើយ មុននឹងសម្រេចចិត្តដាក់ទុនលេងនឹងគេ។ ការយល់តែពីរបៀបលេងតែម្យ៉ាងមិនអាចគ្រប់គ្រាន់នោះទេព្រោះពេលខ្លះតុងទីនអាចនឹងមានបញ្ហាកើតឡើងដែលត្រូវការច្បាប់យកទៅដោះស្រាយ ដូច្នេះហើយការលេងតុងទីនត្រូវតែមានឆន្ទៈពិតប្រាកដ និងទំនួលខុសត្រូវខ្ពស់។

នៅក្នុងផ្នែកសញ្ញាណទូទៅនៃតុងទីននេះ យើងនឹងបានសិក្សាអំពីដំណើរការនៃការលេងតុងទីន នៅកថាខណ្ឌទី១ ដែលបង្ហាញពីការលេងតាំងពីដើមរហូតដល់ចប់តុងទីន ហើយនៅកថាខណ្ឌទី២ នឹងរៀបរាប់ពីសិទ្ធិ និងកាតព្វកិច្ចរបស់មេតុងទីន និងកូនតុងទីនចំពោះគ្នាទៅវិញទៅមក។

---

[5] លី វ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ឆ្នាំ២០១៨, ទំព័រទី២ និងទី៣។

[6] លី វ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី១៣។

## កថាភាគទី១៖ ដំណើរការនៃការលេង

ដើម្បីលេងតុងទីនឱ្យទទួលបានភាពជោគជ័យ និងសុវត្ថិភាព សមាជិកទាំងអស់គប្បីលេងជាមួយអ្នកស្គាល់អត្តសញ្ញាណច្បាស់លាស់ ឬមានប្រវត្តិត្រឹមត្រូវ។ គេកម្រឃើញការលេងតុងទីន ដោយខ្វះទំនុកចិត្តរវាងគ្នានឹងគ្នាណាស់ ពីព្រោះថាបើមេតុងទីនមិនស្គាល់កូនតុងទីនដែលមកសុំលេង ក៏មេតុងទីនមិនអនុញ្ញាតឱ្យចូលលេងដែរ។ មេតុងទីនអនុញ្ញាតឱ្យលេង លុះត្រាតែមានបុគ្គលណាម្នាក់មកធានាចំពោះមេតុងទីនថា នៅពេលដែលកូនតុងទីននោះមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ខ្លួននឹងទទួលខុសត្រូវជាដើម។ ដំណាក់កាលជារួម ដែលមានក្នុងការលេងតុងទីនមានការចាប់ផ្តើមលេង ការដេញថ្លៃ និងការបញ្ចប់ដូចខាងក្រោម។

### ១. ការចាប់ផ្តើមលេងតុងទីន

ក្នុងការលេងតុងទីន ជាទូទៅមានភាគីពីរគឺ ភាគីមេតុងទីន និងភាគីកូនតុងទីន។ មេតុងទីន និងកូនតុងទីនម្នាក់ៗត្រូវមានហ៊ុន ឬចំណែកយ៉ាងតិចមួយហ៊ុន ហើយហ៊ុននីមួយៗត្រូវមានតម្លៃស្មើគ្នាជាដាច់ខាត។[7] មួយវិញទៀត កូនតុងទីនម្នាក់ៗ ព្រមទាំងមេតុងទីនអាចមានហ៊ុនច្រើនបាន។[8] តុងទីនមួយគេហៅថា តុងទីនមួយក្បាល ឬមួយហ៊ុន ឬមួយចំណែក ប៉ុន្តែជាទូទៅគេច្រើនហៅថាតុងទីនមួយក្បាល។ ដូច្នេះហើយ ក្នុងតុងទីនមួយមានមេតែម្នាក់ប៉ុណ្ណោះ តែមានកូនតុងទីនច្រើនអាចឡើងដល់ ៤០ ឬ៦០នាក់ក៏មាន។ កូនតុងទីនជាអ្នកបង់ហើយ និងដេញតុងទីន រីឯមេតុងទីនជាអ្នកកណ្តាលរវាងកូនតុងទីនទាំងអស់ ដែលមានបេសកកម្មក្នុងការប្រមូលប្រាក់រៀងរាល់ពេលដេញម្តងៗ និងរៀបចំតុងទីនឱ្យមានដំណើរការរលូនក្នុងការលេងតាំងពីដើមរហូតដល់ចប់តុងទីន។

មុនពេលចាប់ផ្តើមលេង សមាជិកទាំងអស់ត្រូវកំណត់ទំហំសាច់ប្រាក់ក្នុងមួយក្បាល ឬមួយហ៊ុន ថាតើត្រូវលេងតុងទីនតម្លៃប៉ុន្មាន។ ដូច្នេះ តម្លៃហ៊ុនមួយគុណនឹងចំនួនហ៊ុនទាំងអស់ បានជាទុននៃតុងទីន។ ចំណែកឯរយៈពេលនៃការដេញអាចកំណត់ដេញក្នុងមួយថ្ងៃម្តង ឬមួយសប្តាហ៍ម្តង ឬមួយខែម្តង ដែលជាទូទៅគេប្រើរយៈពេលដេញមួយខែម្តង ដែលពេលវេលានៃការដេញនេះ អាស្រ័យលើការព្រមព្រៀងរវាងមេតុងទីន និងកូនតុងទីនទៅតាមស្ថានភាពជាក់ស្តែង ដែលភាគីចង់បាន។ រីឯ ទីតាំងដេញថ្លៃតុងទីនវិញ ក៏ផ្អែកទៅតាមការព្រមព្រៀងរបស់សមាជិកតុងទីនដែរ ប៉ុន្តែភាគច្រើនគេយកតាមទីតាំងរបស់មេតុងទីន ព្រោះមេតុងទីនជាអ្នករៀបចំការដេញតុងទីន។ ឧទាហរណ៍៖ អ្នកលេងតុងទីនមួយក្រុមបានព្រមព្រៀងគ្នាបង្កើតតុងទីនមួយ ដែលតុងទីនមួយក្បាលតម្លៃ ១០០,០០០៛ ហើយបានសន្យាគ្នាថា១សប្តាហ៍ត្រូវដេញថ្លៃម្តង។ ដូច្នេះជារៀងរាល់សប្តាហ៍មេតុងទីនត្រូវរៀបចំការដេញថ្លៃតុងទីន តែមេតុងទីនមិនមែនជាអ្នកដេញទេ ពោលរៀបចំឱ្យកូនតុងទីនណាដែលចង់ដេញតុងទីនប៉ុណ្ណោះ។

---

[7] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី២ មាត្រា៣។

[8] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី៣ មាត្រា៣។

### ២. ការដេញថ្លៃតុងទីន

មេតុងទីនមានសិទ្ធិដកទុននៅឱកាសដំបូង ហើយត្រូវបានទុកទាំងមូល កាលបើមានហ៊ុនច្រើនមេតុងទីននឹងទៅជាអ្នកដេញបានគ្រប់ៗពេលតាមតែខ្លួននៅមានហ៊ុនមិនទាន់ដេញបាននៅឡើយ។[9] ក្នុងន័យនេះ មេតុងទីនមិនចាំចាច់ដេញតុងទីនទេ ពោលខ្លួននឹងទទួលបានទុនទាំងមូលតែម្តង។ ក្រោយពីនោះមក ពេលដេញបន្តបន្ទាប់មកទៀត អ្នកដែលមានហ៊ុនហើយមិនទាន់បានដេញមានសិទ្ធិចូលដេញតុងទីន ផ្ទុយទៅវិញ បើអ្នកដែលបានដេញហើយ មិនមានសិទ្ធិចូលដេញតុងទីនទៀតឡើយចំពោះហ៊ុនដដែលនោះទេ។

ពេលដល់ថ្ងៃដេញតុងទីន កូនតុងទីនមានសិទ្ធិដេញថ្លៃតុងទីន ឬមិនដេញក៏បានជាសិទ្ធិរបស់ខ្លួន។ ការដេញថ្លៃនេះ ជាឱកាសដ៏សារវន្តមួយរបស់កូនតុងទីនក្នុងការប្រមូលប្រាក់ពីតុងទីន។ បើយោងតាមច្បាប់តុងទីនឆ្នាំ១៩៥៤ ត្រង់មាត្រា១១ បានបញ្ញត្តអំពីការចូលដេញថា "អ្នកដែលមានហ៊ុនហើយមិនទាន់បានដេញនៅឡើយ ត្រូវសុំឱ្យការដល់កូនតុងទីនឯទៀត។ អ្នកដេញនោះយកទុនដោយកាច់ការចេញតែប៉ុណ្ណោះតាមទម្លាប់។ នរណាដែលដាក់ការច្រើនជាងគេ អ្នកនោះជាអ្នកដេញបាន។ បើគ្មានសន្យាគ្នាអ្វីផ្សេងទៀតទេ កូនតុងទីនម្នាក់ៗត្រូវប្រគល់ក្រដាសបិទស្រោមឱ្យជិតមួយដាក់ទឹកប្រាក់ដែលខ្លួនព្រមឱ្យនោះទៅមេតុងទីន។ មេតុងទីនត្រូវបើកស្រោមសំបុត្រនោះនៅមុខកូនតុងទីនទាំងអស់។" កូនតុងទីនណាមួយដែលហ៊ានដេញថ្លៃដាក់ការខ្ពស់ជាងគេ កូនតុងទីននោះនឹងក្លាយជាអ្នកដេញតុងទីនបាននាឱកាសនោះ។ ចំណែកឯកូនតុងទីនដែលដេញថ្លៃមិនបាន ត្រូវបង់ប្រាក់ឱ្យមេតុងទីន។ ប្រាក់ដែលកូនតុងទីនត្រូវបង់ គេគិតតាមសមាមាត្រនឹងការ មានន័យថាកូនតុងទីនដែលនៅរស់ត្រូវបង់ដោយយកតម្លៃតុងទីនមួយហ៊ុន ដកចំណែកការចេញ នោះនឹងឃើញប្រាក់ដែលត្រូវបង់ឱ្យមេតុងទីនម្តងៗហើយ។ សមាជិកតុងទីនធ្វើបែបនេះរហូតដល់តុងទីនដាច់ ឬបញ្ចប់។ ចំពោះអ្នកដែលបានប្រមូលប្រាក់ ក្រោយការដេញតុងទីនមួយលើកៗរួច គឺពុំមានសិទ្ធិដេញតុងទីនយកជាលើកទី២ចំពោះហ៊ុនដដែលនោះទេ ពោលមានតែកាតព្វកិច្ចបង់ប្រាក់ជាបន្តបន្ទាប់ទៅឱ្យមេតុងទីនប៉ុណ្ណោះ។ ចំណែកឯអ្នកដែលមិនទាន់បានដេញតុងទីន ក៏មានកាតព្វកិច្ចបង់ប្រាក់ចំណែកហ៊ុនចូលទៅក្នុងតុងទីនផងដែរ ប៉ុន្តែអាចមានសិទ្ធិដេញតុងទីនបាន។ ហេតុនេះ ការដេញតុងទីនត្រូវដេញច្រើនដងស្មើនឹងចំនួនហ៊ុន [10] ដែលមាននៅក្នុងតុងទីននោះ។

ឧទាហរណ៍: **ក ខ គ** និងអ្នកផ្សេងទៀតបាននាំគ្នាលេងតុងទីនមួយក្បាល១០០$ ដែលមានគ្នា៥0នាក់ (សន្មតថាលេងម្នាក់មួយក្បាល) និងយល់ព្រមដេញជារៀងរាល់ខែរហូតដល់អស់សមាជិក។

- **នៅខែទី១៖** មេតុងទីនជាអ្នកមានសិទ្ធិដកទុនទាំងមូល មានន័យថាកូនតុងទីនម្នាក់ត្រូវបង់ ១០០$ ពេញ ឱ្យទៅមេតុងទីន។ មេតុងទីនបានប្រាក់សរុប៥០០០$ ប៉ុន្តែត្រូវដកមួយក្បាលចេញ ដែលជាចំណែករបស់មេតុងទីន

[9] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា៦។

[10] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី៣ មាត្រា៤។

ដូច្នេះមេតុងទីនបានប្រាក់សរុប ៤,៩០០$។ ចាប់ពីខែទី២ទៅ ជាឱកាសសម្រាប់កូនតុងទីនប្រជែងគ្នាក្នុងការដេញថ្លៃតុងទីន។

- **នៅខែទី២៖ ក** បានដេញថ្លៃដាក់ការ២០$ខ្ពស់ជាងគេក្នុងចំណោមអ្នកដេញផ្សេងទៀត ដូច្នេះ **ក** ជាអ្នកដេញបាននៅខែទី២។ ក្នុងខែទី២នេះ តុងទីនងាប់សរុបចំនួន ២ក្បាល ហើយនៅរស់ចំនួន៤៨ក្បាល។

ដូច្នេះ ចំនួនប្រាក់ដែល **ក** ត្រូវទទួលបាន = [ចំនួនសរុបតុងទីននៅរស់×(តម្លៃតុងទីនក្នុងមួយក្បាល-ការដែលដេញបាន)]+(ចំនួនសរុបតុងទីនងាប់×តម្លៃតុងទីនក្នុងមួយក្បាល)

=[៤៨×(១០០-២០)]+(២×១០០)=**៤,០៤០**$។

មកដល់ដំណាក់កាលនេះ តុងទីនរបស់ **ក** គេហៅថាតុងទីនងាប់ ដូច្នេះខ្លួនមិនចាំបាច់ប្រគល់ចំណែកតុងទីនងាប់ឱ្យមេតុងទីន ហើយមេតុងទីនប្រគល់ប្រាក់នោះឱ្យវិញទេ ពោលយើងត្រូវយក ៤០៤០$-១០០$=៣,៩៤០$។ ដូចនេះប្រាក់តុងទីនដែលមេតុងទីនត្រូវប្រគល់ជាក់ស្តែងឱ្យកូនតុងទីនសរុប ៣,៩៤០$។ ដោយសារតែ **ក** បានដេញរួចហើយ នៅខែទី៣ **ក** មិនមានសិទ្ធិក្នុងការដេញទៀតទេ។

- នៅខែបន្តបន្ទាប់ទៀត៖ គេត្រូវធ្វើការដេញថ្លៃបែបនេះ រហូតដល់សមាជិកទី៤៩ ចំណែកឯសមាជិកទី៥០ វិញមិនចាំបាច់ដេញថ្លៃសុំឱ្យការទេ ពោលត្រូវទទួលបានទុនទាំងស្រុងដូចមេតុងទីនទទួលបាននៅខែដំបូងដែរ។

### ៣. ការបញ្ចប់តុងទីន

ការបញ្ចប់នេះអាចកើតឡើង គឺអាស្រ័យទៅលើសមាជិកដែលចូលរួមលេងម្នាក់ៗ។ ក្នុងការលេងតុងទីន តុងទីនខ្លះបានបញ្ចប់ដោយជោគជ័យ ដោយសារមានការសហការគ្នារវាងកូនតុងទីនទាំងអស់ និងមានទំនួលខុសត្រូវរៀងៗខ្លួន ឯខ្លះទៀតបញ្ចប់ដោយបរាជ័យ។ ដូច្នេះ ការបញ្ចប់តុងទីនអាចកើតឡើងពីររបៀបគឺ របៀបទីមួយៈ ការបញ្ចប់តុងទីនដោយការមកដល់នៃរយៈពេលតុងទីន និងរបៀបទីពីរៈ ការបញ្ចប់តុងទីនដោយរំលាយមុនពេលកំណត់។

#### ៣.១. ការបញ្ចប់តុងទីនដោយការមកដល់នៃរយៈពេលតុងទីន

ក្នុងការលេងតុងទីនរបស់ក្រុមនីមួយៗតែងតែចង់បានភាពជោគជ័យ ដើម្បីទទួលបានផលជាផ្លែផ្កា ដែលកើតចេញពីការខិតខំរបស់ខ្លួន។ កាលបើនៅសល់ហ៊ុនតែមួយមិនទាន់ដេញបាននោះ អ្នកមានសិទ្ធិបានទុនទាំងមូលមិនចាំបាច់សុំឱ្យការឡើយ តុងទីនក៏ត្រូវផុតត្រឹមនេះដែរ។ [11] ការបញ្ចប់តុងទីននេះ សំដៅដល់ការបានដេញថ្លៃ គ្រប់សមាជិកតុងទីនទាំងអស់រួចហើយ លើកលែងតែមេតុងទីន និងកូនតុងទីនចុងក្រោយដែលត្រូវទទួលទុនទាំងមូលដោយមិនដេញថ្លៃ។ នៅពេលនោះហើយ តុងទីនក៏បញ្ចប់ដោយភាពជោគជ័យ ករណីនេះតែងតែកើតមានឡើង ភាគច្រើនជាមួយមនុស្សមានទំនុកចិត្តគ្នាទៅវិញទៅមក និងសមាជិកតុងទីន ដែលគោរពកិច្ចសន្យា ឬបង់ប្រាក់ទៀងទាត់

[11] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា១២។

ទៅឱ្យមេតុងទីន។ ជាពិសេស ប្រសិនបើលេងប៉ះមេតុងទីន ដែលមានទ្រព្យធន និងមានទំនួលខុសត្រូវខ្ពស់ តុងទីនភាគច្រើនសុទ្ធតែទទួលបានជោគជ័យ ហើយកូនតុងទីនក៏មានឆន្ទៈបន្តលេងជាមួយមេតុងទីនដដែលនោះដែរ។ ករណីនេះបង្ហាញឱ្យឃើញថា ទំនុកចិត្ត និងទំនួលខុសត្រូវពិតជាធាតុសំខាន់ណាស់ក្នុងការលេងតុងទីនមួយប្រកបដោយភាពជោគជ័យ។

នៅពេលដែលតុងទីនបានបញ្ចប់ជាស្ថាពររួចមក សមាជិកតុងទីននីមួយៗលែងមានជាប់កាតព្វកិច្ចជាមួយតុងទីន ចាស់ទៀតហើយ វៀរលែងតែកូនតុងទីន ឬមេតុងទីនណា ដែលមិនទាន់អនុវត្តកាតព្វកិច្ចបានពេញលេញ។ មានន័យថា តុងទីនបានចប់ហើយ ប៉ុន្តែសមាជិកតុងទីនមិនទាន់អនុវត្តកាតព្វកិច្ចប្រគល់ ឬបង់ប្រាក់តុងទីននៅឡើយ។ ងាកមកកាន់ការបញ្ចប់តុងទីនយើងវិញ នៅពេលបញ្ចប់ អ្នកលេងតុងទីនអាចឈប់លេងតុងទីន ឬអាចធ្វើការបង្កើតក្រុមមួយទៀត ហើយជ្រើសរើសមេតុងទីនថ្មីក៏បាន មេតុងទីនចាស់ក៏បាន ដោយមានការកំណត់លក្ខខណ្ឌណាមួយ ហើយអនុវត្តបន្តបន្ទាប់ដូចតុងទីនមុនដែរ។

### ៣.២. ការបញ្ចប់តុងទីនដោយរំលាយតុងទីនមុនពេលកំណត់

ជួនកាលខ្វះកូនតុងទីនឈប់សងប្រាក់ច្រើនគ្នា នាំឱ្យមេតុងទីនរំលាយតុងទីនមុនអាយុតុងទីន។ [12] ករណីនេះយើងក៏សង្កេតឃើញនៅកម្ពុជា ដែលកើតឡើងដោយសារតែមេតុងទីនបោកប្រាស់កូនតុងទីន ហើយមិនទទួលខុសត្រូវក្នុងការបន្តតុងទីន ហើយករណីខ្លះមានកូនតុងទីនច្រើនឈប់បង់ប្រាក់តុងទីន ជាហេតុនាំឱ្យមេតុងទីនមិនអាចមានលទ្ធភាពបង់តុងទីនជំនួសកូនតុងទីនទាំងនោះ។ បើនិយាយឱ្យងាយយល់វិញ គឺការបញ្ចប់នូវការលេងតុងទីន ដោយមានកូនតុងទីនខ្លះមិនទាន់បានដេញក៏មាន។ ការរំលាយមុនកំណត់នេះ គឺអាចធ្វើទៅបានកាលណា មានសមាជិកតុងទីនមួយចំនួនមិនបានធ្វើតាមកិច្ចសន្យានៃការលេង ឬមិនបង់ប្រាក់ឱ្យទៅមេតុងទីន ហើយមេតុងទីនមិនមានលទ្ធភាពក្នុងការបង់ប្រាក់ជំនួសកូនតុងទីនទាំងនោះបាន ពេលនោះហើយមេតុងទីនមានសិទ្ធិពិភាក្សាជាមួយសមាជិកតុងទីនដទៃទៀតបាន ដោយធ្វើការរំលាយមុនកាលកំណត់នៃការមកដល់បាន។ ករណីខ្លះរំលាយមុនកំណត់ដោយសារតែមេតុងទីនមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាញឹកញាប់ ឬរត់ចោលស្រុក ដែលជាហេតុនាំឱ្យមិនមានអ្នកចាត់ចែង រៀបចំតុងទីនបន្តទៀត។ ចំណែកឯក្នុងច្បាប់បច្ចុប្បន្ននេះ យើងសង្កេតឃើញថា ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ [13] ខ្លឹមសារច្បាប់ត្រង់បញ្ញត្តិនេះក៏មានភាពស្រដៀងនឹងការរំលាយតុងទីនមុនអាយុកាលដែរ។

[12] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី១ មាត្រា១៤។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤០៧។

នៅពេលដែលតុងទីនត្រូវរំលាយវានឹងផ្តល់អានុភាពប្រតិសកម្ម។[14] អ្នកមិនភៀសខ្លួនទាំងឡាយ ដែលជាអ្នកដេញបានត្រូវប្រគល់ប្រាក់ឱ្យមេតុងទីនតាមចំណែករបស់ខ្លួនគុណនឹងចំនួនពេលដេញ ដែលមិនទាន់បានដេញ។ រីឯប្រាក់នេះតម្រូវឱ្យចេញតាំងពីថ្ងៃរំលាយតុងទីនមក។[15] ពេលទទួលបានប្រាក់នេះ មេតុងទីនត្រូវសងទៅកូនតុងទីនដែលមិនភៀសខ្លួន ហើយពុំមែនជាអ្នកដេញបាននូវប្រាក់តាមចំណែក ដែលអ្នកនោះបានបង់ទាំងប៉ុន្មានឱ្យគ្រប់ចំនួន វៀរលែងតែមេតុងទីនបានប្តឹងពីកូនតុងទីន ដែលជាអ្នកដេញបានពីមុនៗ។[16] ការរំលាយតុងទីននេះនឹងធ្វើឱ្យមានបញ្ហាស្មុគស្មាញកើតមានឡើង ក្នុងន័យនេះ កូនតុងទីនដែលបានដេញរួចហើយត្រូវយកប្រាក់ ដែលខ្លួនដេញបានទៅប្រគល់ជូនមេវិញ ដើម្បីធ្វើការចាត់ចែងប្រាក់នោះទៅឱ្យអ្នកដែលមិនទាន់បានដេញតាមចំណែករៀងៗខ្លួន។ បើនិយាយឱ្យខ្លីទៅ ការធ្វើបែបនេះប្រៀបបីដូចជាគ្មានការលេងតុងទីនតាំងពីដំបូងអីញ្ចឹង ព្រោះអ្នកដែលបានបង់តុងទីនអស់ប៉ុន្មាន ត្រូវទទួលបានប៉ុណ្ណោះវិញ រីឯអ្នកដែលដេញបានប្រាក់ទាំងប៉ុន្មាន ត្រូវប្រគល់ឱ្យមេតុងទីនចាត់ចែងបន្តឱ្យទៅអ្នកដែលមិនទាន់ដេញបាន។ ការធ្វើបែបនេះ គឺជាការធានារបស់មេតុងទីនទៅលើសមាជិកតុងទីនម្នាក់ៗ ហើយបើមេតុងទីនមិនមានប្រាក់គ្រប់គ្រាន់ក្នុងការសងទេ មេតុងទីនអាចលក់ឡាយឡុងទ្រព្យរបស់ខ្លួន ឬប្តឹងកូនតុងទីនដែលមិនព្រមប្រគល់ប្រាក់ត្រលប់មកវិញ ដើម្បីសងប្រាក់ឱ្យបានគ្រប់ចំនួន។

បន្ទាប់ពីបានស្វែងយល់អំពីដំណើរការនៃការលេងតុងទីនរួចហើយមក បន្តទៅទៀតនេះ ជាការពន្យល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់មេ និងកូនតុងទីន ។

## កថាភាគទី២៖ សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី

សិទ្ធិ គឺជាអ្វីមួយ ដែលអនុញ្ញាតឱ្យសេរីភាពនៃជនម្នាក់ស្របជាមួយនឹងសេរីភាពនៃជនទាំងអស់ ហើយអាចឱ្យមនុស្សធ្វើនេះ ឬធ្វើនោះដោយស្ថិតនៅក្រោមដែនកំណត់នៃច្បាប់។ រីឯកាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្ត ដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ ដែលបានកំណត់ មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។[17] យើងអាចនិយាយបានថា បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះ ហៅថាម្ចាស់បំណុល ហើយម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល។

ដូចដែលយើងបានដឹងស្រាប់ហើយថា ក្នុងការលេងតុងទីន ជាទូទៅមានពីរភាគីគឺ ភាគីមេតុងទីន និងភាគីកូនតុងទីន។ មេតុងទីនមានទំនួលខុសត្រូវខ្ពស់ក្នុងការប្រមូលប្រាក់ពីកូនតុងទីនទាំងអស់ ហើយប្រគល់ឱ្យអ្នកដែលដេញ

[14] លី រ៉ុង, *តុងទីន* (២០១៨) , ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី៣០។

[15] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២៥។

[16] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២៦។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣០៨។

តុងទីនបានឱ្យទាន់ពេលវេលា។ ចំណែកឯកូនតុងទីនវិញមានសិទ្ធិដេញតុងទីន និងត្រូវបង់ប្រាក់ទៅមេតុងទីនឱ្យបានទាន់ពេលវេលា។

**១. សិទ្ធិ និងភារកិច្ចរបស់មេតុងទីន**

ក្នុងនាមជាអ្នកចាត់ចែងការលេងតុងទីន មេតុងទីនចាំបាច់ត្រូវមានសិទ្ធិ ដែលជាការព្រមព្រៀងផ្តល់ឱ្យដោយកូនតុងទីន។ ទន្ទឹមនឹងមានសិទ្ធិដែលផ្តល់ដោយកូនតុងទីន មេតុងទីនក៏ត្រូវជាប់កាតព្វកិច្ចមួយចំនួន ដែលជាកាតព្វកិច្ចដ៏សំខាន់ក្នុងការលេងតុងទីន។

**១.១. សិទ្ធិរបស់មេតុងទីន**

ជាទូទៅមេតុងទីនតែងតែមានសិទ្ធិក្នុងការគ្រប់គ្រងកូនតុងទីននីមួយៗ ហើយជាអ្នកមានគំនិតក្នុងការសម្រេច និងពិភាក្សារាល់ពេលតុងទីនជួបបញ្ហា។ សិទ្ធិរបស់មេតុងទីនប្រៀបបីដូចជាមេដឹកនាំម្នាក់ ព្រោះកូនតុងទីនផ្តល់សេចក្តីទុកចិត្តឱ្យមេតុងទីនចាត់ចែងប្រាក់របស់ខ្លួន ដូច្នោះខ្លួនត្រូវផ្តល់សិទ្ធិឱ្យមេតុងទីនក្នុងការសម្រេចបញ្ហានានាដែលពាក់ព័ន្ធនឹងការលេងតុងទីននេះ។

មេតុងទីនមានសិទ្ធិដកទុននៅឱកាសលើកដំបូង ហើយត្រូវបានទុនទាំងមូល កាលបើមានហ៊ុនច្រើន មេតុងទីននឹងទៅជាអ្នកដេញបានគ្រប់ៗពេលតាមតែខ្លួននៅមានហ៊ុនមិនទាន់ដេញបាននៅឡើយ។[18] តាមន័យនេះ ចង់បញ្ជាក់ពីការផ្តល់ប្រាក់ក្នុងឱកាសដំបូងទៅឱ្យមេតុងទីន ព្រោះជាលក្ខន្តិកៈរបស់អ្នកលេងតុងទីននីមួយៗ។ ក្នុងការផ្តល់សិទ្ធិឱ្យមេតុងទីនត្រូវទទួលបានទុនទាំងមូលនាពេលដំបូងនេះ នៅតំបន់ខ្លះសមាជិកតុងទីនឱ្យដាច់តែម្តង មានន័យថាមេតុងទីនមិនមានកាតព្វកិច្ចត្រូវបង់តុងទីនបន្ទាប់ពីលើកដំបូងនោះទេ រីឯនៅតំបន់ខ្លះ មេតុងទីនត្រូវបង់តុងទីនបន្ទាប់ពីបានទុនទាំងមូលនាលើកដំបូងនោះ រហូតដល់អស់សមាជិក។[19]

មួយវិញទៀត មេតុងទីនមានសិទ្ធិរំលាយតុងទីនមុនកំណត់ (ដូចមានបកស្រាយនៅចំណុច ៣.២ ខាងលើ) ក្នុងករណីដែលកូនតុងទីនភាគច្រើនឈប់បង់តុងទីនជាអាទិ៍។ ការសម្រេចត្រូវមានការពិភាក្សាគ្នាជាមួយនិងកូនតុងទីនឯទៀត ទើបមេតុងទីនជាអ្នកសម្រេចចុងក្រោយថាតើត្រូវរំលាយ ឬក៏មិនរំលាយ។

**១.២. ភារកិច្ចរបស់មេតុងទីន**

បេសកកម្មនៃមេតុងទីន ត្រូវប្រមូលទុន ចាត់ចែងឱ្យដេញ និងប្រគល់ប្រាក់ទៅឱ្យអ្នកដេញបាន។[20] បេសកកម្មនេះ ជាបេសកកម្មដ៏សារវន្តរបស់មេតុងទីន ក្នុងនាមជាអ្នកដឹកនាំតុងទីនមួយតាំងពីដើមរហូតដល់ចប់តុងទីន។ រាល់ពេលដេញតុងទីនម្តងៗ មេតុងទីនជាអ្នករៀបចំជាមួយកូនតុងទីនឯទៀត ហើយនៅពេលដែលកូនតុងទីនណាម្នាក់

[18] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា៩។

[19] លី វ៉ុង, *តុងទីន* (២០១៨) , ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី១៦។

[20] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី២ មាត្រា៨។

ដេញតុងទីនបានហើយ មេតុងទីនត្រូវចាប់ផ្តើមប្រមូលទុនតុងទីនពីកូនតុងទីនឯទៀតឱ្យបានគ្រប់ៗគ្នា។ ពេលដែលប្រមូលបានគ្រប់ៗគ្នា និងគ្រប់ចំនួនរួចហើយ មេតុងទីនត្រូវប្រគល់ប្រាក់ឱ្យទៅអ្នកដែលដេញបាននាពេលនោះ។

មេតុងទីន ដែលជាអ្នកកណ្តាលរវាងកូនតុងទីនទាំងអស់ ត្រូវទទួលខុសត្រូវក្នុងការប្រព្រឹត្តទៅនៃតុងទីន។[21] ក្នុងន័យនេះ ជួនកាលមានកូនតុងទីនខ្លះបង់ប្រាក់មិនទាន់ពេលវេលា មេតុងទីនក៏មានកាតព្វកិច្ចត្រូវរ៉ាប់រងចេញជួសកូនតុងទីនតាមចំណែកកូនតុងទីននោះ។ ក្នុងករណីដែលកូនតុងទីនរត់គេចខ្លួន មេតុងទីនក៏នៅតែមានកាតព្វកិច្ចក្នុងការបង់ជំនួសកូនតុងទីននោះដែរ ព្រោះថាខ្លួនជាអ្នកធានាឱ្យការប្រព្រឹត្តទៅរបស់តុងទីនមានភាពរលូនតាំងពីដើមរហូតដល់ចប់ បើមិនដូច្នេះទេ មេតុងទីននឹងប្រឈមមុខទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ២. សិទ្ធិ និងកាតព្វកិច្ចរបស់កូនតុងទីន

មេតុងទីនមានសិទ្ធិ និងកាតព្វកិច្ចដែលត្រូវអនុវត្ត ចំណែកឯកូនតុងទីនក៏មានសិទ្ធិ និងកាតព្វកិច្ចដែលត្រូវអនុវត្តចំពោះគ្នាទៅវិញទៅមកផងដែរ។ ទិដ្ឋភាពជារួមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់កូនតុងទីននឹងត្រូវយកមកបកស្រាយដូចខាងក្រោមនេះ។

### ២.១. សិទ្ធិរបស់កូនតុងទីន

ចំពោះសិទ្ធិ ដែលសំខាន់សម្រាប់កូនតុងទីន គឺការដេញតុងទីន។ ការដេញតុងទីននេះជាសិទ្ធិរបស់កូនតុងទីនក្នុងការសម្រេចចិត្តថា ខ្លួនត្រូវដេញតុងទីន ឬក៏មិនដេញនៅពេលនីមួយៗ។ ចំពោះការដាក់ការក្នុងការដេញតុងទីនវិញ កូនតុងទីនអាចដាក់ការប៉ុន្មានក៏បាន ដោយផ្អែកទៅតាមការសង្កេតមើលការដេញកន្លងមក និងចំនួនអ្នកដេញនាឱកាសនោះ ហើយសម្រេចតាមឆន្ទៈរបស់ខ្លួន តែបើកូនតុងទីននោះត្រូវការប្រាក់បន្ទាន់ ត្រូវតែដាក់ការឱ្យខ្ពស់ជាងគេ ទើបអាចដេញតុងទីនបាន។ ក្នុងការលេងតុងទីន គេមិនបានកំណត់អំពីថ្លៃការប៉ុន្មានក្នុងការដេញជារៀងរាល់ខែនោះទេ ពោលវាផ្អែកទៅតាមស្ថានភាពជាក់ស្តែងនីមួយៗនៅពេលដេញម្តងៗ។ ជួនកាលការខ្ពស់ នៅពេលមានអ្នកដេញច្រើន ហើយពេលខ្លះការទាបនៅពេលដែលមានអ្នកដេញតិច។ បើការខ្ពស់ជាឱកាសចំណេញរបស់កូនតុងទីនដែលនៅរស់ ព្រោះខ្លួនត្រូវបង់តិច ហើយបើការទាបវិញមិនផ្តល់ផលចំណេញច្រើនដល់កូនតុងទីនដែលនៅរស់ទេ ចំណែកឯតុងទីនដែលងាប់ហើយមិនចំណេញការអ្វីទៀតនោះទេ ដោយហេតុថាខ្លួនត្រូវបង់តុងទីនពេញជារៀងរាល់ពេលដេញម្តងៗរួចទៅហើយ។

មួយវិញទៀត នៅពេលតុងទីនមានបញ្ហា កូនតុងទីនក៏មានសិទ្ធិចូលរួមក្នុងការពិភាក្សាជាមួយមេតុងទីន និងកូនតុងទីនឯទៀតក្នុងការស្វែងរកដំណោះស្រាយនានា ដែលសមស្រប។ ក្នុងនោះដែរ បើសិនជាកូនតុងទីនភាគច្រើន

[21] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, កថាខណ្ឌទី១ មាត្រា១៣។

ឈប់បង់តុងទីន កូនតុងទីនដែលមិនភៀសខ្លួនមានសិទ្ធិពិភាក្សាជាមួយសមាជិកតុងទីន ក្នុងការសម្រេចថាតើគួរ រំលាយតុងទីនមុនកំណត់ ឬបន្តលេងទៀត។

ដោយយោងតាមមាត្រា២០ នៃច្បាប់ស្តីពីតុងទីន ឆ្នាំ១៩៥៤ បានផ្តល់សិទ្ធិមួយទៀត ដែលកូនតុងទីនអាចធ្វើបាននោះគឺ ការលក់ហ៊ុនរបស់ខ្លួនទៅអោយអ្នកផ្សេង ដោយមានការយល់ព្រមពីមេតុងទីនដែរ។ ក្នុងករណីនេះអាចកើតឡើងនៅពេលដែលកូនតុងទីនមិនចង់លេងបន្តឬគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់តុងទីនបន្តទៀតជាអាទិ៍។ ការធ្វើបែបនេះ គឺស្មើនឹងការផ្ទេរសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទៅឱ្យអ្នកផ្សេងទទួលបន្ត ដោយទទួលបានតម្លៃថ្នូរមកវិញ។ តម្លៃថ្នូរនេះផ្អែកទៅតាមការចរចាររវាងភាគីកូនតុងទីន និងអ្នកទទួលបន្តចំណែកតុងទីនរបស់ខ្លួន ថាតើត្រូវលក់ទិញក្នុងតម្លៃណាមួយឱ្យប្រាកដ។ បន្ថែមពីនោះទៀត ការលក់ទិញតុងទីនក៏ត្រូវមានការយល់ព្រមពីមេតុងទីន ដែលករណីនេះខុសពីការលក់ទិញវត្ថុផ្សេងៗដោយគ្រាន់តែមានការព្រមព្រៀងគ្នារវាងតែអ្នកលក់ និងអ្នកទិញតែប៉ុណ្ណោះ។

### ២.២. កាតព្វកិច្ចរបស់កូនតុងទីន

មុននឹងចាប់ផ្តើមលេងតុងទីន កូនតុងទីនទាំងអស់ត្រូវតែដឹងថាខ្លួនមានកាតព្វកិច្ចដ៏សំខាន់មួយនោះគឺ ការបង់ប្រាក់ឱ្យបានទៀងទាត់ទៅមេតុងទីន។ ក្នុងន័យនេះ កូនតុងទីនណា ដែលមិនយកប្រាក់ហ៊ុនតាមចំនួនដែលខ្លួនលេងទៅប្រគល់ឱ្យមេនៅពេលដេញម្តងៗ ត្រូវចាត់ទុកជាភៀសខ្លួន។[22] ហេតុនេះ បើអ្នកភៀសខ្លួនមិនទាន់ដេញបានទេ អ្នកនោះត្រូវបាត់អំណាចជាសមាជិកក្នុងតុងទីន ព្រមទាំងគ្មានសិទ្ធិនឹងទាមទារប្រាក់ ដែលខ្លួនបានបង់រួចមកហើយនោះផង។[23] ជាទូទៅកូនតុងទីន ដែលមិនទាន់ដេញតុងទីនបាន ពួកគេមិនពិបាកប្រមូលលុយទេ ព្រោះតុងទីនរបស់ពួកគេនៅរស់ យ៉ាប់តែកូនតុងទីនមួយចំនួនតូច ដែលពិបាកក្នុងការប្រមូលក្រោយពេលដេញរួចហើយនោះ។ ម្យ៉ាងវិញទៀត បើមានកូនតុងទីនណាមិនបង់ប្រាក់ទេ មេតុងទីននោះហើយជាអ្នកធានារ៉ាប់រងបង់ជំនួស។ ដូច្នោះ មុនពេលលេងម្តងៗ មេតុងទីនគប្បីស្វែងយល់អំពីកម្រិតជីវភាព ទំនួលខុសត្រូវ និងភាពស្មោះត្រង់របស់កូនតុងទីនម្នាក់ៗឱ្យបានច្បាស់ជាមុនសិន មុននឹងអនុញ្ញាតឱ្យចូលលេង ជៀសវាងហានិភ័យកើតមានចំពោះមេតុងទីនខ្លួនឯងនៅថ្ងៃក្រោយ។

ក្នុងនាមជាសមាជិកតុងទីនម្នាក់ កូនតុងទីនត្រូវមើលការវិវត្តរបស់តុងទីន ជាពិសេសត្រូវមើលរបៀបដេញដាក់ការជាដើម។ កូនតុងទីនមិនដាក់ការនៅពេលដេញណាមួយ ត្រូវទុកជាបោះបង់ចោលសិទ្ធិរបស់ខ្លួនជាអ្នកដេញនៅពេលនោះ។[24] ទោះបីជាយ៉ាងណា ការមិនដាក់ការប្រាក់នេះនឹងមិនអនុវត្តទៅលើកូនតុងទីនចុងក្រោយទេ ព្រោះកូនតុងទីនចុងក្រោយជាអ្នកប្រមូលទាំងអស់ដោយមិនចាំបាច់ដាក់ការ ដោយសារតែគ្មានអ្នកប្រកួតប្រជែងក្នុងការដេញថ្លៃនោះទេ។

---

[22] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា១៨។

[23] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា១៩។

[24] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា១៧។

បន្ទាប់ពីបានស្វែងយល់ពីសញ្ញាណទូទៅរបស់តុងទីនរួចហើយមក ជាបន្តទៅទៀតនេះ យើងនឹងស្វែងយល់អំពីមូលដ្ឋានគតិយុត្តក្នុងកិច្ចសន្យាតុងទីន តាមរយៈក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញម្តង។

**ផ្នែកទី២៖ កិច្ចសន្យាប្រហាក់ប្រហែលនឹងកិច្ចសន្យាលេងតុងទីន តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧**

តាមច្បាប់តុងទីនសម័យសង្គមរាស្ត្រនិយម កិច្ចសន្យាតុងទីនត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានចុះហត្ថលេខាគូសញ្ញា មានបិទតែម និងប្រថាប់ត្រាលើបន្ទុកដោយប្រធានតុងទីន។ ទម្រង់ការនេះ បើពុំបានបំពេញទេ កិច្ចសន្យាត្រូវទុកជាមោឃៈជាដាច់ខាត។ កិច្ចសន្យានៃតុងទីនមាន[កម្រិត]យ៉ាងនេះ[25] ៖

**១-** ឈ្មោះមេតុងទីន

**២-** ឈ្មោះកូនតុងទីន

**៣-** ចំនួនហ៊ុន

**៤-** តម្លៃហ៊ុននីមួយៗ ព្រមទាំងតម្លៃទុននៃតុងទីន

**៥-** ចំនួនដេញត្រូវស្មើនឹងចំនួនហ៊ុន

**៦-** កាលបរិច្ឆេទត្រូវដេញ ទីកន្លែងត្រូវធ្វើ ព្រមទាំងបែបបទទាំងឡាយ។

ចំណែកឯបច្ចុប្បន្ននេះ យើងសង្កេតឃើញថាមិនមានលិខិតបទដ្ឋានគតិយុត្តណាមួយចែងអំពីកិច្ចសន្យាតុងទីនឱ្យច្បាស់លាស់នោះទេ ពោលកិច្ចសន្យាតុងទីន ដែលមានទម្រង់ការ ឬលក្ខន្តិកៈក្នុងការលេងនេះ គឺផ្អែកទៅតាមការព្រមព្រៀងរបស់ភាគី ហើយលក្ខន្តិកៈទាំងនោះជាការអនុវត្តតៗគ្នាតែប៉ុណ្ណោះ។បើយោងទៅតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ននេះ កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។[26] ក្នុងនោះដែរ កិច្ចសន្យាអាចធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬធ្វើឡើងដោយផ្ទាល់មាត់។ ហេតុនេះហើយទើបតុងទីនត្រូវមានកិច្ចសន្យា ដើម្បីឱ្យមានសុពលភាពក្នុងការលេង និងបង្កើតអានុភាពចំពោះភាគី ព្រោះថាបើមិនមានការព្រមព្រៀងគ្នាក្នុងការលេងតុងទីនទេ តុងទីននោះក៏មិនអាចកើតមានដែរ។ ជាទូទៅកិច្ចសន្យាទាំងឡាយនឹងយកជាការបាន លុះត្រាតែកាតព្វកិច្ចនៃកិច្ចសន្យានោះ កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ដោយមិនមានការភាន់ច្រឡំ ហើយមិនមានការប្រើហិង្សា ឬការបន្លំបោកប្រាស់។

ចំពោះក្នុងរឿងតុងទីននេះវិញ គឺជាកិច្ចសន្យាមួយ ដែលភាគីបានព្រមព្រៀងគ្នាឡើង ដើម្បីសម្រួលដល់ជីវភាពអ្នកត្រូវការប្រាក់បន្ទាន់ ឬការធ្វើជំនួញរបស់ពួកគេ។ យ៉ាងណាក៏ដោយ គ្រប់ភាគីទាំងអស់មុននឹងចាប់ផ្តើមលេងសុទ្ធតែ

[25] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា៥។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣១១។

មានការយល់ព្រម និងព្រមព្រៀងគ្នាក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាមេតុងទីន ឬក្នុងនាមជាកូនតុងទីន ហើយក៏ត្រូវបានដឹងថាខ្លួនមានកាតព្វកិច្ចអ្វីខ្លះចំពោះភាគីម្ខាងទៀតដែរ។

យ៉ាងណាមិញ តុងទីនអាចស្ថិតនៅលើកិច្ចសន្យាច្រើនប្រភេទ ដែលជាកិច្ចសន្យាប្រហាក់ប្រហែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ យើងនេះ។ ផ្អែកទៅលើការសិក្សា ស្រាវជ្រាវ និងវិភាគ យើងសង្កេតឃើញថា តុងទីនអាចស្ថិតនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាលក់ទិញ។

**កថាភាគទី១៖ កិច្ចសន្យាខ្ចីបរិភោគ**

កិច្ចសន្យាខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងហៅថាអ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ស្រូវ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀតហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើនឹងវត្ថុ ដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។[27] ក្នុងករណីដែលអ្នកឱ្យខ្ចីបានឱ្យខ្ចីប្រាក់ ឬស្រូវ អ្នកខ្ចីមានសេរីភាពក្នុងការប្រើប្រាស់ប្រាក់ ឬស្រូវនោះបាន ហើយអ្នកខ្ចីនោះមានករណីយកិច្ចសងទៅអ្នកឱ្យខ្ចីវិញនូវប្រាក់ដែលមានចំនួនស្មើ ឬនូវស្រូវដែលមានប្រភេទ បរិមាណដូចគ្នា ក្រោយពីអំឡុងពេលមួយបានកន្លងផុតទៅ។ ការខ្ចីបរិភោគនេះមានពីរប្រភេទ គឺករណីដែលមានការប្រាក់ និងករណីដែលគ្មានការប្រាក់ ហើយកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺជាវិធីដ៏សំខាន់មួយសម្រាប់សកម្មភាពសេដ្ឋកិច្ច ដែលផ្តល់ជាប្រយោជន៍ដល់ម្ចាស់បំណុល។

នៅក្នុងការលេងតុងទីនបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តរវាងមេតុងទីន និងកូនតុងទីន។ មេតុងទីនមានតួនាទីជាអ្នកប្រមូលប្រាក់ពីកូនតុងទីនទាំងអស់ ដែលដេញមិនបានទៅឱ្យកូនតុងទីនដែលដេញបាន។ ចំណែកឯកូនតុងទីនជាប់កាតព្វកិច្ចបង់ប្រាក់ជាប្រចាំទៅឱ្យមេតុងទីនតាមការដេញមួយលើកៗ។ ចំពោះចំណងគតិយុត្តរវាងកូនតុងទីន និងកូនតុងទីនមិនចងដូចមេតុងទីន និងកូនតុងទីនទេ ដោយសារតែមេតុងទីន និងកូនតុងទីនមានកាតព្វកិច្ចត្រូវបំពេញគ្នាទៅវិញទៅមក ប៉ុន្តែយើងមិនសង្កេតឃើញក្នុងលក្ខន្តិកៈតុងទីនថាឱ្យកូនតុងទីនត្រូវបំពេញកាតព្វកិច្ចរវាងគ្នាទៅវិញទៅមកទេ។ ការលេងតុងទីនត្រូវធ្វើការដេញថ្លៃជាប្រចាំ ហើយការប្រាក់នៅពេលដេញម្តងៗអាស្រ័យទៅតាមស្ថានភាពនីមួយៗ។ ក្នុងន័យនេះ តុងទីនត្រូវបានដឹងថាជាការបង្វិលសាច់ប្រាក់ពីកូនតុងទីនជាច្រើនឱ្យទៅកូនតុងទីនណាមួយដែលដេញបាន តាមរយៈមេតុងទីនជាអ្នកប្រមូល។ យើងអាចសន្និដ្ឋានបានថាទំនាក់ទំនងរវាងកូនតុងទីនស្ថិតក្រោមកិច្ចសន្យាខ្ចីបរិភោគ ព្រោះកូនតុងទីនម្នាក់ៗសុទ្ធតែអាចក្លាយជាអ្នកឱ្យគេខ្ចីនៅពេលដែលខ្លួនមិនទាន់បានដេញតុងទីន ហើយខ្លួនចាំតែយកចំណេញការនៅពេលដេញម្តងៗ។ ពេលខ្លះក៏អាចក្លាយជាអ្នកខ្ចីគេវិញនៅពេលដែលខ្លួនបានដេញតុងទីន ដែលត្រូវបង់ប្រាក់ត្រលប់ទៅវិញជាប្រចាំផងដែរ។ យើងអាចនិយាយបានថា មេតុងទីនជាអ្នកដើរប្រមូលកម្ចីពី

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥៧៨។

កូនតុងទីនឯទៀត យកទៅឱ្យកូនតុងទីនម្នាក់ខ្ចី ហើយកូនតុងទីន ដែលខ្ចីនោះជាកូនតុងទីនដែលដេញតុងទីនបាន នោះឯង។ ករណីនេះដូចជាយកពី **ក, ខ, គ, ឃ** ទៅឱ្យ **ង** ខ្ចីតាមរយៈអ្នកកណ្ដាលមួយ ដែលជាមេតុងទីន។ យើងអាចទាញបានថា **ក, ខ, គ, ឃ** ជាម្ចាស់បំណុល **ង** ជាកូនបំណុល ដែលមានមេតុងទីនជាអ្នកធានាកម្ចីនោះចំពោះមុខសមាជិកតុងទីនទាំងអស់។

**កថាភាគទី២៖ កិច្ចសន្យាអាណត្តិ**

កិច្ចសន្យាតុងទីនក៏អាចជាប្រភេទមួយនៃកិច្ចសន្យាអាណត្តិ ដែលអាណត្តិទាយកប្រគល់សិទ្ធិអំណាចទៅអាណត្តិគាហកធ្វើការចាត់ចែង។ អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងហៅថាអាណត្តិទាយកប្រគល់សិទ្ធិអំណាចទៅឱ្យភាគីម្ខាងទៀតហៅថាអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការ ដើម្បីអាណត្តិទាយក។[28] ពាក្យកិច្ចការនៅក្នុងអាណត្តិរាប់បញ្ចូលគ្រប់កិច្ចការដូចជាការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិក្នុងការធ្វើបណ្ដឹងជាអាទិ៍។ ប៉ុន្តែការរក្សាទុកវត្ថុមិនរាប់បញ្ចូលទៅក្នុងកិច្ចការនៅក្នុងអាណត្តិទេ គឺស្ថិតនៅក្នុងកិច្ចការបញ្ញើ។[29] ចំពោះការទទួលបាននូវប្រាក់ និងវត្ថុផ្សេងៗទៀតតាមការចាត់ចែងកិច្ចការអាណត្តិ អ្នកចាត់ចែងកិច្ចការត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងទៀតនោះឱ្យទៅអ្នកប្រគល់សិទ្ធិ។ ម៉្យាងទៀត អ្នកចាត់ចែងកិច្ចការក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអ្នកប្រគល់សិទ្ធិផងដែរ។ ជាពិសេស សិទ្ធិដែលអ្នកចាត់ចែងកិច្ចការទទួលបាននៅក្នុងនាមរបស់ខ្លួន អ្នកចាត់ចែងត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអ្នកប្រគល់សិទ្ធិវិញនៅពេលដែលចប់អាណត្តិ។

យោងទៅតាមសៀវភៅសេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី បានពន្យល់ពីលក្ខខណ្ឌរបស់អាណត្តិថា អាណត្តិ គឺជាកិច្ចសន្យាមានការព្រមព្រៀង ដែលមិនតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ សម្រាប់ជាលក្ខខណ្ឌសុពលភាពនៃអាណត្តិនោះទេ មានន័យថាឱ្យតែមានឆន្ទៈត្រូវគ្នារវាងភាគីទាំងសងខាង នោះអាណត្តិនឹងត្រូវបានបង្កើតឡើង។ និយាយម្យ៉ាងទៀត នៅក្នុងករណីដែលអាណត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហកធ្វើកិច្ចការណាមួយ ហើយអាណត្តិគាហកឯកភាពទទួលធ្វើកិច្ចសន្យានោះ។[30]

អាណត្តិគាហកត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងទៀត ដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ អាណត្តិគាហកក៏ត្រូវប្រគល់ផលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ។ សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួន ដើម្បីអាណត្តិទាយកត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក។[31] ម្យ៉ាងវិញទៀត

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៣៧។

[29] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២*, (ភ្នំពេញ៖ មេសា ២០១៣), ទំព័រទី៥៨។

[30] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២*, (ភ្នំពេញ ៖ មេសា ២០១៣), ទំព័រទី៥៩។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៤២។

ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទារអាណត្តិគាហក។[32] ចំពោះគោលការណ៍នៃអាណត្តិដោយមិនយកម្រៃ[33] មានៈ

**១-** អាណត្តិអាចធ្វើដោយយកកម្រៃ ឬមិនយកកម្រៃបាន។ បើពុំបានបង្ហាញឆន្ទៈអំពីការធ្វើដោយយកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកម្រៃ។

**២-** បញ្ញត្តិនៃមាត្រា៦៤៤ (សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក) នៃក្រមនេះត្រូវយកមកអនុវត្តចំពោះកម្រៃ នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ។

ក្នុងការលេងតុងទីនវិញ ជាកិច្ចព្រមព្រៀងរវាងកូនតុងទីនច្រើននាក់ជាមួយនិងមេតុងទីនម្នាក់។ ការព្រមព្រៀងរវាងមេតុងទីន និងកូនតុងទីន ពិតជាស្ថិតនៅក្រោមទម្រង់កិច្ចសន្យាអាណត្តិ មេតុងទីនត្រូវបំពេញនូវកាតព្វកិច្ចចំពោះកូនតុងទីន ហើយកូនតុងទីនក៏មានកាតព្វកិច្ចក្នុងការបង់ប្រាក់ចំពោះមេតុងទីនវិញដែរ។ កូនតុងទីន ដែលនៅទីនេះយើងអាចហៅថាអាណត្តិទាយក បានប្រគល់សិទ្ធិអំណាចឱ្យមេតុងទីន ដែលជាអាណត្តិគាហកបំពេញកិច្ចការក្នុងការប្រមូលប្រាក់ទៅឱ្យអ្នក ដែលដេញបាន រហូតដល់តុងទីនត្រូវបានបញ្ចប់ដោយជោគជ័យ។ កូនតុងទីនម្នាក់ៗក៏ត្រូវមានកាតព្វកិច្ចបង់ប្រាក់ឱ្យមេតុងទីនឱ្យបានទាន់ពេលវេលានៅក្រោយពេលដេញម្តងៗ។ រីឯមេតុងទីនមានកាតព្វកិច្ចគ្រប់គ្រងដំណើរការទាំងមូលរបស់តុងទីន ក្នុងន័យនេះ មេតុងទីនត្រូវបំពេញកិច្ចការនេះរហូតដល់តុងទីនត្រូវបានបញ្ចប់ បើមិនដូច្នេះទេ កូនតុងទីនអាចចោទថាមេតុងទីនមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។

សិទ្ធិសំខាន់ៗមួយចំនួនបានផ្តល់ទៅឱ្យមេតុងទីន ដោយយោងទៅតាមការចំណាយពេលវេលា កម្លាំងកាយសោហ៊ុយផ្ទាល់ខ្លួនរបស់គាត់ ក្នុងការចាត់ចែងប្រមូលប្រាក់តុងទីន។ ជាការតបស្នងរបស់កូនតុងទីន នាឱកាសដំបូងមេតុងទីនមានសិទ្ធិទទួលបានទុកទាំងមូល ហើយបើមានទុនច្រើន មេតុងទីនក៏នឹងក្លាយទៅជាអ្នកដេញបានគ្រប់ៗពេល។ តុងទីននៅតំបន់ខ្លះ មេតុងទីនត្រូវទទួលបានទុននាលើកដំបូងនេះដោយមិនមានការបង់តុងទីនបន្ទាន់ពីនោះឡើយ ពោលកូនតុងទីនឱ្យទុននោះដាច់តែម្តង។ នៅតំបន់ខ្លះ នាពេលដេញម្តងៗ កូនតុងទីនឱ្យជាសគុណទៅមេតុងទីននៅពេលដែលខ្លួនដេញបាន ដើម្បីជាការបង្ហាញនូវអំណរគុណដល់មេតុងទីនដែលបានរៀបចំ និងប្រមូលប្រាក់តុងទីនឱ្យខ្លួនបានគ្រប់ចំនួន។ ជាថ្នូរមកវិញ ការដកហូតទុនជាលើកដំបូង ឬសគុណនេះជាកម្រៃទៅនឹងកាតព្វកិច្ចរបស់មេតុងទីនក្នុងឋានៈជាអាណត្តិគាហក។ តម្លៃនេះបានចងមេតុងទីនឱ្យទទួលខុសត្រូវក្នុងបញ្ហាមួយចំនួន ដែលបានជួបដូចក្នុងករណីធានារ៉ាប់រង ចេញសងជួសចំពោះកូនតុងទីន ដែលក្ស័យមិនព្រមចេញប្រាក់តាមការកំណត់របស់ខ្លួន។[34]

---

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៤៥។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៣៨។

[34] លី វ៉ុង, *តុងទីន* (២០១៨) , ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី១៦។

**កថាភាគទី៣៖ កិច្ចសន្យាលក់ទិញ**

ការលក់ទិញ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឱ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់។[35] ការលក់ទិញនេះ អ្នកលក់មិនត្រឹមតែត្រូវប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញឱ្យអ្នកទិញប៉ុណ្ណោះទេ តែថែមទាំងត្រូវមានករណីយកិច្ចធ្វើឱ្យអ្នកទិញបានធ្វើលទ្ធកម្មនូវសិទ្ធិលើកម្មសិទ្ធិចំពោះវត្ថុនោះផងដែរ។ ផ្ទុយទៅវិញ អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ បើមិនមែនជាប្រាក់ទេ វាជាការដូរ ដែលមិនស្ថិតនៅក្រោមកិច្ចសន្យាលក់ទិញនោះទេ។ កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជនជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។[36]

ជាធម្មតា ការលក់ទិញមានតែពីរភាគីគឺ ភាគីអ្នកលក់ និងភាគីអ្នកទិញ ប៉ុន្តែការលក់ទិញតុងទីននេះវិញមានបីភាគី ភាគីកូនតុងទីន (អ្នកលក់) ភាគីអ្នកទិញតុងទីន និងភាគីមេតុងទីន។ យើងអាចសន្និដ្ឋានបានថាការលក់ទិញតុងទីននេះមានបីភាគីតាមរយៈចំណែកច្បាប់តុងទីន ឆ្នាំ១៩៥៤ បានចែងថាកូនតុងទីនអាចលក់ហ៊ុនរបស់ខ្លួនមួយហ៊ុនឬទាំងអស់ឱ្យទៅកូនតុងទីនដទៃទៀត ឬឱ្យទៅជនដទៃបានគ្រប់ពេលវេលាទាំងអស់ តែត្រូវមានសេចក្តីព្រមព្រៀងយ៉ាងជាក់លាក់ពីមេតុងទីនផង។[37] យើងអាចពិនិត្យទៅលើពាក្យពេចន៍ដែលប្រើនៅក្នុងមាត្រានេះថា "តែត្រូវមានសេចក្តីព្រមព្រៀងយ៉ាងជាក់លាក់ពីមេតុងទីនផង" ត្រង់ចំណុចនេះ យើងសង្កេតឃើញថា ការព្រមព្រៀងរវាងអ្នកលក់ និងអ្នកទិញមិនអាចបង្កើតអានុភាពកិច្ចសន្យាលក់ទិញតុងទីនមួយបានទេ លុះត្រាតែមានការយល់ព្រមពីមេតុងទីនដែរ ព្រោះមេតុងទីនជាអ្នកសម្របសម្រួល ជាអ្នកកណ្តាលរវាងកូនតុងទីនទាំងអស់ និងជាអ្នកទទួលខុសត្រូវក្នុងការលេងតុងទីន ដូច្នេះចាំបាច់ណាស់ត្រូវមានការយល់ព្រមពីមេតុងទីន ទើបអាចលក់ទិញបាន។ កិច្ចសន្យាលក់ទិញក្នុងរឿងតុងទីននេះវិញ វាមានលក្ខណៈពិសេសជាងកិច្ចសន្យាលក់ទិញអចលនវត្ថុនានា ព្រោះនៅក្នុងតុងទីនត្រូវតែមានការចូលរួមបីភាគីក្នុងការបង្ហាញឆន្ទៈព្រមព្រៀងគ្នា ដែលមានមេតុងទីន កូនតុងទីន(អ្នកលក់) និងអ្នកទិញតុងទីន។

កិច្ចសន្យាលក់ទិញតុងទីនកើតមានឡើងនៅពេលដែលសមាជិកតុងទីនណាម្នាក់ចង់បោះបង់ ឬគ្មានលទ្ធភាពបង់បន្តតុងទីនរបស់ខ្លួន អាចធ្វើការលក់ទៅឱ្យបុគ្គលមួយណា ដែលចង់លេងបន្តហើយបុគ្គលនោះត្រូវបង់ថ្លៃឱ្យកូនតុងទីននោះតាមការព្រមព្រៀងរវាងភាគីទាំងពីរ។ នៅពេលអ្នកទិញបានបំពេញកាតព្វកិច្ច របស់ខ្លួនរួចហើយមក អ្នកទិញនឹងលទ្ធកម្មបន្តនូវសិទ្ធិរបស់កូនតុងទីនមុន មានន័យថាអ្នកទិញនឹងក្លាយទៅជាកូនតុងទីនជំនួសកូនតុងទីន

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥១៤។

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥១៦។

[37] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២០។

ចាស់ ដែលបានលក់តុងទីនរបស់ខ្លួន។ ការធ្វើកិច្ចសន្យាលក់ទិញនេះ ជាទូទៅគួរតែធ្វើឡើងជាលាយលក្ខណ៍អក្សរ រវាងភាគីទាំងពីរ ដើម្បីជាឯកសារសំអាង និងត្រូវមានបញ្ជាក់ពីការព្រមព្រៀងរបស់មេតុងទីនក្នុងនោះដែរ ដើម្បីឱ្យមេតុងទីនប្រកាសឱ្យកូនតុងទីនដទៃទៀតបានដឹងឮផង។

បន្ទាប់ពីបានស្វែងយល់អំពីទិដ្ឋភាពទូទៅរបស់តុងទីនហើយមក ជាបន្តទៅទៀត យើងនឹងស្វែងយល់អំពីការទទួលខុសត្រូវក្នុងតុងទីនវិញម្តង។

# ជំពូកទី២

# ការទទួលខុសត្រូវក្នុងតុងទីន

# ជំពូកទី២៖
# ការទទួលខុសត្រូវក្នុងតុងទីន

មតិមជ្ឈដ្ឋានសាធារណៈមួយចំនួនតែងតែលើកឡើងថា ការលេងតុងទីនជាអំពើខុសច្បាប់ ដោយគាត់យល់ថា មិនមានច្បាប់ណាមួយដែលបានបញ្ញត្តទុកអំពីការលេងតុងទីននេះឡើយ។ ដូចដែលយើងបានដឹងរួចមកហើយថា ប្រទេសកម្ពុជាបច្ចុប្បន្នពុំទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយ ដែលចែងអំពីច្បាប់តុងទីននៅឡើយទេ លើកលែងតែក្នុងសម័យសង្គមរាស្ត្រនិយម ដែលជាព្រះរាជក្រមលេខ ៨៦៥នស ចុះថ្ងៃទី២៧ ឧសភា ១៩៥៤ ស្ដីពីតុងទីន។ ចំណែកឯសម័យបច្ចុប្បន្ននេះវិញ មានតែយកបញ្ញត្តិផ្សេងៗនៅក្រម និងច្បាប់ដោយឡែក មកបកស្រាយអំពីកិច្ចគតិយុត្ត នៅក្នុងតុងទីន។

កាលណាប្រជាជន លោកបានយល់អំពីបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងតុងទីន លោកនឹងមានភាពងាយស្រួល ក៏ដូចជាលេងតុងទីនដោយមានភាពស្រណុកក្នុងចិត្ត ដោយហេតុថាច្បាប់បានការពារសិទ្ធិ និងកាតព្វកិច្ចរបស់គាត់នៅក្នុងការលេងតុងទីននោះផងដែរ។ កាលណាមានច្បាប់ចែងអំពីបញ្ហានេះ នឹងធ្វើឱ្យការលេងតុងទីនប្រកបទៅដោយភាពជឿទុកចិត្តគ្នាទៅវិញទៅមក និងប្រសិទ្ធភាពចំពោះតុងទីននីមួយៗ។ បើសិនជាមេតុងទីនរត់គេច ឬកូនតុងទីនមិនអនុវត្តកាតព្វកិច្ច ករណីនេះគេអាចចាត់ទុកជាការបំពានកិច្ចសន្យា ដូច្នេះម្ចាស់បំណុលអាចប្ដឹងសុំឱ្យភាគីដែលមិនអនុវត្តកាតព្វកិច្ច ឱ្យទៅអនុវត្តកាតព្វកិច្ចតាមប្រព័ន្ធតុលាការបាន បើភាគីនោះមិនព្រមអនុវត្តដោយស្ម័គ្រចិត្ត។ មួយវិញទៀត បើតុលាការរកឃើញថា ភាគីដែលរត់គេចពីការអនុវត្តកាតព្វកិច្ចពិតជាមានចេតនាទុច្ចរិតបោកប្រាស់សមាជិកតុងទីនមែន ភាគីនោះនឹងត្រូវផ្ដន្ទាទោសផ្នែកព្រហ្មទណ្ឌផង និងសំណងនៃការខូចខាតផង។

ដូច្នេះហើយបានជាមានចំណោទ ដែលសាធារណជនបានចោទថា តើមេតុងទីន និងកូនតុងទីនត្រូវទទួលខុសត្រូវយ៉ាងដូចម្ដេចខ្លះ ប្រសិនបើពួកគាត់មិនបានអនុវត្តកាតព្វកិច្ច?

តុងទីនជាករណីមួយ ដែលការទទួលខុសត្រូវតាមផ្លូវច្បាប់ អាចជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (ផ្នែកទី១) និងផ្នែករដ្ឋប្បវេណី (ផ្នែកទី២)។ ជាបន្តទៅទៀតនេះ សូមធ្វើការបកស្រាយនូវចំណុចទាំងពីរដូចតទៅ៖

## ផ្នែកទី១៖ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

ការមិនអនុវត្តកាតព្វកិច្ច ត្រូវបានចាត់ទុកថាជាកំហុសនៅក្នុងរឿងរដ្ឋប្បវេណី។ កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវ ជាពិសេសអំពីបរិមាណ គុណភាព ទីកន្លែង និងរយៈពេល។[38] ចំណែកឯការទទួលខុសត្រូវរដ្ឋប្បវេណីមានពីរប្រភេទធំៗ គឺការទទួលខុសត្រូវរដ្ឋប្បវេណីតាមកិច្ចសន្យា និងការទទួលខុសត្រូវរដ្ឋប្បវេណីក្រៅកិច្ចសន្យា។ ការមិនអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចសន្យា ជាហេតុនាំឱ្យមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន បែបនេះហៅថាការទទួលខុសត្រូវតាមកិច្ចសន្យា។

[38] ក្រឹត្យ-ច្បាប់ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ ៣៨ក្រ.ច, ២៨ តុលា ១៩៨៨, មាត្រា២៩។

ចំពោះការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី មិនមែនជារឿងចម្លែកទេក្នុងតុងទីន។ តុងទីនស្ថិតនៅក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា ដោយសារតែច្បាប់បាន ផ្តល់និយមន័យតុងទីនជាកិច្ចសន្យារួចទៅហើយ។ កាលណាតែទាក់ទងទៅនឹងកិច្ចសន្យា ច្បាស់ណាស់ទាក់ទងទៅនឹងរឿងរដ្ឋប្បវេណី ហេតុដូច្នេះក្នុងតុងទីនប្រាកដជាមានទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។

ជាបន្តទៅទៀត យើងខ្ញុំសូមលើកយកអំពីលក្ខខណ្ឌនៃការទទួលខុសត្រូវ (កថាភាគទី១) និងដំណោះស្រាយចំពោះការមិនអនុវត្តកាតព្វកិច្ច (កថាភាគទី២) មកធ្វើការបកស្រាយ។

**កថាភាគទី១៖ លក្ខខណ្ឌនៃការទទួលខុសត្រូវ**

នៅក្នុងរឿងក្តីរដ្ឋប្បវេណី អាចឱ្យចុងចម្លើយទទួលខុសត្រូវបាន ចាំបាច់ត្រូវមានលក្ខខណ្ឌចំនួនបី។ នៅក្នុងរឿងតុងទីនក៏ដូចគ្នាដែរ លក្ខខណ្ឌបីដែលអាចនាំឱ្យមេតុងទីន កូនតុងទីនទទួលខុសត្រូវគឺ ទី១៖ការមិនអនុវត្តកាតព្វកិច្ច ទី២៖ព្យសនកម្ម និងទី៣៖ ទំនាក់ទំនងរវាងអំពើ (ការមិនអនុវត្តកាតព្វកិច្ច) និងព្យសនកម្ម។

**១. ការមិនអនុវត្តកាតព្វកិច្ច ដែលចាត់ទុកជាកំហុស**

កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់ ហើយក្នុងករណីកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចក្រៅផ្លូវតុលាការ ឬតាមផ្លូវតុលាការ។[39] រាល់ការអនុវត្តនូវកិច្ចសន្យា មិនប្រាកដថាសុទ្ធតែជោគជ័យទាំងអស់នោះទេ មានន័យថា វាតែងតែអាចមានភាគីណាម្ខាងមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហេតុនេះហើយបានជាច្បាប់ត្រូវបានបញ្ញត្តទុកជាមុនលើបញ្ហានេះ ដើម្បីយកច្បាប់ជាគោលក្នុងការដោះស្រាយវិវាទ។ ការមិនអនុវត្តកាតព្វកិច្ចដែលផ្តល់និយមន័យដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា។[40] តាមរយៈនិយមន័យនេះ ការមិនអនុវត្តកាតព្វកិច្ច គឺជាការមិនអនុវត្តករណីយកិច្ចកើតឡើងពីកិច្ចសន្យា ហេតុដូច្នេះដើម្បីយល់ថាតើករណីយកិច្ចណាមួយជាការមិនអនុវត្តកាតព្វកិច្ច មានភាពចាំបាច់ត្រូវពិចារណាថាតើកូនបំណុលត្រូវមានករណីយកិច្ចណា ដែលកើតឡើងពីកិច្ចសន្យា ដែលភាគីបានសន្យាជាមួយគ្នាទុកជាមុន។ មានន័យថា បើភាគីបានព្រមព្រៀងគ្នាអនុវត្តកាតព្វកិច្ចរួចហើយ ប៉ុន្តែនៅពេលដែលត្រូវអនុវត្តជាក់ស្តែងបែរជាមានភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងន័យនេះភាគីម្ខាងនោះហើយ ដែលមិនអនុវត្តនូវករណីយកិច្ចកើតចេញពីកិច្ចសន្យារបស់ខ្លួន ដែលបានសន្យាជាមួយភាគីម្ខាងទៀត។

មិនអនុវត្តកាតព្វកិច្ចអាចស្ថិតនៅក្រោមរូបភាពច្រើន ដូចជាកូនបំណុលមិនអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្តដោយសារការយឺតយ៉ាវក្នុងការអនុវត្ត ឬដោយសារអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ឬមកពីកូនបំណុល

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, កថាខណ្ឌទី១ មាត្រា៣៨៤ និងមាត្រា៣៨៥។

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, កថាខណ្ឌទី១ មាត្រា៣៨៩។

មិនបានអនុវត្តឱ្យពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច ឬករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។[41] រីឯកំហុស មានន័យថាជាការមិនគោរពករណីយកិច្ចត្រូវប្រុងប្រយ័ត្ន ដែលត្រូវបានតម្រូវឱ្យមានចំពោះកូនបំណុល។ កំហុសអាចនឹងកើតមានឡើង នៅពេលដែលកាតព្វកិច្ចមិនបានអនុវត្តទាំង ស្រុង ឬពាក់កណ្ដាល ឬកាតព្វកិច្ចដែលបានធ្វើមិនសមស្របទៅនឹងគុណភាពនៃកាតព្វកិច្ច ដែលទាមទារក្នុងកិច្ចសន្យា។

**១.១. ការអនុវត្តកាតព្វកិច្ចមិនទាន់ពេលកំណត់**

ជាទូទៅ គូភាគីសន្យាថានឹងអនុវត្តកាតព្វកិច្ចនៅពេលកំណត់ណាមួយ។ ប្រសិនបើកាលកំណត់សម្រាប់អនុវត្តកាតព្វកិច្ចបានមកដល់ហើយ គូភាគីត្រូវតែអនុវត្តកាតព្វកិច្ចនោះ។ ប៉ុន្តែមានករណីខ្លះ នៅពេលដល់កាលកំណត់អនុវត្តកាតព្វកិច្ចហើយ ភាគីម្ខាងទៀតមិនបានអនុវត្តឡើយ។

កូនបំណុលត្រូវបានចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ចនៅពេលដែលបានកំណត់ដូចខាងក្រោម[42]៖

ក. ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលដល់កាលកំណត់នោះ។

ខ. ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះបានដឹងថា ដល់ពេលកំណត់ហើយ។

គ. ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត។

ចំណែកឯក្នុងរឿងតុងទីនវិញ ភាគីត្រូវអនុវត្តកាតព្វកិច្ចរៀងៗខ្លួន ប៉ុន្តែការអនុវត្តកាតព្វកិច្ចនៅពេលណាមួយនោះ ភាគីមិនបានកំណត់ឱ្យច្បាស់លាស់ថានៅថ្ងៃណាមួយឱ្យប្រាកដទេ។ មេតុងទីន និងកូនតុងទីនគ្រាន់តែដឹងថាខ្លួនត្រូវអនុវត្តកាតព្វកិច្ចបន្ទាប់ពីការដេញមួយលើកៗ។ ចំពោះមេតុងទីន បន្ទាប់ពីដេញតុងទីនហើយ ត្រូវចាប់ផ្ដើមប្រមូលប្រាក់ពីកូនតុងទីនឯទៀតឱ្យគ្រប់ចំនួនកាន់តែលឿន កាន់តែល្អ ដើម្បីប្រគល់ទៅឱ្យអ្នកដេញបាន។ ចំណែកឯកូនតុងទីនវិញ ត្រូវអនុវត្តកាតព្វកិច្ចបង់ប្រាក់ទៅឱ្យមេតុងទីនបន្ទាប់ពីដេញមួយលើកៗដូចគ្នា។ ជាក់ស្ដែង មេតុងទីន ឬកូនតុងទីនអនុវត្តកាតព្វកិច្ចយឺតយ៉ាវ នៅពេលដល់ពេលដេញលើកបន្ទាប់ មេតុងទីន ឬកូនតុងទីននោះនៅតែមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនទាន់ពេលវេលា ព្រោះក្នុងការលេងតុងទីន មិនសូវជាឃើញភាគីកំណត់ថាត្រូវអនុវត្តកាតព្វកិច្ចបង់ប្រាក់ ឬប្រគល់ប្រាក់ក្នុងរយៈពេលប៉ុន្មានថ្ងៃឱ្យហើយនោះទេ។ ប្រសិនបើដល់ពេលដេញលើកបន្ទាប់ហើយ នៅតែមិនអនុវត្តកាតព្វកិច្ចទៀត ភាគីនឹងដឹងថាបានហួសពេលកំណត់ហើយ។ ដូច្នេះ កូនតុងទីន ឬមេតុងទីនត្រូវបានគេសន្មតថាមានភាពយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនហើយ។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, កថាខណ្ឌទី២ មាត្រា៣៨៩។

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩១។

### ១.២. អលទ្ធភាពក្នុងការអនុវត្ត

ករណីនេះមានភាពខុសគ្នាពីការអនុវត្តកាតព្វកិច្ចមិនទាន់ពេលកំណត់ អលទ្ធភាពក្នុងការអនុវត្ត គឺកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចតែម្តង ដែលអាចមកពីមូលហេតុនៃស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់ខ្លួនជាដើម។ នៅពេលនោះហើយ កូនបំណុលនឹងក្លាយទៅជាអលទ្ធភាព ហើយនឹងធ្លាក់ចូលទៅក្នុងស្ថានភាពនៃការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព។ អលទ្ធភាពនេះត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះត្រូវបានវាយតម្លៃថា មិនអាចធ្វើកើត តាមស្ថានភាពសង្គម ឬសេដ្ឋកិច្ច។ ប្រសិនបើការណ៍ ដែលមិនអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ។[43]

ងាកមកកាន់តុងទីនវិញ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចរបស់មេតុងទីន និងកូនតុងទីននឹងត្រូវចាត់ទុកជាកំហុស។ មេតុងទីនដែលមិនអាចប្រមូលប្រាក់ឱ្យទៅកូនតុងទីន ដែលដេញតុងទីនបាន មេតុងទីននោះនឹងក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច។ ការណ៍ដែលមិនអាចប្រមូលបាននេះអាចកើតចេញពីកូនតុងទីនមិនមានប្រាក់បង់ឱ្យមេតុងទីនបានគ្រប់ចំនួន ឬក៏ករណីខ្លះមេតុងទីនមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានតែម្តងដោយសារតែស្ថានភាពរបស់ខ្លួនដូចជា មិនមានប្រាក់គ្រប់គ្រាន់សម្រាប់បង់ជំនួសកូនតុងទីនជាអាទិ៍។ រីឯកូនតុងទីនវិញនឹងក្លាយទៅជាអលទ្ធភាពដែរ នៅពេលដែលខ្លួនមិនបានបង់ប្រាក់ទៅឱ្យមេតុងទីន ដោយសារតែមូលហេតុនៃស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់ខ្លួនជាដើម។

### ១.៣. អនុវត្តកាតព្វកិច្ចមិនបានពេញលេញ

ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់តាវកាលិកមិនបានពេញលេញ ឬករណីដែលអនុវត្តបានតែមួយផ្នែកនៃកាតព្វកិច្ច ឬករណីផ្សេងទៀត ដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។[44]ក្នុងករណីនេះ កូនបំណុលបានអនុវត្តកាតព្វកិច្ចបានខ្លះៗហើយ ប៉ុន្តែខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីអនុវត្តកាតព្វកិច្ចឱ្យបានពេញលេញតែប៉ុណ្ណោះ។ ករណីនេះ ក៏ច្បាប់ចាត់ទុកថាកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលបង្កើតជាកំហុសបណ្តាលឱ្យមានការប៉ះពាល់ដល់ប្រយោជន៍របស់ម្ចាស់បំណុល។ ឧទាហរណ៍ៈ តុងទីនមួយក្បាលតម្លៃ២០០$ ហើយកូនតុងទីនបានដេញតុងទីនរួចត្រូវទទួលបានប្រាក់សរុប៥,៣៥០$ ក៏ប៉ុន្តែមេតុងទីនប្រមូលប្រាក់ឱ្យបានត្រឹមតែ៥,០០០$ ប៉ុណ្ណោះ។ នេះហើយជាករណី ដែលមេ

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩២។

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩៣។

តុងទីនអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ដែលត្រូវប្រគល់ប្រាក់៥,៣៥០$ ផ្ទុយទៅវិញខ្លួនប្រមូលប្រាក់បានតែ ៥,០០០$ ប៉ុណ្ណោះ។

**១.៤. ករណីផ្សេងទៀត ដែលមិនអនុវត្តទៅតាមលក្ខន្តិកៈតុងទីន**

ក្នុងករណីដែលមានការបំពានករណីយកិច្ចផ្សេងទៀត ដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ជាការមិនអនុវត្តកាតព្វកិច្ចដែរ។ ករណីនៃការបំពាននេះមិនមានបញ្ញត្តក្នុងក្រមទេ ដោយហេតុថា ការមិនអនុវត្តកាតព្វកិច្ចអាចកើតមានឡើងក្នុងទម្រង់ផ្សេងៗទៀតជាច្រើន ដែលនីតិករមិនអាចកំណត់ទុកជាមុនឱ្យបានទាំងអស់ឡើយ ដូច្នេះមានតែបញ្ញត្តករណីផ្សេងៗ នៃការមិនអនុវត្តកាតព្វកិច្ច ហើយការមិនអនុវត្តកាតព្វកិច្ច ឬការបំពាននេះធ្វើឱ្យខូចប្រយោជន៍របស់ភាគីម្ខាងទៀត។

ងាកទៅកាន់រឿងតុងទីនរបស់យើងវិញ មេតុងទីន និងកូនតុងទីនប្រាកដជាបានសន្យាទុកជាមុនថានឹងត្រូវលេងតុងទីនដោយរបៀបណា ដូច្នេះមេតុងទីន និងកូនតុងទីនត្រូវអនុវត្តទៅតាមកិច្ចសន្យានោះ។ ដូច្នេះយើងក៏មិនអាចកំណត់ថាតើមេតុងទីន និងកូនតុងទីននឹងកំណត់លក្ខន្តិកៈអ្វីបន្ថែមទៀតនោះទេ។ ក្នុងន័យនេះ អាចមានតុងទីនខ្លះ មេតុងទីន និងកូនតុងទីនព្រមព្រៀងគ្នា មិនឱ្យកូនតុងទីនដែលលេងច្រើនក្បាលដេញផ្ទួនៗគ្នានោះទេ ពោលអាចទុកចន្លោះពេលមួយសម្រាប់ដេញមួយក្បាលទៀត ឬករណីខ្លះត្រូវទុកមួយ ឬពីរក្បាលរហូតដល់តុងទីនជិតបញ្ចប់។ គេអនុវត្តបែបនេះ ព្រោះមានការព្រួយបារម្ភថា ប្រសិនបើឱ្យដេញផ្ទួនៗ កូនតុងទីននោះអាចនឹងដេញហើយរត់ចោលស្រុកបាត់ ហើយសមាជិកតុងទីនឯទៀតពិបាកក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច។ បើគេកំណត់បែបនេះ ទោះបីជាកូនតុងទីននោះរត់ចោលស្រុកក៏ដោយ ក៏នៅសល់តុងទីនរបស់កូនតុងទីននោះសម្រាប់ដេញយកមកចាត់ចែងក្នុងតុងទីនបន្តទៀតដែរ។

**២.ព្យសនកម្ម**

ការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង បង្កើតបានជាកំហុស ហើយកំហុសនោះនឹងបង្កជាព្យសកម្មដល់ភាគីម្ខាងទៀត។ ព្យសនកម្ម គឺជាការខូចខាតខាងសម្ភារៈ ដូចជាការបាត់បង់នូវទ្រព្យសម្បត្តិ នូវស្ថានភាពវិជ្ជាជីវៈ ឬការខូចខាតខាងរាងកាយ ឬការខូចខាតខាងផ្លូវចិត្ត ដូចជាការប៉ះពាល់ដល់ការរាប់អាន ដល់ការគោរពនូវជីវភាពឯកជន ដែលបុគ្គលម្នាក់បានរងបណ្តាលមកពីអំពើរបស់អ្នកដទៃ។ [45] ព្យសនកម្មអាចស្តែងឡើងក្រោមរូបភាពជាការបាត់បង់ទ្រព្យសកម្មភាពណាមួយនៃបេតិកភ័ណ្ឌ ឬជាការខកខានមិនបានចំណេញ។ មិនតែប៉ុណ្ណោះ ព្យសនកម្មនេះក៏កើតមានទៅលើផ្លូវចិត្ត និងរាងកាយផងដែរ។ ការទទួលរងនូវការខូចខាតនេះកើតឡើងពីកំហុសរបស់ភាគីម្ខាងទៀត ដែលមិនបាន

[45] ញឹក វុទ្ធី, "នីតិកាតព្វកិច្ច", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, ភាគទី២,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ទំព័រទី១៩។

អនុវត្តកាតព្វកិច្ចត្រឹមត្រូវរបស់ខ្លួនជាដើម។ ព្យសនកម្មនេះត្រូវតែជាលទ្ធផលផ្ទាល់នៃកំហុស បានន័យថាកំហុសជាមូលហេតុដោយផ្ទាល់នៃព្យសនកម្ម បើគ្មានកំហុសក៏គ្មានព្យសនកម្មដែរ។

ចំណែកឯក្នុងរឿងតុងទីនវិញ មេតុងទីនមានកាតព្វកិច្ចធានាឱ្យតុងទីនមានដំណើរការល្អ មានន័យថាប្រសិនបើមានភាពមិនប្រក្រតីកើតឡើងក្នុងតុងទីនដូចជាការមិនបង់ប្រាក់ ឬបង់ប្រាក់មិនទាន់ពេលវេលារបស់កូនតុងទីន នោះមេតុងទីនមានកាតព្វកិច្ចបង់ជំនួស។ ការមិនអនុវត្តកាតព្វកិច្ចរបស់មេតុងទីននឹងបណ្តាលឱ្យកើតមានព្យសនកម្មធ្ងន់ធ្ងរ ដោយសារតែមេតុងទីនប្រៀបបីដូចជាមេគេ ដូច្នេះហើយបើមេមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន វានឹងនាំឱ្យកូនៗមានភាពច្របូកច្របល់ទៅតាមហ្នឹងដែរ។ ជាលទ្ធផលធ្វើឱ្យខូចប្រយោជន៍របស់កូនតុងទីន ដែលរំពឹងថានឹងទទួលបានប្រាក់នៅពេលដែលខ្លួនដេញបាន តែបែរជាមិនទទួលបានប្រាក់ទៅវិញ។

រីឯកូនតុងទីនវិញ កាតព្វកិច្ចចម្បងរបស់ខ្លួនគឺត្រូវបង់ប្រាក់ទៅឱ្យមេតុងទីនឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាកំណត់។ ដូច្នេះហើយកូនតុងទីនណាដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន មេតុងទីននឹងរងនូវព្យសនកម្មជាងគេ ព្រោះមេតុងទីនត្រូវរ៉ាប់រងការបង់ជំនួសកូនតុងទីននោះ។ បើមេតុងទីនមិនមានលទ្ធភាពបង់ជំនួសទេ វានឹងធ្វើឱ្យប៉ះពាល់ទៅដល់កូនតុងទីនឯទៀត ដែលលេងជាមួយគ្នាផងដែរ។

កាលណាតែភាគីមេតុងទីន ឬភាគីកូនតុងទីនមិនអនុវត្តកាតព្វកិច្ចខាងលើនេះ វានឹងកើតមានឡើងនូវព្យសនកម្មដែលនឹងប៉ះពាល់ទៅដល់សមាជិកតុងទីន ឬជនរងគ្រោះក្នុងរូបភាពជាការខូចខាតខាងសម្ភារៈ និងផ្លូវចិត្ត ដោយមិនមានការខូចខាតខាងផ្លូវកាយនោះទេ។ បើកូនតុងទីនមិនអនុវត្តកាតព្វកិច្ច មេតុងទីនអាចនឹងអនុវត្តជំនួសបាន ប៉ុន្តែប្រសិនបើមេតុងទីនមិនអនុវត្តកាព្វកិច្ច វាជារឿងមួយដែលកាន់តែស្មុគស្មាញក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលតម្រូវឱ្យមានការស្ម័គ្រចិត្តក្នុងការអនុវត្ត ផ្ទុយទៅវិញបើមិនអាចអនុវត្តដោយស្ម័គ្រចិត្តបាន ចាំបាច់ត្រូវស្នើសុំឱ្យរដ្ឋជួយអន្តរាគមន៍ តាមរយៈការដាក់ពាក្យប្តឹងទៅកាន់តុលាការ។

**៣. ទំនាក់ទំនងរវាងអំពើ (ការមិនអនុវត្តកាតព្វកិច្ច) និងព្យសនកម្ម**

ដើម្បីឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងដំណើររឿងមួយ ជនរងគ្រោះ ត្រូវបង្ហាញឱ្យឃើញថារវាងអំពើនាំឱ្យមានការខូចខាតហើយនឹងព្យសនកម្ម ដែលបានទទួលមានទំនាក់ទំនងពីហេតុទៅផល គឺត្រូវតែពិតប្រាកដ និងដោយផ្ទាល់ ហើយដោយថាបើគ្មានអំពើនោះទេ ការខូចខាតក៏មិនអាចកើតមានបានដែរ។[46] ព្យសនកម្មនឹងចាប់បង្ខំឱ្យជនប្រព្រឹត្តត្រូវទទួលខុសត្រូវបាន លុះត្រាតែវាជាលទ្ធផលដោយផ្ទាល់ និងដោយភ្លាមៗនៃកំហុស ឬការមិនអនុវត្តកាតព្វកិច្ចនោះ។[47] ព្យសនកម្មដែលត្រូវជួសជុល គឺត្រូវបានបង្កឡើងដោយកំហុសចារីតែម្តង មានន័យថាព្យសកម្ម

[46] ញឹក វុទ្ធី, "នីតិកាតព្វកិច្ច", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, ភាគទី២,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ទំព័រទី២២។
[47] លី រ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី២៦។

ដែលបានបង្កឡើងត្រូវបន្តភ្លាមៗ ហើយផ្ទាល់ពីអំពើនាំឱ្យមានការខូចខាតនោះ។[48] ហេតុនេះបើមានហេតុការណ៍ណាមួយចូលមកជ្រៀតទៅក្នុងអង្គហេតុនោះ នាំឱ្យហេតុការណ៍នោះ មិនមានចំណងហេតុផលមានលក្ខណៈមិនផ្ទាល់ដែលធ្វើឱ្យរួចផុតពីការទទួលខុសត្រូវ។

បែរមកកាន់តុងទីនវិញ ការមិនអនុវត្តកាតព្វកិច្ចរបស់មេតុងទីន អាចជាការមិនបង្វែរសាច់ប្រាក់ដែលកូនតុងទីនដេញបានប្រគល់ទៅឱ្យកូនតុងទីននោះ។ ចំណែកឯកូនតុងទីនអាចស្តែងចេញតាមរយៈការមិនបង់ប្រាក់តុងទីនទៅតាមសមាមាត្រនៃការដេញនៅលើកនីមួយៗ។ ការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា វានឹងផ្តល់ព្យសនកម្មដោយផ្ទាល់ទៅដល់ជនរងគ្រោះ ដោយហេតុថាជនរងគ្រោះជាអ្នកចូលរួមក្នុងតុងទីនដែរ បើមានការមិនអនុវត្តកាតព្វកិច្ច វានឹងធ្វើឱ្យប៉ះពាល់ដល់អ្នកចូលរួមទាំងនោះ។ អ្នកដែលរងគ្រោះជាងគេនោះ គឺអ្នកដែលមិនទាន់ដេញថ្លៃបាន (នៅរស់)។

គ្រប់លក្ខខណ្ឌទាំងបីខាងលើ ត្រូវបានបំពេញ ទើបនាំឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។ ជាពិសេសដើម្បីទាមទារតាមផ្លូវតុលាការទទួលបានភាពជោគជ័យ ភាគីត្រូវមានភស្តុតាង ដើម្បីអះអាង ឬការពារនូវការលើកឡើងនោះ។ ភស្តុតាងនោះទៀតសោត ត្រូវតែជាភស្តុតាងដែលមានភាពច្បាស់លាស់ ដើម្បីបញ្ជាក់ពីអត្ថិភាពដ៏ពិតប្រាកដនៃការមិនអនុវត្តកាតព្វកិច្ច និងព្យសនកម្ម។ [49] ការធ្វើបែបនេះដើម្បីធានាថាតុលាការនឹងជឿជាក់ទៅលើភស្តុតាងដែលយើងដាក់ជូនលោកពិនិត្យ។ ភស្តុតាងដែលមានភាពច្បាស់លាស់នេះ សំដៅទៅលើភស្តុតាងដែលមិនមានវិមតិសង្ស័យនោះឡើយ ពោលជា ភស្តុតាងដែលអាចជឿជាក់បាន និងអាចយកទៅធ្វើជាមូលដ្ឋានក្នុងការវិនិច្ឆ័យរកខុសត្រូវបាន។ កាលណាតែភស្តុតាងនោះមានវិមតិសង្ស័យនឹងត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។[50]

បន្ទាប់ពីបានជ្រាបអំពីលក្ខខណ្ឌនៃការទទួលខុសត្រូវរដ្ឋប្បវេណីរួចហើយ ជាបន្តទៅទៀត សូមធ្វើការបកស្រាយអំពីវិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច ដែលជាដំណោះស្រាយមួយសម្រាប់អ្នកលេងតុងទីន។

### កថាភាគទី២៖ ដំណោះស្រាយចំពោះការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ចអាចនឹងកើតមានឡើងនៅក្នុងកិច្ចសន្យា ដែលភាគីបានព្រមព្រៀងគ្នា។ ការមិនអនុវត្តកាតព្វកិច្ចច្បាស់ណាស់នឹងធ្វើឱ្យប៉ះពាល់ ឬមានព្យសនកម្មទៅលើភាគីម្ខាងទៀតនៃកិច្ចសន្យា។ កាលណាមានភាពមិនប្រក្រតីកើតមាននៅក្នុងតុងទីន ដោយសារការមិនអនុវត្តកាតព្វកិច្ច ច្បាប់មានវិធីសង្គ្រោះចំនួនបី គឺការអនុវត្តដោយបង្ខំ (១) សំណងនៃការខូចខាត (២) និងការរំលាយតុងទីនមុនកំណត់ (៣) ។

#### ១. ការអនុវត្តកាតព្វកិច្ចដោយបង្ខំ

ម្ចាស់បំណុលមានសិទ្ធិទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។ ការទាមទារឱ្យអនុវត្តកាតព្វកិច្ចនេះអាចធ្វើឡើងក្រៅផ្លូវតុលាការ មុននឹងឈានដល់ការទាមទារឱ្យអនុវត្តតាមផ្លូវតុលាការ។ បើគូភាគីព្រមព្រៀងគ្នាក្នុងការអនុវត្ត

[48] អ៊ុក វណ្ណារ័ត្ន, *នីតិកាតព្វកិច្ច* (ភ្នំពេញ៖ អ៊ឹម ឌី អេ, ២០១៧), ទំព័រទី៣៤។

[49] លី រ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី២៧។

[50] កថាខណ្ឌទី៥ មាត្រា៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

កាតព្វកិច្ចដោយស្ម័គ្រចិត្ត ការអនុវត្តដោយបង្ខំមិនមែនជាមធ្យោបាយមួយចាំបាច់ត្រូវធ្វើទេ ព្រោះនីតិវិធីនេះត្រូវចំណាយពេល និងថវិកាសម្រាប់អនុវត្ត។

ប្រសិនបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត នោះម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ទៅតាមនីតិវិធីអនុវត្តដោយបង្ខំ។ ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ គឺជាការចាប់បង្ខំកូនបំណុលឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ខំតាមនីតិវិធីតុលាការ។ ម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលរបស់ខ្លួនអនុវត្តកាតព្វកិច្ចដោយតម្រូវឱ្យមាននូវសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ ព្រមទាំងលិខិតអនុវត្ត និងរូបមន្តអនុវត្ត ដើម្បីសម្រេចនូវការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំនេះអាចស្ដែងឡើងតាមរយៈការរឹបអូសនូវអចលនទ្រព្យរបស់កូនបំណុល ដើម្បីយកទៅលក់សម្រាប់ទូទាត់ជាមួយបំណុលរបស់ខ្លួនជាដើម។

ឯក្នុងតុងទីនវិញ សមាជិកតុងទីន ដែលបានរងគ្រោះអាចដាក់ពាក្យប្ដឹងទៅកាន់តុលាការសុំឱ្យចេញសាលក្រម ឬសាលដីកាស្ថាពរ ដើម្បីឱ្យមេតុងទីន ឬកូនតុងទីន ដែលមិនព្រមអនុវត្តទៅតាមលក្ខន្តិកៈតុងទីន ឱ្យអនុវត្តដោយបង្ខំបាន។ ការអនុវត្តដោយបង្ខំនេះអាច ឬមិនអាចនឹងជោគជ័យទាំងស្រុងនោះដែរ មិនអាចនោះគឺដោយសារតែមេតុងទីន ដែលមិនព្រមប្រគល់ប្រាក់ឱ្យកូនតុងទីន ឬកូនតុងទីន ដែលមិនព្រមបង់ប្រាក់ឱ្យមេតុងទីនមួយចំនួន អាចនឹងមិនមានលទ្ធភាពក្នុងការអនុវត្តទៅបាន ដោយសារតែទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តមិនគ្រប់គ្រាន់តាមការទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។

ការអនុវត្តកាតព្វកិច្ចដោយបង្ខំនេះអាចនឹងត្រូវចំណាយពេលយូរគួរសមដែរ បើយើងមើលទៅការអនុវត្តជាក់ស្ដែង ព្រោះទម្រាំតែបានចេញអនុវត្តដោយបង្ខំ នីតិវិធីត្រូវដើរតាំងពីការដាក់ពាក្យបណ្ដឹង រហូតដល់ចេញសាលក្រម ឬសាលដីកាស្ថាពរ ទើបម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តដោយបង្ខំ។ បន្ទាប់ពីនោះតុលាការចេញរូបមន្តអនុវត្ត ទើបអាចអនុវត្តដោយបង្ខំបាន។

**២. សំណងនៃការខូចខាត**

ភាគីទាំងពីរត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចសន្យា ប្រសិនបើមានភាគីណាមួយមិនអនុវត្តកាតព្វកិច្ច នោះច្បាប់ចាត់ទុកថា ភាគីនោះបានប្រព្រឹត្តកំហុសដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ការមិនអនុវត្តកាតព្វកិច្ច និងកំហុស គឺជាលក្ខខណ្ឌចាំបាច់ ក្នុងការទាមទារសំណងការខូចខាត។ ពាក្យថា កំហុស គឺមានន័យថា ការមិនគោរពករណីយកិច្ចរបស់ភាគីណាមួយ។ សំណងនៃការខូចខាត គឺជាការខូចខាតដែលបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា។ [51] ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឱ្យសងការខូចខាត ជំនួសឱ្យការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬជាមួយការទាមទារឱ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាព

[51] ក្រុមការងារនៃគម្រោងបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១*, (ភ្នំពេញ៖ មេសា ២០១៣), ទំព័រទី១៦៣។

ផ្ទុយគ្នា។[52] ការអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាពផ្ទុយគ្នានេះមានន័យថា កូនបំណុលត្រូវអនុវត្តកាតព្វកិច្ច ដែលមានកម្មវត្ថុផ្សេងពីកម្មវត្ថុដែលបានចែងក្នុងកិច្ចសន្យា ហើយក្នុងទំហំ ឬចំនួនប្រហាក់ប្រហែល ឬក៏ស្មើទៅនឹងកម្មវត្ថុចាស់។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលរំលាយកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចបានទេ ប៉ុន្តែគ្រាន់តែអាចទាមទារសំណងការខូចខាតជំនួសបានប៉ុណ្ណោះ។

ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។[53] ម្ចាស់បំណុលអាចទាមទារនូវសំណងការខូចខាតដូចជាការបាត់បង់ផលប្រយោជន៍ ចំណាយផ្សេងៗ ដែលគ្មានប្រយោជន៍ដោយការមិនអនុវត្តកាតព្វកិច្ច និងសំណងការខូចខាតខាងផ្លូវចិត្ត។[54]

### ២.១. ការទាមទារសំណងការខូចខាតនាពេលបច្ចុប្បន្ន

ដើមចោទអះអាងអំពីសិទ្ធិទាមទារឱ្យសងការខូចខាត ដែលបានកើតឡើងពីការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយមកដល់បច្ចុប្បន្ននេះ។ កូនតុងទីនម្នាក់ៗមានកាតព្វកិច្ចបង់ប្រាក់ទៅមេតុងទីនឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា ប៉ុន្តែបើខ្លួនមិនបានធ្វើបែបនេះទេ ច្បាប់ចាត់ទុកថាកូនតុងទីននោះមិនអនុវត្តកាតព្វកិច្ច ឬក៏អាចហៅម្យ៉ាងទៀតថា កូនតុងទីននោះបានភៀសខ្លួន។ ការភៀសខ្លួននេះ នឹងធ្វើឱ្យកូនតុងទីននោះ បាត់បង់នូវភាពជាសមាជិកនៃតុងទីន និងថែមទាំងគ្មានសិទ្ធិក្នុងការទាមទារនូវប្រាក់ដែលខ្លួនបានបង់រួចហើយនោះមកវិញបានឡើយ។ សិទ្ធិក្នុងការដេញនេះ និងដកទុននេះ នឹងត្រូវបានផ្ទេរទៅឱ្យអ្នកជំនួស ដែលត្រូវចូលមកទទួលហ៊ុនទាំងអស់របស់អ្នកដែលបានភៀសខ្លួននោះដោយពេញច្បាប់។[55]

ក្នុងករណីដែលអ្នកភៀសខ្លួននោះបានដេញរួចហើយ(ងាប់) នោះខ្លួនត្រូវសងទៅអ្នកដែលជំនួសខ្លួន នូវប្រាក់ដែលគេបានចេញជំនួសខ្លួន ក្នុងអំឡុងពេលភៀសខ្លួន។ អ្នកជំនួសក៏អាចទាមទារសោហ៊ុយជំងឺចិត្តពីអ្នកដែលបានភៀសខ្លួននោះផងដែរ។ មួយវិញទៀត បើអ្នកភៀសខ្លួននោះ មិនមានលទ្ធភាពក្នុងការសងប្រាក់នោះទេ បើខ្លួនជាអ្នកជំនួយលក់ដូរជាអាទិ៍ នោះខ្លួនត្រូវបិទទ្វារហាងលក់ឡាយឡុងដើម្បីសងអ្នកជំនួសនោះឱ្យបានគ្រប់ចំនួន។ ឧទាហរណ៍៖ តាំងពីកូនតុងទីនមិនអនុវត្តកាតព្វកិច្ចហូតមកដល់ពេលនេះ មានទឹកប្រាក់សរុប ២,៥០០ដុល្លារអាមេរិក។ ដូច្នេះ អ្នកបង់ជំនួសអាចប្តឹងទាមទារសំណងជាទឹកប្រាក់សរុប២,៥០០ដុល្លារអាមេរិក និងសំណងការខូចខាតផ្លូវចិត្តបន្ថែមពីលើនោះទៀត។

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩៧។

[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, វាក្យខណ្ឌទី១ កថាខណ្ឌទី១ មាត្រា៣៩៨។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤០០។

[55] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, វាក្យខណ្ឌទី១ មាត្រា១៩។

### ២.២. ការទាមទារសំណងការខូចខាតនាពេលអនាគត

ការទាមទារសំណងនេះ ដើមចោទអះអាងអំពីសិទ្ធិទាមទារឱ្យសងប្រាក់ ដែលចុងចម្លើយត្រូវអនុវត្តបន្តនាពេលអនាគត។ បណ្តឹងទាមទារការផ្តល់តាវកាលិកនៅពេលអនាគតអាចធ្វើឡើងបាន លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុន។[56] ការទាមទារបែបនេះធ្វើបានក្នុងករណីថា កូនបំណុលត្រូវមានកាតព្វកិច្ចបង់តុងទីនបន្តទៀត ព្រោះតុងទីនមិនទាន់ចង់ទេ ប៉ុន្តែដោយសារតែម្ចាស់បំណុលមិនមានសង្ឃឹមថា កូនបំណុលនឹងអនុវត្តកាតព្វកិច្ចក្នុងនាមជាមេតុងទីន ឬកូនតុងទីនបន្តទៅទៀត ដូច្នេះ ម្ចាស់បំណុលទាមទារប្រាក់ ដែលកូនបំណុលនឹងត្រូវបង់នាពេលអនាគតឱ្យហើយ ដើម្បីជៀសវាងទាមទារសំណងដែលមិនអនុវត្តនាពេលកន្លងមក ស្រាប់តែក្រោយមកកូនបំណុលលែងអនុវត្តកាតព្វកិច្ចនាពេលអនាគត។ ករណីនេះម្ចាស់បំណុលត្រូវដាក់ពាក្យប្តឹងម្តងទៀត ដែលធ្វើឱ្យខាតពេលវេលា និងថវិការបស់ម្ចាស់បំណុល។ ឧទាហរណ៍៖ តាំងពីកូនតុងទីនមិនអនុវត្តកាតព្វកិច្ចរហូតមកដល់ពេលនេះ មានទឹកប្រាក់សរុប ២៥០០ដុល្លារអាមេរិក។ តុងទីននឹងត្រូវបញ្ចប់ក្នុងរយៈពេល១០ខែទៀត ដែលត្រូវនឹងប្រាក់ ២,០០០ ដុល្លារអាមេរិក។ ប្រាក់ចំនួន២,០០០ដុល្លារអាមេរិកនេះហើយ ដែលជាសំណងការខូចខាតនាពេលអនាគត ហើយមេតុងទីនអាចប្តឹងទាមទារសរុបតែម្តងគឺ ៤,៥០០ដុល្លារអាមេរិក។

ចំពោះសំណងនៃការខូចខាតនេះក៏មានអាជ្ញាយុកាលក្នុងការប្តឹងទាមទារផងដែរ។ សំណងនៃការការខូចខាតនេះអាចទាមទារបានក្នុងរយៈពេល៥ឆ្នាំ គិតពីថ្ងៃដែលការខូចខាតនោះបានកើតឡើង [57] បើយោងទៅតាមក្រមរដ្ឋប្បវេណី។ បើហួសរយៈពេល៥ឆ្នាំហើយ ជនរងគ្រោះមិនអាចដាក់ពាក្យប្តឹងសុំសំណងការខូចខាតបានឡើង។ ក៏ប៉ុន្តែបើភាគីព្រមព្រៀងគ្នាលើសំណង ដែលជាការព្រមព្រៀងក្រៅប្រព័ន្ធតុលាការក៏មិនជាបញ្ហាដែរ ពោលភាគីអាចធ្វើបាន ទោះបីជាហួសអាជ្ញាយុកាលក៏ដោយ។

### ៣. ការផ្ទេរនូវសមាជិកភាពនៃតុងទីន

ក្នុងករណីដែលសមាជិកតុងទីនណាម្នាក់ អលទ្ធភាព ឬមិនអនុវត្តកាតព្វកិច្ចដោយមូលហេតុផ្សេងៗ ជននោះអាចផ្ទេរសមាជិកភាពរបស់ខ្លួនទៅជនដទៃបាន។ នៅក្នុងច្បាប់នៃការលេងតុងទីនក្នុងសម័យសង្គមរាស្ត្រនិយម យើងសង្កេតឃើញថា មានករណីផ្ទេរនូវសមាជិកភាពនៃតុងទីនតាមរយៈការលក់ហ៊ុនតុងទីន។ ចំណែកឯទិដ្ឋភាពជាក់ស្តែងនៅបច្ចុប្បន្ននេះ ការផ្ទេរនូវការសមាជិកភាពតុងទីនពិតជាកើតមានឡើងមែន (សូមមើលឧបសម្ព័ន្ធទី៧)។ ការផ្ទេរនូវសមាជិកភាពតុងទីននេះអាចធ្វើឡើងក្នុងទម្រង់ជារូបភាពនៃការលក់ទិញ ជាទម្រង់នៃការធ្វើប្រទានកម្ម ឬជាទម្រង់នៃការដូរជាអាទិ៍។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៦។

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤០៦។

ការលក់តុងទីននេះអាចជាករណីប្លែកសម្រាប់អ្នកសិក្សាស្រាវជ្រាវមួយចំនួន ដែលគិតថាមិនអាចមានការលក់ទិញតុងទីនដូចលក់ទិញឥវ៉ាន់ផ្សេងៗបាន។ ការលក់ទិញតុងទីននេះមិនមែនមានតែនៅក្នុងតុងទីនបច្ចុប្បន្ននេះទេ ពោលតុងទីននៅសម័យសង្គមរាស្ត្រនិយមក៏មានលក់ទិញដែរ ដែលស្តែងឱ្យឃើញនៅក្នុងច្បាប់តុងទីនថា កូនតុងទីនអាចលក់ហ៊ុនរបស់ខ្លួនមួយហ៊ុន ឬទាំងអស់ឱ្យទៅកូនតុងទីនម្នាក់ទៀត ឬឱ្យទៅជនដទៃបានគ្រប់ពេលទាំងអស់ តែត្រូវឱ្យមានសេចក្តីព្រមព្រៀងយ៉ាងជាក់ច្បាស់ពីមេតុងទីនផង [58] ។ ការលក់ទិញក្នុងតុងទីននេះ អ្នកលក់ជាសមាជិកដែលកំពុងលេងតុងទីនលែងចង់លេងតុងទីនបន្តទៀត ហើយចង់បានប្រាក់ដែលខ្លួនបានបង់កន្លងមកត្រឡប់មកវិញ ដូច្នេះត្រូវមាននរណាម្នាក់មកលេងបន្តជំនួសខ្លួន។ ជាថ្នូរនឹងការឱ្យបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន អ្នកទទួលបន្តត្រូវឱ្យថ្លៃទៅឱ្យអ្នកចាស់តាមការព្រមព្រៀងរបស់ភាគីទាំងពីរ។ តម្លៃនេះអាចជាចំនួនប្រាក់ដែលខ្លួនបានបង់តុងទីនកន្លងមក ដើម្បីយកជាមូលដ្ឋានក្នុងការដាក់តម្លៃលក់ ឬក៏អាចលើ ឬក្រោមតម្លៃនេះក៏ថាបាន ពោលគឺអាស្រ័យលើការព្រមព្រៀងរវាងភាគីទាំងសងខាង។ ការលក់ទិញនេះត្រូវមានការព្រមព្រៀងយ៉ាងជាក់ច្បាស់ពីមេតុងទីន ព្រោះមេតុងទីនជាអ្នកសម្របសម្រួល ជាអ្នកកណ្តាលរវាងកូនតុងទីនទាំងអស់ និងជាអ្នកទទួលខុសត្រូវក្នុងការលេងតុងទីន ដូច្នេះចាំបាច់ណាស់ត្រូវមានការយល់ព្រមពីមេតុងទីន ទើបអាចលក់ទិញបាន។

ចំណែកឯការធ្វើប្រទានកម្មនូវតុងទីននេះវិញ គឺអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចមិនមានកាតព្វកិច្ចត្រូវបង់ថ្លៃ ដែលជាថ្នូរនឹងការលទ្ធកម្មនូវសិទ្ធិនេះឡើយ ពោលជាការឱ្យអ្នកទទួលបន្តនោះដោយមិនគិតកម្រៃអ្វីនោះទេ។ ករណីនេះអាចកើតមានឡើងរវាងសាច់ញាតិរបស់កូនតុងទីន ឬអ្នកដែលមានទំនាក់ទំនងល្អជាមួយខ្លួន ដោយយល់ថាមិនចង់លេងបន្តទៀត ឬចង់ឱ្យតតិយជន ដែលខ្លួនឱ្យនោះទទួលបានផលប្រយោជន៍ពីតុងទីនរបស់ខ្លួនជាដើម។ ដូចគ្នានឹងការលក់ទិញតុងទីនដែរ ការធ្វើប្រទានកម្មនេះក៏ត្រូវមានការដឹងឮ និងព្រមព្រៀងពីមេតុងទីនដែរ ដើម្បីទុកជាការជូនដំណឹងដល់មេតុងទីនថាកូនតុងទីនមានការផ្លាស់ប្តូរ។

**៤. ការរំលាយតុងទីនមុនកំណត់**

ករណីនេះយើងក៏សង្កេតឃើញនៅកម្ពុជា ដែលកើតឡើងដោយសារតែមេតុងទីនបោកប្រាស់កូនតុងទីន ហើយមិនទទួលខុសត្រូវក្នុងការបន្តតុងទីន ហើយករណីខ្លះមានកូនតុងទីនច្រើនឈប់បង់ប្រាក់តុងទីន ជាហេតុនាំឱ្យមេតុងទីនមិនអាចមានលទ្ធភាពបង់តុងទីនជំនួសកូនតុងទីនទាំងនោះ។ លទ្ធភាពក្នុងការរំលាយតុងទីនមុនអាយុនេះមានចែងនៅក្នុងច្បាប់ស្តីពីតុងទីន ឆ្នាំ១៩៥៤។ ការរំលាយតុងទីនមុនអាយុនេះ បើឱ្យងាយយល់វិញ វាជាការបញ្ឈប់នូវការលេងតុងទីនក្នុងពេលដែលកូនតុងទីននៅទាន់បានដេញថ្លៃអស់ (នៅរស់) ពោលរំលាយមុនកាលកំណត់ដែលតុងទីននោះចប់ជាស្ថាពរ។ ការរំលាយតុងទីននេះអាចធ្វើទៅបានកាលណាមានការមិនបង់ប្រាក់ពីកូនតុងទីនច្រើន

[58] ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២០។

នាក់ហើយមេតុងទីនមិនមានលទ្ធភាពក្នុងការបង់ជំនួសកូនតុងទីនទាំងនោះ មេតុងទីនមានសិទ្ធិក្នុងការរំលាយតុងទីននោះមុនអាយុបាន ក្រោយពីបានពិភាក្សាជាមួយសមាជិកតុងទីន ហើយសមាជិកទាំងនោះយល់ព្រម។

បើក្រឡេកទៅមើលខ្លឹមសារច្បាប់វិញ ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។[59] មាត្រានេះ ជាការឆ្លើយតបទៅនឹងការមិនព្រមបង់ប្រាក់ច្រើននាក់ដែលយើងចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ដោយយោងទៅតាមខ្លឹមសារនេះ យើងអាចរំលាយតុងទីនមួយមុនកាលកំណត់របស់វាបាន។ នៅពេលដែលតុងទីនត្រូវបានរំលាយ វានឹងផ្តល់អានុភាពប្រតិសកម្ម។[60] ក្នុងន័យនេះ ចំពោះអ្នកដែលដេញបាន (មិនភៀសខ្លួន) ត្រូវប្រគល់ប្រាក់ដែលខ្លួនដេញបាន ទៅប្រគល់ជូនមេតុងទីនវិញ ហើយមេតុងទីនយកប្រាក់ទាំងនោះទៅចែកឱ្យអ្នកដែលមិនទាន់បានដេញតាមចំណែករៀងៗខ្លួន បើនិយាយឱ្យងាយយល់វិញ ការធ្វើបែបនេះ ប្រៀបដូចជាគ្មានតុងទីននេះកើតឡើងតាំងពីដំបូងអីញ្ចឹង ព្រោះអ្នកដែលបានបង់តុងទីនអស់ប៉ុន្មានត្រូវទទួលបានប៉ុណ្ណោះវិញ រីឯអ្នកដែលដេញបានប្រាក់ទាំងប៉ុន្មាន ត្រូវប្រគល់ឱ្យមេតុងទីនចាត់ចែងបន្តឱ្យទៅអ្នកដែលមិនទាន់ដេញបាន។ មេតុងទីនក៏ត្រូវធានាទទួលខុសត្រូវចំពោះការបែងចែកប្រាក់ទៅឱ្យកូនតុងទីន ដែលមិនទាន់ដេញឱ្យបានគ្រប់ចំនួនផងដែរ។ ក្នុងករណីមេតុងទីនគ្មានប្រាក់សង នោះអាចនឹងត្រូវបិទទ្វារឡាយឡុងនូវជំនួញរបស់ខ្លួន។

បន្ទាប់ពីបានជ្រាបអំពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរួចហើយមក ខាងក្រោមនេះ ជាការពន្យល់បកស្រាយចម្ងល់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងតុងទីន។

## ផ្នែកទី២៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

អ្នកច្បាប់ និងសាធារណជនមួយចំនួននៅតែគិតថា តុងទីនមិនអាចចូលទៅក្នុងបទល្មើសព្រហ្មទណ្ឌបានឡើយ ដោយសំអាងថាតុងទីនត្រូវបានបង្កើតឡើងក្នុងទម្រង់ជាកិច្ចសន្យាតែប៉ុណ្ណោះ។ ការលើកឡើងបែបនេះ មិនខុសទាំងស្រុងនោះឡើយ ដោយសារតែមានសំអាងសមហេតុសមផល។ ប៉ុន្តែបើយើងសង្កេតទៅលើការលេងតុងទីន ជាការលេងចាប់ពីសមាជិក២រូបឡើងទៅ កម្រ ឬស្ទើតែគ្មានការបង្កើតនូវតុងទីនណាដែលមានសមាជិកតែ ៣ទៅ៤នាក់ឡើយ ពីព្រោះវាផ្តល់អត្ថប្រយោជន៍តិចបំផុតដល់បុគ្គលដែលត្រូវការជំនួយហិរញ្ញវត្ថុបន្ទាន់។[61] កាលណាតែមានសមាជិកច្រើន មានន័យថាសាធារណជនបានចូលរួមក្នុងតុងទីននោះ។ បើយើងរំលឹកទៅដល់ក្រមព្រហ្មទណ្ឌវិញ គឺមានកម្មវត្ថុធានាការពារសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សុវត្ថិភាព សន្តិសុខទ្រព្យសម្បត្តិ និងសេចក្តីថ្លៃថ្នូររបស់សង្គម។[62] ក្នុងការលេងតុងទីន ប្រសិនបើមានកូនតុងទីន ឬមេតុងទីនណាម្នាក់រត់ចោលស្រុក ប្រាកដជាមាន

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤០៧។

[60] លី វ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី៣០។

[61] លី វ៉ុង, *តុងទីន* (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី៥ និងទី៦។

[62] លី វ៉ុង, តុងទីន (២០១៨), ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ទំព័រទី៣១។

ផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ការនិយាយតៗគ្នា និងបង្កជាការព្រួយបារម្ភដល់មេតុងទីន ឬកូនតុងទីនឯទៀតជាច្រើន។ មិនតែប៉ុណ្ណោះ បើយើងក្រឡេកទៅមើលច្បាប់ស្តីពីតុងទីន ឆ្នាំ១៩៥៤ វិញ ក៏យើងឃើញថា ច្បាប់សម័យនោះមានដាក់ទណ្ឌកម្មព្រហ្មទណ្ឌក្នុងរឿងតុងទីន ត្រង់មាត្រា១៥, ១៦, ២២, ២៧, និង២៨នៃច្បាប់នេះផងដែរ។

ក្នុងរឿងព្រហ្មទណ្ឌ អំពើរបស់មេតុងទីន ឬកូនតុងទីនអាចចោទពីបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែអំពើនោះបំពេញនូវធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។ ជាគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ អំពើដែលមិនបានបំពេញធាតុផ្សំបទល្មើសព្រហ្មទណ្ឌទេ តុលាការនឹងមិនអាចប្រកាសទោសព្រហ្មទណ្ឌបានឡើយ ពីព្រោះថាច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយយ៉ាងតឹងរ៉ឹង និងមិនអាចបកស្រាយក្នុងន័យប្រដូចបានឡើយ។

ជាបន្តទៅទៀតនឹងបកស្រាយអំពីបទល្មើសពីរដែលអាចកើតមានឡើងក្នុងរឿងតុងទីន គឺបទរំលោភលើទំនុកចិត្ត និងបទឆបោក។

## កថាភាគទី១៖ បទរំលោភលើទំនុកចិត្ត

ការរំលោភលើទំនុកចិត្ត ជាបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងការដកហូតទ្រព្យសម្បត្តិ ដែលកើតមានឡើងក្នុងពេលដែលជនល្មើសបានទទួលទ្រព្យសម្បត្តិស្របច្បាប់ តាមរយៈកិច្ចសន្យាជាមួយម្ចាស់ទ្រព្យសម្បត្តិ ហើយជនល្មើសនោះបានគៃបន្លំយកទ្រព្យសម្បត្តិនោះជាអចិន្ត្រៃយ៍ដោយចេតនា។ បទរំលោភលើទំនុកចិត្តបច្ចុប្បន្ននេះ កាលពីច្បាប់ព្រហ្មទណ្ឌអន្តរកាលគេឱ្យឈ្មោះថា បទគៃបំបាត់ទំនុកចិត្ត ប៉ុន្តែខ្លឹមសារ និងអត្ថន័យនៃបទល្មើសទាំងពីរនេះប្រហាក់ប្រហែលគ្នាទេ បើទោះបីជាការប្រើពាក្យខុសគ្នាបន្តិចក៏ដោយ។

ជួនកាលមានការភ័ន្តច្រឡំថា ការរំលោភលើកិច្ចសន្យា អាចចោទពីបទរំលោភលើទំនុកចិត្តនេះបាន។ មិនត្រឹមតែប៉ុណ្ណោះ តុលាការមួយចំនួនបានអនុវត្តមាត្រានេះខុសពីគោលគំនិតដើមរបស់ច្បាប់ ដោយចោទប្រកាន់បទល្មើសព្រហ្មទណ្ឌចំពោះការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីប្រាក់។ ក្រោយមកទើបមានសេចក្តីណែនាំរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល បំភ្លឺ និងបកស្រាយបន្ថែមទៅលើមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលថាបទល្មើសនេះកើតចេញពីកិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាឱ្យខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬមិនមែនរវាងនិយោជិត និងកម្មករ និយោជិត។[63]

ដើម្បីសិក្សាឱ្យបានច្បាស់លាស់ទៅលើបទល្មើសមួយនេះ យើងនឹងបង្ហាញទៅលើធាតុផ្សំនៃបទល្មើសទាំងបី និងបកស្រាយអំពើរំលោភលើទំនុកចិត្តក្នុងតុងទីន។

### ១. ធាតុនីត្យានុកូល

ក្រឡេកមកចាប់អារម្មណ៍ បទរំលោភលើទំនុកចិត្តបច្ចុប្បន្ននេះមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថា អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយ

[63] សេចក្តីណែនាំរួមស្តីពីការអនុវត្តមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, លេខ ០២ កយសណន/០៥, ០៨ សីហា ២០០៥។

បុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។[64]

ទោសចំពោះបទល្មើសនេះមាននៅមាត្រា៣៩២ អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ១,០០០,០០០ (មួយលាន) រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន) រៀល។[65] មិនតែប៉ុណ្ណោះ បទរំលោភលើទំនុកចិត្តនេះក៏មានផ្តន្ទាទោសចំពោះការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមនេះដែរ ដែលយើងអាចឃើញមាននៅមាត្រា៣៩៥ នៃក្រមដដែល។

**២. ធាតុសត្យានុម័ត**

បើយោងទៅតាមព្រឹត្តិបត្រមេធាវីអំពីការប្រៀបធៀបបទល្មើសរំលោភលើទំនុកចិត្ត និងបទល្មើសឆបោក របស់ឯកឧត្តម **សួន វិសាល** បទល្មើសរំលោភលើទំនុកចិត្តនេះមានធាតុផ្សំសត្យានុម័តចំនួន៥ជាចម្បង[66]ដូចតទៅ៖

**១- គៃបំបាត់៖** នៅក្នុងន័យនេះ សំដៅទៅលើការគេងចំណេញលើអ្នកដទៃនូវទ្រព្យសម្បត្តិ ប្រាក់កាក់ ទំនិញ ឬឯកសារអ្វីមួយ។ ចំពោះអ្នកដែលត្រូវគេគៃបំបាត់នោះគឺជាម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់។ ម្ចាស់កម្មសិទ្ធិ គឺសំដៅទៅលើអ្នកដែលមានកម្មសិទ្ធិស្របច្បាប់ ដើម្បីប្រើប្រាស់ ចាត់ចែង ឬអាស្រ័យផល ដូចជាការលក់ផ្ទេរ បញ្ចាំជាដើម។ រីឯ ម្ចាស់ទីកន្លែង ចង់សំដៅលើអ្នកដែលមានសិទ្ធិកាន់កាប់ទៅលើអចលនវត្ថុ ដោយស្របច្បាប់ ហើយវាក៏ប្រហែលនឹងពាក្យ អ្នកកាន់កាប់ ផងដែរ។ អ្នកកាន់កាប់ ចង់សំដៅអ្នកដែលមានសិទ្ធិប្រើប្រាស់ ឬអាស្រ័យផលទៅលើវត្ថុអ្វីមួយ។ ដើម្បីឱ្យមានភាពងាយស្រួល យើងអាចប្រើពាក្យ ម្ចាស់ ឬ ម្ចាស់វត្ថុ ជំនួសពាក្យទាំងបីខាងលើក៏បាន។ សរុបមក ការគៃបំបាត់ គឺជាការគេងចំណេញ ឬផលប្រយោជន៍ពីជនណាម្នាក់ ហើយតាមរយៈការគេងចំណេញ ឬប្រយោជន៍នេះបានធ្វើឱ្យម្ចាស់ទ្រព្យបាត់បង់ប្រយោជន៍របស់ខ្លួន។

**២- មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ៖** នៅចំណុចនេះ យើងត្រូវយល់ឱ្យបានច្បាស់លាស់នូវអត្ថន័យនៃពាក្យៈ

- មូលនិធិ សំដៅទៅលើប្រាក់កាសដែលមានតម្លៃ ហើយអាចចាយវាយបាន។
- តម្លៃ សំដៅទៅលើវត្ថុមានតម្លៃ រួមទាំងឯកសារផ្សេងៗ។
- ទ្រព្យសម្បត្តិ គឺជារបស់ ឬអ្វីៗ ដែលជាកម្មសិទ្ធិ។

**៣- នាំឱ្យខូចប្រយោជន៍របស់អ្នកដទៃ៖** សំដៅលើអំពើធ្វើឱ្យបាត់បង់ ឬខូចខាតលាភធនរបស់ជនណាម្នាក់។ ដូច្នេះ វាត្រូវតែស្តែងឱ្យឃើញនូវការបាត់បង់ ឬការខូចខាតលាភធនរបស់ម្ចាស់ទ្រព្យជាចាំបាច់។

---

[64] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩១។

[65] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩២។

[66] សួន វិសាល, "ការប្រៀបធៀបបទល្មើសរំលោភលើទំនុកចិត្ត និងបទល្មើសឆបោក", ព្រឹត្តិបត្រមេធាវី លេខ៦, មេសា-មិថុនា ២០១២, ទំព័រទី២។

**៤- ម្ចាស់ ឬម្ចាស់មូលនិធិបានប្រគល់មកឱ្យខ្លួន៖** នៅក្នុងចំណុចនេះ ជនល្មើសបានទទួលពីម្ចាស់នូវមូលនិធិ នូវតម្លៃ ឬទ្រព្យ ដោយស្របច្បាប់ និងការទុកចិត្តគ្នាតាមរយៈ៖

- ការជួល
- ការតម្កល់ទុក
- អាណត្តិ ឬ
- ការឱ្យខ្ចីប្រើ។

**៥- ជនល្មើសបានយល់ព្រមប្រគល់សងវិញ ឬប្រើប្រាស់ជាកំណត់៖** ចំណុចនេះ ជនល្មើសបានយល់ព្រមតាមលក្ខខណ្ឌរបស់ម្ចាស់ទ្រព្យ ដូចជាការសងមកម្ចាស់ដើមវិញ ឬត្រូវចាត់ចែង ឬប្រើប្រាស់ទ្រព្យតាមការកំណត់របស់ម្ចាស់ទ្រព្យ មុននឹងម្ចាស់ទ្រព្យប្រគល់មកឱ្យខ្លួន។ ក្នុងន័យនេះ ជនល្មើសមានកាតព្វកិច្ចក្នុងការសង ចាត់ចែង ឬប្រើប្រាស់តាមបំណងរបស់ម្ចាស់ទ្រព្យជាការចាំបាច់។

យើងសង្កេតឃើញថា គោលបំណងនៃការព្រមព្រៀងរវាងជនល្មើស និងជនរងគ្រោះគឺជាការប្រគល់វត្ថុទៅឱ្យជនល្មើស ដោយដាក់បន្ទុកឱ្យជនល្មើសនូវកាតព្វកិច្ចមួយចំនួនដែលជនល្មើសត្រូវប្រតិបត្តិ ពុំមែនប្រគល់វត្ថុឱ្យជនល្មើសផ្តាច់យកទៅចាត់ចែងប្រើប្រាស់តាមទំនើងចិត្តរបស់ខ្លួនទេ។ ដូច្នេះ ប្រសិនបើមានការផ្ទេរកម្មសិទ្ធិលើវត្ថុ ឬឱ្យភាគីម្ខាងទៀតចាត់ចែងតាមចិត្តរបស់ខ្លួន ពុំបង្កើតជាបទរំលោភលើទំនុកចិត្តនេះទេ។

**៣. ធាតុអត្តនោម័ត**

ធាតុអត្តនោម័តក្នុងបទរំលោភលើទំនុកចិត្តនេះ ពិតជាមានសារៈសំខាន់ណាស់ ព្រោះថា បទល្មើសនេះតម្រូវឱ្យចារីមានចេតនាក្នុងការប្រព្រឹត្តនូវបទល្មើសនេះ បើមិនមានចេតនាក្នុងការប្រព្រឹត្តទេ មិនមែនជាបទល្មើសនេះទេ បើទោះបីជាចូលទៅក្នុងធាតុផ្សំខាងលើក៏ដោយ។ ក្នុងសារធាតុនៃបទល្មើសនេះ ជាដំបូងជនល្មើសមិនមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនេះទេ ប៉ុន្តែក្រោយពីទទួលបានវត្ថុរួចហើយ ជនល្មើសមានគំនិតចង់បានវត្ថុនោះជារបស់ខ្លួនតាមរយៈមធ្យោបាយទុច្ចរិត។ ក្នុងន័យនេះ បើមិនមានចេតនាទេ វានឹងចូលទៅក្នុងករណីបំពានកិច្ចសន្យាវិញ ដែលជាការមិនអនុវត្តកាតព្វកិច្ច ដោយមូលហេតុណាមួយ។ ដូច្នេះ ជនរងគ្រោះត្រូវបង្ហាញថា ចារីពិតជាមានចេតនាក្នុងការមិនអនុវត្តកាតព្វកិច្ចដែលដំបូងឡើយកើតចេញពីកិច្ចសន្យាប្រាកដមែន។

តាមរយៈនិយមន័យនៃអំពើរំលោភលើទំនុកចិត្តដែលផ្តល់ដោយច្បាប់ព្រហ្មទណ្ឌថ្មី ការរំលោភលើទំនុកចិត្តកើតឡើង នៅពេលដែលយោងតាមបុរេនិច្ច័យនៃអ្នកឯទៀត ជនម្នាក់បានគេបន្លំមូលនិធិ ទ្រព្យមានតម្លៃ ឬទ្រព្យណាមួយ

ដែលគេបានប្រគល់ឱ្យទទួលខុសត្រូវ ហើយជននោះបានយល់ព្រមទទួលវត្ថុនោះ ទៅតាមលក្ខខណ្ឌនៃការសងវិញ ប្រគល់ឱ្យវិញ ឬប្រើប្រាស់វាតាមរបៀបកំណត់មួយ។[67]

បើយើងក្រឡេកទៅក្រោយបន្តិច ច្បាប់តុងទីនសម័យសង្គមរាស្ត្រនិយមបានចាត់ទុកថា មេតុងទីនប្រព្រឹត្តបទគៃបំបាត់លើទំនុកចិត្តកាលណា មេតុងទីនគៃបំបាត់ជាប្រយោជន៍ខ្លួន ឬប្រយោជន៍អ្នកដទៃនូវប្រាក់ ដែលកូនតុងទីនអ្នកដេញបានពីលើកមុន បានប្រគល់ឱ្យខ្លួន មិនព្រមប្រគល់ឱ្យកូនតុងទីន ដែលមិនទាន់បានដេញបានតាមចំនួនទឹកប្រាក់ ដែលអ្នកទាំងនោះបានបង់ចំណែករៀងខ្លួន។[68] ចំណែកឯតុងទីនបច្ចុប្បន្នយើងនេះវិញស្ថិតនៅក្នុងកិច្ចសន្យាអាណត្តិ ដោយមេតុងទីនមានបេសកកម្មប្រមូលប្រាក់ និងរៀបចំតុងទីនឱ្យមានភាពរលូន រីឯកូនតុងទីនត្រូវបង់ប្រាក់ឱ្យបានទាន់ពេលវេលា។ ចំពោះកូនតុងទីនណាដែលបានដេញតុងទីនហើយប្រមូលយកប្រាក់ពីផលនៃតុងទីននោះ ក្រោយមកស្រាប់តែឈប់បង់ប្រាក់ទៅឱ្យមេតុងទីនដោយចេតនាតាមរូបភាពនៃការរត់គេចខ្លួនជាអាទិ៍ គេចាត់ទុកថា កូនតុងទីនម្នាក់នោះបានប្រព្រឹត្តអំពើរំលោភលើទំនុកចិត្ត ដោយសារមិនបានបង់ប្រាក់ដោយចេតនាបន្ទាប់ពីខ្លួនបានដេញរួចហើយ។ ចំណែកឯមេតុងទីនក៏ដូចគ្នាដែរ ប្រសិនបើមានកូនតុងទីនណាម្នាក់ដេញបាន មេតុងទីនប្រមូលប្រាក់គ្រប់ចំនួនហើយបែរជាមិនប្រគល់ប្រាក់នោះទៅឱ្យអ្នកដែលដេញបាននោះ ក្នុងគោលបំណងទុកជាប្រាក់របស់ខ្លួន ឬប្រមូលបានហើយរត់គេចខ្លួនបាត់ជាដើម។ សកម្មភាពដែលបានរៀបរាប់ខាងលើ ជាធាតុសត្យានុម័តដែលមានក្នុងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។ ការធ្វើបែបនេះទៀតសោត ត្រូវមានចេតនាក្នុងការប្រព្រឹត្ត បើមិនមានចេតនាក្នុងការប្រព្រឹត្តទេ មិនចូលទៅក្នុងធាតុអត្តនោម័តនៃនីតិព្រហ្មទណ្ឌឡើយ។ ហេតុនេះ មេតុងទីនក៏នឹងមិនត្រូវបានចោទពីបទរំលោភលើទំនុកចិត្តដែរ បើគ្មានចេតនាទុច្ចរិត ដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់។

**កថាភាគទី២៖ បទឆបោក**

បទល្មើសឆបោក ជាបទល្មើសមួយ ដែលយើងសង្កេតឃើញថា អាចកើតមានឡើងនៅក្នុងរឿងតុងទីន។ បទឆបោកនេះប្រហាក់ប្រហែលនឹងបទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ ដែលមានចែងនៅមាត្រា៣៨៣ នៃក្រមព្រហ្មទណ្ឌដែរ ប៉ុន្តែយើងមិនធ្វើការប្រៀបធៀបបទល្មើសទាំងពីរនៅទីនេះនោះទេ។ គ្រប់អំពើនៃបទល្មើសនេះ សុទ្ធតែមានគម្រោងទុកជាមុន ដើម្បីកុហកជនរងគ្រោះឱ្យជឿជាក់លើខ្លួន ហើយទទួលបានប្រយោជន៍ពីការកុហកនោះ។ យើងនឹងសិក្សាអំពីធាតុផ្សំនៃបទឆបោកនេះឱ្យកាន់តែស៊ីជម្រៅ។

---

[67] រឿងក្តីអំពីការរំលោភលើទំនុកចិត្ត៖ ការអនុវត្តដោយមិនត្រឹមត្រូវ និងឥទ្ធិពលរបស់វាមកលើ សេដ្ឋកិច្ចកម្ពុជា, ឯកសារពិភាក្សាវិស័យឯកជន លេខ២៣, សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC), ទំព័រទី២៨។

[68] ច្បាប់ស្តីពីតុងទីន, លេខ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២៧។

**១. ធាតុនីត្យានុកូល**

អំពើឆបោកគឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវៈ[69]

**១-** ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ

**២-** ការផ្តត់ផ្គង់សេវា

**៣-** ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

អំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១,០០០,០០០ (មួយលាន)រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន)រៀល។[70]

**២. ធាតុសត្យានុម័ត**

ផ្អែកទៅតាមបទបង្ហាញ "នីតិព្រហ្មទណ្ឌពិសេស" សម្រាប់សិស្សថ្នាក់បរិញ្ញាបត្រឆ្នាំទី៣ ដែលត្រូវបានរៀបរៀងដោយសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ធាតុសត្យានុម័តនៅក្នុងបទល្មើសនេះ មានធាតុផ្សំ២យ៉ាងជាចម្បង[71]៖ អំពើបន្លំដែលធ្វើឱ្យមានការប្រគល់វត្ថុ និងការប្រគល់វត្ថុដោយស្ម័គ្រចិត្ត។

**១- អំពើបន្លំដែលធ្វើឱ្យមានការប្រគល់វត្ថុ**

ការបន្លំនេះសំដៅដល់ការប្រើល្បិច ឬការបញ្ចុះបញ្ចូលតាមរយៈសំដី ឬឯកសារ ដើម្បីឱ្យជនណាម្នាក់ជឿជាក់មកលើខ្លួន ហើយទទួលយកអ្វីមួយ ដែលខុសពីការពិត។ សកម្មភាពនេះប្រព្រឹត្តឡើង ដោយមានគម្រោងការទុកជាមុនក្នុងគោលបំណងមួយច្បាសលាស់។

ការបន្លំនេះអាចចែកចេញជាពីរប្រភេទ៖

- ការភូតភរក្នុងទំនាក់ទំនងបុគ្គល អាចជា៖
  - ប្រើឈ្មោះក្លែង៖ ការប្រើនាម ឬត្រកូលរបស់អ្នកដទៃ ឬការប្រើត្រកូល និងនាម ដែលជនល្មើសប្រឌិតឡើងដោយខ្លួនឯង។
  - អះអាងលើឋានៈក្លែង៖ ឋានៈរបស់បុគ្គលណាមួយ ដែលគេមានសិទ្ធិប្រើតាំងពីកំណើត ដោយសារមុខងារវិជ្ជាជីវៈផ្សេងៗ។

---

[69] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៧៧។

[70] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៧៨។

[71] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, "នីតិព្រហ្មទណ្ឌពិសេស", (បទបង្ហាញសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៤)។

- ○ វិលោភលើឋានៈពិតប្រាកដ។

➢ ការប្រើឧបាយកលទុច្ចរិត

ការប្រើឧបាយកលទុច្ចរិត សំដៅទៅលើការភូតកុហក រួមបញ្ចូលជាមួយនឹងកលល្បិចផ្សេងទៀត ដែលតែងតែស្តែងឡើងតាមរយៈអំពើខាងក្រៅតាមរយៈ ៖

- ○ ការលេងល្បែងឆ្អិនឆ្អែក
- ○ ការប្រើប្រាស់អន្តរាគមន៍ពីអ្នកដទៃ ដើម្បីពង្រឹងជំនឿរបស់ជនរងគ្រោះ។

**២- ការប្រគល់វត្ថុដោយស្ម័គ្រចិត្តពីជនរងគ្រោះ**

ដើម្បីឱ្យមានបទឆបោក លុះត្រាតែការប្រគល់វត្ថុនោះធ្វើឡើងដោយសារតែជនរងគ្រោះជឿតាមការបន្លំរបស់ជនល្មើស។ ក្នុងនោះដែរ ដោយសារតែជនរងគ្រោះជឿជាក់លើជនល្មើស ជនរងគ្រោះស្ម័គ្រចិត្តឱ្យកម្មវត្ថុឱ្យជនល្មើស ដោយមិនមានការគំរាមកំហែងអ្វីនោះឡើយ។ កម្មវត្ថុដែលប្រគល់ដោយជនរងគ្រោះរួមមាន៖

➢ ការប្រគល់វត្ថុ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

➢ ការផ្គត់ផ្គង់សេវា។

➢ ការធ្វើលិខិតដែលមានតម្លៃកាតព្វកិច្ច ឬជាការឱ្យរួចផុតពីកាតព្វកិច្ច។

**៣. ធាតុអត្តនោម័ត**

ជនល្មើសមានចេតនាទុច្ចរិតប្រព្រឹត្តបទល្មើសនេះ ដើម្បីទទួលបានផលប្រយោជន៍អ្វីមួយពីជនរងគ្រោះ។ ក្នុងបទល្មើសឆបោកនេះ ជនល្មើសមានបំណង ឬគម្រោងទុកជាមុនសម្រាប់ធ្វើសកម្មភាព ដោយមានរូបភាពជាការក្លែងឈ្មោះ ក្លែងឋានៈ វិលោភលើឋានៈពិតប្រាកដ ដើម្បីឱ្យជនរងគ្រោះជឿជាក់លើខ្លួន ហើយប្រគល់នូវទ្រព្យសម្បត្តិ ឬការផ្គត់ផ្គង់សេវា ឬការធ្វើលិខិត មានតម្លៃកាតព្វកិច្ច ឬឱ្យរួចពីកាតព្វកិច្ចជាដើម។

តាមរយៈនិយមន័យដែលច្បាប់ផ្តល់ឱ្យអំពើឆបោក យើងអាចនិយាយបានថា អំពើឆបោក ជាអំពើដែលបុគ្គលណាម្នាក់ បន្លំចំពោះបុគ្គលផ្សេងទៀត ដោយការប្រើឈ្មោះក្លែង ឬឧបាយកលទុច្ចរិត ដើម្បីបន្លំធ្វើជាបុគ្គលម្នាក់ទៀតក្នុងគោលបំណងដើម្បីបានផលប្រយោជន៍ពីអ្នកដែលខ្លួនបន្លំដាក់។ ខ្ញុំងាយយល់គឺជាការបន្លំថាខ្លួនមានឋានៈណាមួយដែលការពិតខ្លួនមិនមែនឋានៈបែបនោះឡើយ ឬក៏ជនល្មើសមានឧបាយកលទុច្ចរិត ដើម្បីឱ្យជនរងគ្រោះប្រគល់វត្ថុដែលជាកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស។ ចារីដែលប្រព្រឹត្តបទល្មើសនេះ គឺប្រព្រឹត្តដោយមានចេតនា និងមានមធ្យោបាយ ដែលធ្វើឱ្យជនរងគ្រោះ ជឿជាក់ ដើម្បីទទួលបានមូលនិធិ ប្រាក់កាស វត្ថុ សម្ភារៈ ពីជនរងគ្រោះមកឱ្យជនល្មើស។

ក្នុងច្បាប់គុងទីនចាស់ ត្រូវទុកជាបានឆបោក ដោយប្រើឧបាយកលទុច្ចរិត មេគុងទីនណាកុហកកូនគុងទីនណាម្នាក់ ដែលជាអ្នកដេញបានក្នុងគុងទីនឯណាមួយ ដោយក្លែងថាគុងទីននោះរលាយបាត់មុនអាយុទៅហើយ ដើម្បីឱ្យ

កូនតុងទីននោះប្រគល់ប្រាក់មកឱ្យខ្លួន។ [72] ចំណែកឯកូនតុងទីនណាដេញតុងទីនបានដោយឱ្យការច្រើនហួសពេក ហើយក្រោយមកឈប់បង់ប្រាក់ចំណែកខ្លួនទៅ កូនតុងទីននោះទុកជាបានល្មើសនឹងមាត្រា៥១៥ វគ្គទី៣ នៃក្រមព្រហ្មទណ្ឌ (ឆបោក)។[73] នៅបច្ចុប្បន្ននេះវិញ មេតុងទីនណាដែលធ្វើឱ្យកូនតុងទីនជឿជាក់ថា ជាតុងទីនមួយត្រឹមត្រូវ ប៉ុន្តែតុងទីននោះមានសមាជិកភាគច្រើនគ្មានរូបសោះ ឬមិនបានចូលលេងតុងទីននោះសោះ មេតុងទីនក៏ត្រូវប្រឈមមុខនឹងច្បាប់ពីបទឆបោក។ ចំណែកឯកូនតុងទីនក៏យ៉ាងដូច្នេះដែរ កូនតុងទីននោះបន្លំឈ្មោះតុងទីនក្រៅពីឈ្មោះខ្លួនក្នុងគោលបំណង ដើម្បីដេញយកប្រាក់ពីតុងទីនដែលគ្មានមនុស្សលេងនោះ។ ជនដែលបានចូលរួមក្នុងការបិទបាំងអំពីតុងទីនខ្មោចនោះ នឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌក្នុងឋានៈជាអ្នកសមគំនិតផងដែរ។ ដែលទាំងអស់នេះជាធាតុផ្សំសត្យានុម័តនៃបទល្មើសព្រហ្មទណ្ឌ។ ការធ្វើបែបនេះទៀតសោត ត្រូវមានបំណង ឬចេតនាក្នុងការប្រព្រឹត្ត បើមិនមានបំណង ឬចេតនាក្នុងការប្រព្រឹត្តទេ មិនចូលទៅក្នុងធាតុអត្តនោម័តនៃនីតិព្រហ្មទណ្ឌឡើយ។

ឧទាហរណ៍ថា បុរសម្នាក់ឈ្មោះ ឌីណា ហើយទៅក្លែងឈ្មោះតុងទីនទៅជា វុធ វី ហើយដេញតុងទីនយកប្រាក់ ហើយក៏ឈប់បង់តុងទីនចាប់ពីពេលដេញតុងទីនបានទាំងអស់ ដោយកុហកថាឈ្មោះ វុធ និងវី ខាងលើមិនដែលឱ្យប្រាក់ឱ្យខ្លួនយកមកបង់ទេ។ ការក្លែងឈ្មោះ ដើម្បីទទួលបានមូលនិធិតុងទីន ឬទ្រព្យសម្បត្តិនេះ ជាអំពើឆបោកដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា។ ឧទាហរណ៍មួយខាងលើនេះជាឧទាហរណ៍មួយដ៏ងាយយល់ករណីឆបោកនៅក្នុងរឿងតុងទីន។ ការឆបោកក្នុងករណីនេះ គឺជាការក្លែងឈ្មោះតុងទីនរបស់លោក ឌីណា ទៅជាឈ្មោះផ្សេងក្រៅពីឈ្មោះរបស់ខ្លួន ក្នុងគោលបំណងទុច្ចរិត រួចដេញតុងទីននោះដើម្បីប្រមូលប្រាក់ ប៉ុន្តែតុងទីននោះមិនមានអ្នកលេងទេ (តុងទីនខ្មោច)។ ពេលដែលដេញបានក៏មិនព្រមបង់តុងទីនបន្តទៀត។

បន្ទាប់ពីបានស្វែងយល់អំពីទិដ្ឋភាពទូទៅ ក៏ដូចជាការទទួលខុសត្រូវរបស់ភាគីក្នុងការលេងតុងទីន ដែលជាលក្ខណៈទ្រឹស្តីរួចហើយមក នៅជំពូកចុងក្រោយ យើងនឹងបានសិក្សាទៅលើករណីសិក្សាក្នុងរឿងតុងទីនវិញម្តង។

[72] ច្បាប់ស្តីពីតុងទីន, លេខ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២៨។

[73] ច្បាប់ស្តីពីតុងទីន, លេខ៨៦៥ នស, ២៧ ឧសភា ១៩៥៤, មាត្រា២២។

# ជំពូកទី៣

# ករណីសិក្សាក្នុងរឿងតុងទីន

# ជំពូកទី៣៖
# ករណីសិក្សាក្នុងរឿងតុងទីន

ការសិក្សាទៅលើទ្រឹស្តីពិតជាមានសារៈសំខាន់ណាស់ ដើម្បីយកទ្រឹស្តីច្បាប់នោះទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្តែង ដែលបានកើតមានឡើងក្នុងសង្គមរស់នៅប្រចាំថ្ងៃ។ ការសិក្សាទៅលើទ្រឹស្តីតែមួយមុខ អ្នកសិក្សាស្រាវជ្រាវអាចមានការពិបាកក្នុងការស្វែងយល់ឱ្យបានស៊ីជម្រៅ ដូច្នេះហើយនៅក្នុងជំពូកនេះ យើងខ្ញុំនឹងរំលេចនូវអង្គហេតុបានកើតឡើងក្នុងការលេងតុងទីន សម្រាប់ធ្វើជាករណីសិក្សាជាក់ស្តែង និងបង្ហាញនូវតថភាពក្នុងការលេងតុងទីនជាមួយនឹងទិដ្ឋភាពច្បាប់របស់កម្ពុជាយើងបច្ចុប្បន្ន។

នៅក្នុងជំពូកនេះ យើងនឹងបានសិក្សាទៅលើករណីសិក្សាក្នុងរឿងរដ្ឋប្បវេណី (ផ្នែកទី១) ទាំងករណីសិក្សាក្នុងរឿងព្រហ្មទណ្ឌ (ផ្នែកទី២) សម្រាប់យកជាមូលដ្ឋានក្នុងការពិចារណាអំពីកិច្ចគតិយុត្តក្នុងបញ្ហានៃការលេងតុងទីន។ ជាបន្តទៅទៀត សូមលើកឡើងនូវចំណុចទាំងនោះដូចតទៅ។

## ផ្នែកទី១៖ ករណីសិក្សាក្នុងរឿងក្តីរដ្ឋប្បវេណី

### អង្គហេតុ

កូនតុងទីនម្នាក់បានលេងតុងទីន៣ក្បាល ដោយក្នុងមួយក្បាលតម្លៃ២០០ដុល្លារអាមេរិក សមាជិកសរុប ៤៨ នាក់។ នៅខែបន្តបន្ទាប់ កូនតុងទីនបានដេញតុងទីនទាំងអស់នោះ ហើយទទួលបានប្រាក់សរុបចំនួន ២០,៥០០ ដុល្លារអាមេរិក។ នៅពេលប្រគល់ប្រាក់ មេតុងទីនបានឱ្យកូនតុងទីនធ្វើកិច្ចសន្យាទទួលស្គាល់ថា ខ្លួនពិតជាបានទទួលប្រាក់តុងទីន២០,៥០០ដុល្លារអាមេរិកគ្រប់ចំនួនមែន។ ចាប់ពីថ្ងៃដែលមេតុងទីនបានប្រគល់ប្រាក់ឱ្យកូនតុងទីននេះគ្រប់ចំនួនហើយ ការបង់ប្រាក់របស់កូនតុងទីនចាប់ផ្តើមបង់យឺតយ៉ាវ ម្តងថាថ្ងៃនេះ ម្តងថាថ្ងៃនោះ មានន័យថាកូនតុងទីនមិនដែលបង់ប្រាក់តុងទីនបន្តទៀតទេ។ ចាប់ពីពេលនោះមក មេតុងទីនជាអ្នកបង់ជំនួសរហូតដល់ចប់តុងទីន។

លុះក្រោយមកក៏លេចឮថា កូនតុងទីននោះជំពាក់បំណុលគេជាច្រើនគ្នា ចំណូលធ្លាក់ចុះ ហើយថែមទាំងធ្លាក់ខ្លួនឈឺធ្ងន់ទៀតផង។ មេតុងទីនតែងតែទៅទារប្រាក់តុងទីនពីកូនតុងទីននោះដែរ ប៉ុន្តែកូនតុងទីននោះប្រាប់ថាខ្លួនគ្មានលទ្ធភាពសងទៀតទេ ចំណែកឯប្រាក់តុងទីនដែលខ្លួនជំពាក់នោះ ខ្លួនទទួលស្គាល់ថាជំពាក់ប៉ុណ្ណឹងមែន។

### កំណែលំហាត់អនុវត្ត

កូនតុងទីនម្នាក់បានលេងតុងទីន៣ក្បាល ដោយក្នុងមួយក្បាលតម្លៃ២០០ដុល្លារអាមេរិក សមាជិកសរុប ៤៨ នាក់។ នៅខែបន្តបន្ទាប់ កូនតុងទីនបានដេញតុងទីនទាំងអស់នោះ ហើយទទួលបានប្រាក់សរុបចំនួន ២០,៥០០ ដុល្លារអាមេរិក។ នៅពេលប្រគល់ប្រាក់ មេតុងទីនបានឱ្យកូនតុងទីនធ្វើកិច្ចសន្យាទទួលស្គាល់ថា ខ្លួនពិតជាបានទទួលប្រាក់តុងទីន២០,៥០០ដុល្លារអាមេរិកគ្រប់ចំនួនមែន។ ចាប់ពីថ្ងៃដែលមេតុងទីនបានប្រគល់ប្រាក់ឱ្យកូនតុងទីននេះគ្រប់ចំនួនហើយ កូនតុងទីនលែងអនុវត្តកាតព្វកិច្ចបង់តុងទីនបន្តទៀត។ ចាប់ពីពេលនោះមក មេតុងទីនជាអ្នកបង់ជំនួស

របូតដល់ចប់តុងទីន។ មេតុងទីនតែងតែទៅទារប្រាក់តុងទីនពីកូនតុងទីននោះ ប៉ុន្តែកូនតុងទីននោះប្រាប់ថាខ្លួនគ្មានលទ្ធភាពសងទៀតទេ ដោយសារមូលហេតុសេដ្ឋកិច្ចរបស់ខ្លួន ចំណែកឯប្រាក់តុងទីនដែលខ្លួនជំពាក់នោះ ខ្លួនទទួលស្គាល់ថាជំពាក់ប៉ុណ្ណឹងមែន។ មេតុងទីនដឹងថាកូនតុងទីនដី មានផ្ទះ ប៉ុន្តែកូនតុងទីននោះមិនព្រមលក់ដីយកប្រាក់មកសងខ្លួនទេ។

តើមេតុងទីនត្រូវធ្វើដូចម្តេច ដើម្បីទាមទារប្រាក់ត្រលប់មកវិញពីកូនតុងទីនបាន?

យោងមាត្រា៥៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ "**ការខ្ចីបរិភោគ សំដៅទៅកិច្ចសន្យាមួយ ដែលភាគីម្ខាងហៅថាអ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ស្រូវ ឬវត្ថុជំនួសផ្សេងទៀតក្នុងអំឡុងដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ**"។ រីឯមាត្រា៥៩១ នៃក្រមដដែល បានបញ្ញត្តថា "**អ្នកខ្ចីមានករណីយកិច្ចត្រូវសងទៅឱ្យអ្នកខ្ចី នូវវត្ថុ ដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុ ដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង**"។ និងមាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ចែងថា "**បុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង**"។

ជាក់ស្តែង កូនតុងទីនពិតជាបានទទួលប្រាក់តុងទីនចំនួន២០,៥០០ដុល្លារអាមេរិកប្រាកដមែន ហើយកូនតុងទីនក៏ទទួលស្គាល់ថាខ្លួនជំពាក់មេតុងទីនប៉ុណ្ណឹងមែន។ បញ្ហានៅត្រង់ថា កូនតុងទីនមិនមានលទ្ធភាពក្នុងការសងមេតុងទីន បានជានាំឱ្យកើតមានបញ្ហាបែបនេះ។ កូនតុងទីនមិនមានលទ្ធភាពកូនតុងទីនបានដោយសារមូលហេតុសេដ្ឋកិច្ចរបស់ខ្លួន។ កូនតុងទីនបានទទួលប្រាក់ពីមេតុងទីនក្នុងរូបភាពជាការជំពាក់ប្រាក់មេតុងទីន ហើយខ្លួនបានយកប្រាក់នោះទៅចាយវាយអស់ទៅហើយ ប៉ុន្តែនៅពេលដែលត្រូវចាប់ផ្តើមបង់តុងទីនបន្តទៀត ខ្លួនគ្មានប្រាក់បង់នោះទេ។

ផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ យើងសង្កេតឃើញថា កូនតុងទីនមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ប្រាក់ត្រលប់ទៅឱ្យមេតុងទីនវិញ ក្នុងរូបភាពជាការខ។ ដូច្នេះដើម្បីសម្រេចសិទ្ធិនូវការទាមទារប្រាក់របស់មេតុងទីនបាន មេតុងទីនត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់កូនតុងទីននោះ ពីព្រោះថា កូនតុងទីនបញ្ជាក់យ៉ាងច្បាស់ថាខ្លួនគ្មានលទ្ធភាពសងប្រាក់ឱ្យមេតុងទីនវិញនោះទេ ហើយក៏មិនបង្ហាញឆន្ទៈថានឹងលក់ដី ឬលក់ផ្ទះកន្លែងណាមួយយកមកសងមេតុងទីនដែរ។ បើមេតុងទីនមិនសម្រេចសិទ្ធិតាមរយៈការអនុវត្តដោយបង្ខំទេ ស្ថានភាពរបស់កូនតុងទីនមិនអាចសងមេតុងទីនឡើយ។

## ផ្នែកទី២៖ ករណីសិក្សាក្នុងរឿងព្រហ្មទណ្ឌ

ក្នុងករណីសិក្សារឿងក្តីតុងទីន ដែលអាចកើតមានជាបទល្មើសព្រហ្មទណ្ឌនេះ យើងនឹងបានស្វែងយល់ពីបទល្មើសទាំងពីរ ដែលកើតមានក្នុងរឿងតុងទីនគឺ បទរំលោភលើទំនុកចិត្ត (កថាភាគទី១) និងបទឆបោក (កថាភាគទី២)។

### កថាភាគទី១៖ បទរំលោភលើទំនុកចិត្ត

**អង្គហេតុ**

លោក **ក** ជាអ្នករត់តាក់ស៊ីម្នាក់បានសុំមេតុងទីន **ខ** លេងតុងទីនក្បាល២០០ដុល្លារអាមេរិក ចំនួន២ក្បាល ហើយសមាជិកសរុបទាំងអស់៦៥នាក់។ ដោយជាអ្នកស្រុកភូមិជាមួយគ្នា ហើយមេតុងទីនយល់ថាលោក **ក** មានជីវភាពធូរធារអាចលេងតុងទីននេះបាន មេតុងទីនក៏អនុញ្ញាតឱ្យលេងក្នុងតុងទីននោះដែរ។ នៅខែដំបូងលោក **ក** បានបង់ប្រាក់ដំបូងឱ្យមេតុងទីនជាធម្មតា ដោយមិនមានការយឺតយ៉ាវអ្វីនោះទេ។ នៅខែទី២ និងទី៣ លោក **ក** បានដេញតុងទីនទាំងពីរក្បាលរបស់ខ្លួន ហើយទទួលបានប្រាក់សរុប ចំនួន១៥,៣២០ដុល្លារអាមេរិក។ ក្នុងនោះដែរ មេតុងទីនក៏បានធ្វើកិច្ចសន្យាប្រគល់-ទទួលប្រាក់ជាមួយលោក **ក** ដើម្បីទុកធ្វើជាភស្តុតាងសម្រាប់ថ្ងៃមុខដែរ។ លោក **ក** បានយកប្រាក់នោះទិញរថយន្តមួយគ្រឿង និងនៅសល់ប្រាក់មួយចំនួនទៀតពីការដេញតុងទីននោះ សម្រាប់ចាយវាយប្រចាំថ្ងៃ។ ក្រោយពីនោះមក ក៏ឈានមកដល់រដូវកាលកូវីដ-១៩ ធ្វើឱ្យចំណូលរបស់គាត់មានការថយចុះ និងថែមទាំងជំពាក់បំណុលគេគ្រប់ទិស ហើយគ្មានប្រាក់គ្រប់គ្រាន់សម្រាប់បង់ការប្រាក់ និងបង់តុងទីនឱ្យមេតុងទីនទៀតផង។ ដោយគ្មានប្រាក់បែបនេះ លោកក៏មានគំនិតចង់ឈប់បង់តុងទីនតែម្តង។ លោកគិតថាបើនៅស្រុកទៀត មេតុងទីននឹងមកទារប្រាក់តុងទីនរាល់ថ្ងៃជាមិនខាន។ លុះស្អែកឡើងក៏លេចឮដំណឹងថា លោក **ក** បានរត់ចោលស្រុកមិនដឹងជាទៅទីណានោះទេ។ ដំណឹងនេះធ្វើឱ្យមានការផ្អើល ទៅដល់មេតុងទីន និងកូនតុងទីនឯទៀត ដែលលេងតុងទីនជាមួយលោក **ក** ព្រោះខ្លាចមេតុងទីនរត់ចោលស្រុកដែរ។

**កំណែលំហាត់អនុវត្ត**

លោក **ក** ជាអ្នករត់តាក់ស៊ី បានលេងតុងទីនក្បាល២០០ដុល្លារអាមេរិក ចំនួន២ក្បាល។ បន្ទាប់ពីបានដេញតុងទីនទាំងពីរក្បាលរបស់ខ្លួនបានប្រាក់សរុប១៥៣២០ដុល្លារអាមេរិករួចហើយ ចំណូលមានការធ្លាក់ចុះដោយសាររដូវកូវីដ-១៩ លោកមានគំនិតឈប់បង់តុងទីន។ នៅថ្ងៃបន្ទាប់ក៏មានដំណឹងថា លោកបានរត់ចោលស្រុកមិនដឹងជាទីដល់ទីណានោះទេ។

តើមេតុងទីនអាចប្តឹងអំពើរបស់លោក **ក** ជាបទរំលោភលើទំនុកចិត្តដែរ ឬទេ?

យោងទៅតាមមាត្រា៣៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ញត្តថា "**អំពើរំលោភលើទំនុកចិត្ត គឺជាតែបំបាត់មូលនិធិ តម្លៃឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍ អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបាន**

**ប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់"។**

ដោយផ្អែកទៅតាមអង្គហេតុខាងលើ បន្ទាប់ពីទទួលបានប្រាក់តុងទីនគ្រប់ចំនួនហើយ លោក **ក** ចាប់ល្មើស ចាប់ផ្តើមមានគំនិតទុច្ចរិតឈប់បង់ប្រាក់ ហើយគំនិតទុច្ចរិតនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈការរត់ចោលស្រុក មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់តុងទីនបន្តទៅទៀត។ ក្នុងករណីនេះ សូមលម្អិតទៅលើសកម្មភាពនីមួយៗ របស់លោក **ក**៖

**ទី១.** លោក **ក** បាន**តែបំបាត់**ប្រាក់តុងទីន ដែលគាត់ដេញបាននោះពីមេតុងទីន ហើយគាត់មិនបន្តបង់ប្រាក់តុងទីនឱ្យមេតុងទីនបន្តទៀត។

**ទី២.** លោក **ក** បានតែបំបាត់**មូលនិធិ**តុងទីន ដែលគាត់ដេញបានចំនួន ១៥៣២០ដុល្លារអាមេរិក ពីមេតុងទីន ហើយប្រាក់នេះមេតុងទីនប្រមូលបានពីកូនតុងទីនឯទៀត។

**ទី៣.** មេតុងទីន និងកូនតុងទីនឯទៀត បាន**បាត់បង់ផលប្រយោជន៍**ពីការប្រព្រឹត្តរបស់លោក **ក**។ មេតុងទីនត្រូវទទួលបង់ប្រាក់ជំនួសលោក **ក** រីឯកូនតុងទីនឯទៀតខាតបង់ប្រាក់ ដែលបានបង់កន្លងមកឱ្យលោក **ក** តាមរយៈមេតុងទីន។

**ទី៤.** មេតុងទីនបានប្រគល់ប្រាក់តុងទីនគ្រប់ចំនួនឱ្យលោក **ក** ដោយ**ស្ម័គ្រចិត្ត និងស្របច្បាប់**តាមលក្ខន្តិកៈតុងទីន ក្រោមកិច្ចសន្យាអាណត្តិក្នុងការលេងតុងទីននេះ។

**ទី៥.** លោក **ក** ដឹងថា**គាត់មានកាតព្វកិច្ចត្រូវបង់ប្រាក់តុងទីនបន្តទៀត** បន្ទាប់ពីបានដេញរួចហើយ តែគាត់មានចេតនាគេចវេសពីការបង់ប្រាក់តុងទីន ដែលស្តែងចេញតាមរយៈការរត់គេចខ្លួន។

ផ្អែកតាមការវិភាគខាងលើនេះ យើងសង្កេតឃើញថា រាល់ធាតុផ្សំនៃបទល្មើសរំលោភលើទំនុកចិត្តត្រូវបានបំពេញ។ ដូច្នេះ អំពើរបស់លោក **ក** ខាងលើជាបទល្មើសរំលោភលើទំនុកចិត្ត ដែលអាចឱ្យមេតុងទីនប្តឹងគាត់ពីបទល្មើសព្រហ្មទណ្ឌបាន។ បទរំលោភលើទំនុកចិត្តនេះជាបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ១,000,000 (មួយលាន) រៀល ទៅ៦,000,000 (ប្រាំមួយលាន) រៀល។

### **កថាភាគទី២៖ បទឆបោក**

**អង្គហេតុ**

កាលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ឈ្មោះ **ក** ដែលជាមេតុងទីនបានបបួល លោក **ខ**, អ្នកស្រី **គ**, កញ្ញា **ឃ**, លោក **ង**, លោក **ច**, កញ្ញា **ឆ** និងសមាជិកតុងទីនផ្សេងទៀតលេងជាមួយខ្លួនចំនួន ៣ខ្សែ ដូចតទៅ៖

**១- តុងទីនខ្សែទី១៖** មានចំនួន៥១ក្បាល ក្នុងមួយក្បាលតម្លៃ ២០០ដុល្លារអាមេរិក ដោយចាប់ផ្តើមលេងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ នឹងត្រូវបញ្ចប់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដោយដេញមួយខែម្តង។

**២- តុងទីនខ្សែទី២៖** មានចំនួន៦៦ក្បាល ក្នុងមួយក្បាលតម្លៃ ២០០ដុល្លារអាមេរិក ដោយចាប់ផ្តើមលេងពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៦ នឹងត្រូវបញ្ចប់នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ដោយដេញមួយខែម្តង។

**៣- តុងទីនខ្សែទី៣៖** មានចំនួន៥៦ក្បាល ក្នុងមួយក្បាលតម្លៃ៣០០ដុល្លារអាមេរិក ដោយចាប់ផ្តើមលេងពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ នឹងត្រូវបញ្ចប់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ ដោយដេញមួយខែម្តង។

ពេលលេងចាប់ផ្តើមលេងដំបូងមិនសូវជាមានបញ្ហាអ្វីឡើយ។ ក្រោយមកមានព័ត៌មានថា សមាជិកតុងទីនខ្លួនដេញហើយ តែមេតុងទីនមិនបានប្រគល់លុយគ្រប់ចំនួនទៅឱ្យសមាជិកតុងទីនដេញបាននោះទេ។ លុះមកដល់ឆ្នាំ២០១៨ មេតុងទីនបានប្រកាសថាតុងទីនទាំងបីខ្សែ ដែលខ្លួនបានធ្វើមេតុងទីននោះខូចអស់ហើយ ដោយគ្មានមូលហេតុត្រឹមត្រូវ។ ចំពោះសមាជិកតុងទីន ដែលមិនទាន់ងាប់នោះ មេតុងទីនបានបង់ឱ្យតែពីរទៅបីខែដំបូងប៉ុណ្ណោះ។ ក្រោយមកមេតុងទីនមិនព្រមបង់ប្រាក់ឱ្យទៅកូនតុងទីនតាមការសន្យានោះទេ ហើយដោយមានការសង្ស័យ លោក **ខ** បានសាកសួរសមាជិកតុងទីនដទៃទៀត ទើបដឹងថាសមាជិកតុងទីនខ្លះមានតែឈ្មោះ ដែលជាតុងទីនខ្មោច មេតុងទីនចេះតែដាក់ដើម្បីភូតកុហក និងបញ្ឆោតឱ្យកូនតុងទីនផ្សេងទៀតលេងជាមួយខ្លួន។

ជាក់ស្តែងសមាជិកតុងទីនឈ្មោះ **ឆ** ត្រូវបានមេតុងទីនដាក់ថាលេងតុងទីនក្បាល២០០ដុល្លារអាមេរិក ជាមួយ ហើយបានដេញរួចហើយ ប៉ុន្តែការពិតឈ្មោះ **ឆ** មិនបានលេងតុងទីនក្បាលនោះទេ ហើយគាត់ក៏មិនបានដេញតុងទីននោះដែរ។

**កំណែលំហាត់អនុវត្ត**

កាលពីឆ្នាំ២០១៥ ដល់២០១៦ ឈ្មោះ **ក** ដែលជាមេតុងទីនបានបបួលជនរងគ្រោះចំនួន០៦នាក់ លេងតុងទីន៣ខ្សែ។ ពេលចាប់ផ្តើមលេងដំបូងមិនសូវជាមានបញ្ហាអ្វីកើតឡើងឡើយ។ ក្រោយមកមានព័ត៌មានថា សមាជិកតុងទីនខ្លួនដេញហើយ តែមេតុងទីនមិនបានប្រគល់លុយគ្រប់ចំនួនទៅឱ្យសមាជិកតុងទីនដែលដេញបាននោះទេ។ លុះដល់ឆ្នាំ២០១៨ មេតុងទីនបានប្រកាសថាតុងទីនទាំងបីខ្សែនោះខូចអស់ហើយ ដោយគ្មានមូលហេតុត្រឹមត្រូវ។ ដោយមានការសង្ស័យកូនតុងទីនម្នាក់បានសួរសមាជិកតុងទីនដទៃទៀត ទើបដឹងថាសមាជិកតុងទីនខ្លះមានតែឈ្មោះ ប៉ុន្តែការពិតឈ្មោះនោះជាឈ្មោះខ្មោច ដែលមេតុងទីនចេះតែដាក់ដើម្បីភូតកុហក និងបោកបញ្ឆោតសមាជិកតុងទីនផ្សេងទៀតឱ្យលេងតុងទីនជាមួយ។ ជាក់ស្តែងសមាជិកតុងទីនឈ្មោះ **ឆ** ត្រូវបានមេតុងទីនដាក់ថាលេងតុងទីនក្បាល ២០០ដុល្លារអាមេរិកជាមួយ ហើយបានដេញរួចហើយ ប៉ុន្តែការពិតឈ្មោះ **ឆ** មិនបានលេងតុងទីនក្បាលនោះទេ ហើយគាត់ក៏មិនបានដេញតុងទីននោះដែរ។

ចូរពន្យល់ពីធាតុផ្សំនៃបទល្មើសខាងលើ។

**១.ធាតុនីត្យានុកូល**

យើងតាមមាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តថា "**អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬ**

**នីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬតតិយជននូវ៖**

**១- ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ**

**២- ការផ្តត់ផ្គង់សេវា**

**៣- ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។"**

**២.ធាតុសត្យានុម័ត**

ដាក់ស្តែងមេតុងទីនបានបោកបញ្ឆោតកូនតុងទីន ដោយបន្លំឈ្មោះតុងទីនឈ្មោះ ជ ដាក់ថាលេងតុងទីនក្បាល ២០០ដុល្លារអាមេរិកជាមួយ ហើយបានដេញរួចហើយ។ ការពិតឈ្មោះ ជ មិនបានលេងតុងទីនក្បាលនោះទេ ហើយគាត់ថាក៏មិនបានដេញតុងទីននោះដែរ។ បើយើងពិនិត្យឱ្យបានលម្អិត មេតុងទីនមានគំនិតបោកបញ្ឆោតកូនតុងទីនឱ្យលេងតុងទីនជាមួយខ្លួន ដោយដាក់ឈ្មោះតុងទីនក្លែងក្លាយ ដើម្បីឱ្យឃើញសមាជិកមានច្រើននាក់ ប៉ុន្តែការពិតតុងទីននោះជាតុងទីនគ្មានអ្នកលេង (តុងទីនខ្មោច) សោះ។

មេតុងទីនក្លែងឈ្មោះតុងទីនបែបនេះ គឺក្នុងគោលបំណងប្រមូលប្រាក់ពីតុងទីនក្លែងឈ្មោះនោះ។ អ្វីដែលសំខាន់មេតុងទីនបានទទួលប្រយោជន៍ជាប្រាក់ពីការធ្វើបែបនេះ គឺតាមរយៈការដេញយកតុងទីន ដែលដាក់ឈ្មោះអ្នកដទៃ ហើយដេញយកខ្លួនឯងនោះ។ បន្ថែមពីនេះទៀត មេតុងទីនធ្វើបែបនេះ ដើម្បីឱ្យសមាជិកតុងទីនផ្សេងទៀតលេងជាមួយខ្លួន ដោយបន្លំភ្នែកកូនតុងទីនថា តុងទីនខ្លួនមានអ្នកលេងច្រើន និងគួរឱ្យទុកចិត្តបាន។

**៣. ធាតុអត្តនោម័ត**

មេតុងទីនរូបនេះមានចេតនាយ៉ាងច្បាស់លាស់ក្នុងការបន្លំសមាជិកតុងទីនរបស់ខ្លួនឱ្យជឿថា តុងទីនរបស់ខ្លួនមានសមាជិកគ្នាច្រើន ហើយសូម្បីតែនៅពេលមានបញ្ហា មេតុងទីនក៏ឆ្លើយយករួចខ្លួនថា តុងទីនខ្លួនខូចអស់ហើយ។ ចេតនានេះបង្ហាញឱ្យឃើញតាមរយៈកូនតុងទីនតែងតែបង់ប្រាក់ឱ្យមេតុងទីនបានគ្រប់ចំនួន តែមេតុងទីនបែរជាប្រគល់ឱ្យអ្នកដេញបានមិនគ្រប់ចំនួនទៅវិញ ហើយចុងក្រោយក៏ប្រកាសថាតុងទីនខូចអស់ហើយ។ នៅពេលដែលត្រូវបង់តុងទីន ខ្លួនក៏មិនបង់តុងទីនក្លែងក្លាយនោះដែរ ហើយថែមទាំងថា តុងទីននោះខូចអស់ហើយ។

ឆ្លងកាត់ការបកស្រាយខាងលើ យើងសង្កេតឃើញថាអំពើរបស់មេតុងទីនពិតជាបំពេញនូវធាតុផ្សំបទល្មើសឆបោកប្រាកដមែន។ បទល្មើសឆបោកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១,០០០,០០០ (មួយលាន)រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន)រៀល។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយអំពីការទទួលខុសត្រូវក្នុងតុងទីនខាងលើ យើងប្រាកដជាបានទទួលនូវចំណីនៃចំណេះដឹងថ្មីមួយទៀត ដោយកាលពីមុនយើងអាចនឹងធ្លាប់គិតថាតុងទីនមិនមានបទដ្ឋានគតិយុត្តណាមកមានអានុភាពគ្រប់គ្រងបានឡើយ។ ការទទួលខុសត្រូវ ជាយន្តការមួយដ៏ប្រពៃក្នុងការធានាឱ្យការប្រព្រឹត្តទៅរបស់តុងទីនប្រកបដោយសុវត្ថិភាព និងមានទំនុកចិត្តចំពោះគ្នាទៅវិញទៅមកផងដែរ។ តុងទីនត្រូវចាត់ទុកជាកិច្ចសន្យាដែលយកបុគ្គលជាធំ ព្រោះការយកបុគ្គលជាធំជាគំនិតយ៉ាងសំខាន់ ក្នុងការទុកចិត្តគ្នាទៅវិញទៅមកហើយវាក៏បានធ្វើអោយតុងទីននេះមានសុវត្ថិភាព និងជោគជ័យទៀតផង។ ក្នុងការលេងតុងទីន តុងទីនខ្លះត្រូវបានបញ្ចប់ដោយជោគជ័យ ព្រោះមានការសហការគ្នារវាងកូនតុងទីនទាំងអស់ដោយមានទំនួលខុសត្រូវទៅវិញទៅមក ឯតុងទីនខ្លះទៀតបញ្ចប់ដោយរំលាយតុងទីនមុនអាយុកាលដោយសារតែកើតឡើងបញ្ហាមួយចំនួនដូចជា កូនតុងទីនមួយចំនួនមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬក្នុងករណីមួយទៀតគឺ មេតុងទីនបានរត់គេចខ្លួន។

ការទទួលខុសត្រូវរបស់សមាជិកតុងទីនអាចជាការទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី ឬអាចជាការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ។ ក្នុងរឿងរដ្ឋប្បវេណី តុងទីនស្ថិតនៅក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា ដោយសារតែតុងទីនជាកិច្ចសន្យារួចទៅហើយ ម្យ៉ាងទៀតបើនិយាយពីរឿងកិច្ចសន្យាច្បាស់ជាទាក់ទងទៅនឹងរឿងរដ្ឋប្បវេណីហើយ។ ជាទូទៅគូភាគីសន្យាគ្នាថានឹងអនុវត្តកាតព្វកិច្ចក្នុងពេលកំណត់ណាមួយ ហើយនៅពេលដល់កាតព្វកិច្ចគូភាគីត្រូវតែអនុវត្ត។ ការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាវានឹងផ្តល់ព្យសនកម្មដោយផ្ទាល់ទៅលើជនរងគ្រោះ ដោយហេតុថាជនរងគ្រោះជាអ្នកចូលរួមក្នុងតុងទីនដែរ បើមានការមិនអនុវត្តកាតព្វកិច្ច វានឹងធ្វើឱ្យប៉ះពាល់ដល់អ្នកចូលរួមទាំងនោះ។ ក្នុងករណីខ្លះ សមាជិកតុងទីនមានការទទួលខុសត្រូវដល់ផ្នែកព្រហ្មទណ្ឌ ដែលក្នុងផ្នែកព្រហ្មទណ្ឌនេះ យើងសង្កេតឃើញថាមានបទល្មើសពីរ ដែលមេតុងទីន និងកូនតុងទីនអាចត្រូវបានចោទប្រកាន់ដោយតុលាការ គឺបទឆបោក ឬបទរំលោភលើទំនុកចិត្ត។ បទល្មើសទាំងពីរនេះជាបទមជ្ឈិម ដែលមានចរិតលក្ខណៈជាការដកហូតទ្រព្យសម្បត្តិពីជនរងគ្រោះដោយមធ្យោបាយទុច្ចរិត។ ជាពិសេសជនល្មើសមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនេះ ដែលខុសពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចុងចម្លើយមិនមានចេតនាក្នុងការមិនអនុវត្តនោះទេ ប៉ុន្តែដោយសារតែខ្លួនមិនអាចអនុវត្តកាតព្វកិច្ចបានដូចជាអលទ្ធភាព ឬអនុវត្តកាតព្វកិច្ចយឺតយ៉ាវជាអាទិ៍។ នៅក្នុងការអនុវត្តជាក់ស្តែងក៏យើងសង្កេតឃើញថាតុលាការចោទប្រកាន់មេតុងទីន ឬកូនតុងទីនពីបទល្មើសព្រហ្មទណ្ឌ ដែលយើងអាចឃើញតាមការផ្សព្វផ្សាយរបស់បណ្តាញសារព័ត៌មាន ឬបណ្តាញសង្គមជាដើម។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សា ស្រាវជ្រាវលើប្រធានបទស្តីពីតុងទីនរួចហើយមកបានបង្ហាញឱ្យឃើញថាតុងទីនជាប្រធានបទមួយ ដែលកង្វះនូវឯកសារគតិយុត្ត ដោយសារតែត្រូវផ្សេផ្សំលិខិតបទដ្ឋានគតិយុត្តនានាយកមកអនុវត្តទៅលើការលេងតុងទីននេះ។ ជាមួយគ្នានេះដែរ ការស្រាវជ្រាវ និងចងក្រងឯកសារពាក់ព័ន្ធនឹងការលេងតុងទីននៅកម្ពុជាយើងក៏មិនទាន់មានភាពទូលំទូលាយដែរ ព្រោះនៅមានកម្រិតតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងបទដ្ឋានគតិយុត្ត ឬប្រធានបទ ដែលអនុវត្តជាប្រចាំដូចតុងទីនដែរនោះ។ ហេតុនេះហើយបានជាយើងខ្ញុំខិតខំស្រាវជ្រាវ និងចងក្រងនូវប្រធានបទនេះ សម្រាប់ជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋទូទៅក្នុងការស្វែងយល់ជាគំនិតបន្ថែមពាក់ព័ន្ធនឹងលិខិតបទដ្ឋាគតិយុត្ត ដែលអាចយកទៅអនុវត្តលើការលេងតុងទីនបាន។

នាពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋ អ្នកធ្វើការ អាជីវករតាមផ្សារ ពិតជានិយមលេងតុងទីនណាស់។ ពេលខ្លះអ្នកលេងតុងទីនចូលរួមលេង ឬដេញថ្លៃដោយគ្មានការចុះកិច្ចសន្យាទៀតផង ដែលនេះនឹងក្លាយទៅជាហានិភ័យនៅពេលមានបញ្ហាក្នុងការលេងតុងទីន។ យើងទាំងអស់គ្នាបានដឹងហើយថា តុងទីនដែលមានហានិភ័យខ្ពស់ គឺកើតឡើងដោយសារតែទុកចិត្តគ្នាពេក ដែលស្តែងចេញតាមរយៈការលេងដោយមិនមានធ្វើជាកិច្ចសន្យាលាយលក្ខណ៍អក្សរ ដល់ចុងក្រោយអ្នកដែលទុកចិត្តនោះហើយ ដែលបង្កជាបញ្ហាដល់សមាជិកតុងទីនឯទៀត។ ក្នុងន័យនេះ អ្នកលេងតុងទីនគួរតែចងក្រងកិច្ចសន្យាលេងតុងទីនជាលាយលក្ខណ៍អក្សរ ដោយចែងអំពីលក្ខន្តិកៈឱ្យបានត្រឹមត្រូវមុននឹងលេង ដើម្បីជៀសវាងនូវបញ្ហានានាក្នុងការលេង និងយកលក្ខន្តិកៈតុងទីននោះជាគោលក្នុងការដោះស្រាយវិវាទ។ មិនតែប៉ុណ្ណោះ នៅពេលដែលកូនតុងទីនដេញតុងទីនបាន មេតុងទីនក៏គួរតែធ្វើកិច្ចសន្យាប្រគល់ទទួលប្រាក់តុងទីនជាមួយកូនតុងទីនដែលអាចបញ្ជាក់ថា មេតុងទីនពិតជាបានប្រគល់ប្រាក់ឱ្យកូនតុងទីនបន្ទាប់ពីប្រមូលបានពីកូនតុងទីនឯទៀត ដែលដេញមិនបាន ហើយកូនតុងទីនដែលដេញបាននោះពិតជាទទួលបានប្រាក់ពីមេតុងទីនមែន។

ប្រសិនបើអ្នកលេងតុងទីនមានការចងក្រងនូវកិច្ចសន្យា និងមានសាក្សីក្នុងការលេងតុងទីនឱ្យបានត្រឹមត្រូវ ទោះជាមានបញ្ហាមិនអនុវត្តកាតព្វកិច្ច ក៏មេតុងទីន ឬកូនតុងទីននោះ នៅតែមានទំនួលខុសត្រូវចំពោះមុខកូនតុងទីន ឬមេតុងទីន និងជាពិសេសទំនួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ឯកសារជាលាយលក្ខណ៍អក្សរនេះជាភស្តុតាងដ៏រឹងមាំសម្រាប់ដាក់ជូនតុលាការពិនិត្យ និងវិនិច្ឆ័យតាមការទាមទាររបស់ដើមចោទ ឬជនរងគ្រោះ ចំណែកឯសាក្សីបំភ្លឺរឿងហេតុ ដើម្បីឱ្យកាន់តែតុលាការជឿជាក់បន្ថែមទៀត។ ផ្ទុយទៅវិញ បើមិនមានឯកសារជាលាយលក្ខណ៍អក្សរ ឬសាក្សីនឹងធ្វើឱ្យមានភាពលំបាកក្នុងការអះអាងអំពីសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការណាស់ ដោយសារតែយើងកង្វះនូវភស្តុតាងរឹងមាំអាចឱ្យតុលាការជឿជាក់នូវការទាមទាររបស់យើង។

# ឯកសារយោង

# ឯកសារយោង


### ១.វចនានុក្រម

- សម្តេចព្រះសង្ឃរាជ ជួនណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៨។
- **Oxford Dictionary of English.**

### ២.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ច្បាប់គុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤។
- ក្រឹត្យ-ច្បាប់ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ ៣៨ក្រ.ច, ២៨ តុលា ១៩៨៨។
- សេចក្តីណែនាំរួមស្តីពីការអនុវត្តមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, លេខ ០២ កយសណន/០៥, ០៨ សីហា ២០០៥។

### ៣.សៀវភៅ

- ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. ២០១៣. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ . ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។
- ញឹក វុឌ្ឍី. គ្មានកាលបរិច្ឆេទ. នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត. ២០១៤. នីតិព្រហ្មទណ្ឌពិសេស. បទបង្ហាញសម្រាប់ថ្នាក់បរិញ្ញបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លី វ៉ុង. ២០១៨. គុងទីន. ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ។
- អ៊ុក វណ្ណារ័ត្ន.២០១៧. នីតិកាតព្វកិច្ច. ភ្នំពេញ៖ អឹម ឌី អេ។

### ៤.ឯកសារពិភាក្សា

- រឿងក្តីអំពីការរំលោភលើទំនុកចិត្តៈ ការអនុវត្តដោយមិនត្រឹមត្រូវ និងឥទ្ធិពលរបស់វាមកលើ សេដ្ឋកិច្ចកម្ពុជា. ឯកសារពិភាក្សាវិស័យឯកជនលេខ២៣, សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC), ភ្នំពេញ។

### ៥.ព្រឹត្តិបត្រ

- សួន វិសាល. ២០១២. ការប្រៀបធៀបបទល្មើសរំលោភលើទំនុកចិត្ត និងបទល្មើសឆបោក. ព្រឹត្តបត្រមេធាវី លេខ ៦៖ ទំព័រទី១-ទំព័រទី៨។

**៦.គេហទំព័រ**


- លី វិទ្យា. (២០១៨). មេ និងកូនគុងទីនអាចប្រឈមបទល្មើស២នេះ បើហ៊ានធ្វើស៊ី. ដកស្រង់ចេញពី https://khmerpostasia.com/archives/3246 ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៨។

# ឧបសម្ព័ន្ធ

# តារាងបញ្ជីឧបសម្ព័ន្ធ

| ឧបសម្ព័ន្ធ | បរិយាយ |
|---|---|
| ឧបសម្ព័ន្ធទី១ | ច្បាប់តុងទីន, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤។ |
| ឧបសម្ព័ន្ធទី២ | សេចក្ដីណែនាំរួមស្ដីពីការអនុវត្តមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, លេខ ០២ កយស ណន/០៥, ០៨ សីហា ២០០៥។ |
| ឧបសម្ព័ន្ធទី៣ | សាលក្រមសាលាដំបូងខេត្តតាកែវ, លេខៈ ០៦ "ខ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។ |
| ឧបសម្ព័ន្ធទី៤ | សាលក្រមសាលាដំបូងខេត្តតាកែវ, លេខៈ ៨៦ "ង" ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨។ |
| ឧបសម្ព័ន្ធទី៥ | សាលដីកាសាលាឧទ្ធរណ៍, លេខ៖ ១៧ "ក្រ V ទល" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។ |
| ឧបសម្ព័ន្ធទី៦ | ដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួន, លេខ២៨ ដកឱ/២០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០។ |
| ឧបសម្ព័ន្ធទី៧ | លិខិតផ្ទេរសិទ្ធិ (តុងទីន) |

# ឧបសម្ព័ន្ធទី១

## ច្បាប់ភូមិបាល, លេខ ៨៦៥ នស, ២៧ ឧសភា ១៩៥៤

# ច្បាប់តុងទីន

ព្រះរាជក្រមលេខ ៤៦៥ – ន ស. ចុះថ្ងៃ ២៧-៨-៥៤

មាត្រា មួយ – ព្រះរាជក្រមនេះ មាន គោលបំណង ដើម្បីបង្ក្រាប សេចក្ដីដែលគ្មាន ក្នុងអនុសញ្ញា នៃការ ទុកសម្រាប់ ជំរះទូទៅ រឺកិច្ចការ ដែលអាច នឹងកើតឡើង បាន នៅវេលា ដែលតុងទីន កំពុងនៅរស់ ឬ ដែលត្រូវជំរះ តុងទីន ឲ្យផុះស្រឡះ ។ ការ៍ មាន សេរីភាព នឹងធ្វើ អនុសញ្ញា ណាមួយ ផ្សេង ពីបទបញ្ញត្តិ នៃព្រះរាជក្រម នេះកំបាន ។

មាត្រា ២ – មាត្រា ១៨, ១៦, ២២, ២៧, នឹង ២៨ នៃព្រះរាជក្រម នេះ អធិប្បាយ ពីបទល្មើស ជាអាទិ៍ ដែលគួរ ឲ្យផ្ដន្ទា ទោស បណ្ដាល មក ពីតុងទីន នេះ ។

មាត្រា ៣ – តុងទីន ជាកិច្ចសន្យា មួយ ដែលបង្កើតឡើង ដោយមេតុងទីន នឹង សមាជិក តុងទីន ពី ២ រូប ឡើងទៅ មេតុងទីន នឹង កូនតុងទីនម្នាក់ៗ ត្រូវមាន ហ៊ុន ឬ ចំណែក យ៉ាងតិច មួយ ហ៊ុន ម្នាក់ ។

ហ៊ុន នីមួយ ៗ ត្រូវមាន តម្លៃ ស្មើគ្នា ជារាល់ខាង ។ កូនតុងទីន ម្នាក់ ៗ ព្រមទាំង មេតុងទីន អាច មាន ហ៊ុន ច្រើន បាន ។

មាត្រា ៤ – តម្លៃ ហ៊ុន មួយ គុណ នឹងចំនួន ហ៊ុនទាំងអស់ បាន ជាទុន នៃតុងទីន ។ ហ៊ុន នីមួយ ៗ ដកយក ទុន បាន តែម្ដង ទេ ។

ខ្លះ ឬ ការចេញ កុងទីន ត្រូវចេញ ច្រើនជាន់ ស្មើនឹងចំនួន ហ៊ុន ។

មាត្រា ៥- កិច្ចសន្យា នៃកុងទីន មាន កំណត់យ៉ាងនេះ :

១- ឈ្មោះ មេកុងទីន

២- ឈ្មោះ កូនកុងទីន

៣- ចំនួន ហ៊ុន

៤- ដំរៃ ហ៊ុន នីមួយៗ ព្រមទាំង ដំរៃ ទុន នៃកុងទីន

៥- ចំនួន ចេញ ត្រូវស្មើ នឹងចំនួន ហ៊ុន

៦- កាលបរិច្ឆេទ ត្រូវចេញ , ទីកន្លែង ត្រូវចុះ ព្រមទាំង បែបបទ ទាំងឡាយ ។

មាត្រា ៦- ចំប្រែង មិនទៀងត្រង់ នៃកិច្ចសន្យា ត្រូវទុក ជាភស្តុតាង តាមច្បាប់ សាធារណៈ ។

មាត្រា ៧- អ្នកមាន ហ៊ុន មួយៗ ដែល ចេញ កុងទីន បាន ត្រូវហៅថា « អ្នកចេញបាន » ;

និក្ខេប នៃកុងទីន

មាត្រា ៨- នៅពេល ចេញ ប្លង់ ១ កូនកុងទីន ត្រូវមាន ព្រាក់ ស្មើ នឹងចំនួន ហ៊ុន ដែល ខ្ទង់ គេ ទុកប្រគល់ឲ្យ មេកុងទីន ។ មេស- តកម្ម នៃមេកុងទីន ត្រូវប្រមូល ទេ , តាមតែ ឲ្យចេញ និងប្រគល់

ប្រាក់ឲ្យទៅ អ្នកដេញបាន ។

មាត្រា ៩– បេក្ខជន មានសិទ្ធិ ត្រូវដក ខ្លួន ទៅចោលការ ដេញ លើកដំបូង ហើយត្រូវបាន ខុនតាំងមូល , កាលបើបាន ហ៊ុន ច្រើន បេក្ខជន មិនទៅ ជាអ្នកដេញបាន គ្រប់ ៗ ពេល តាមដែលខ្លួន នៅ បាន ហ៊ុន មិនទាន់ ដេញ បាន នៅ ឡើយ ។

មាត្រា ១០– ពេល ដេញ ជាបន្ទាប់ មកទៀត អ្នក ដែលបាន ហ៊ុន ហើយ មិនទាន់ ដេញ បាន នៅឡើយ ត្រូវចូលដេញ ; អ្នក ដែល បាន ហ៊ុន មួយ ឬ ហ៊ុន ច្រើន ហើយ ដេញ បាន អស់ហើយ មិនត្រូវ ចូល ដេញ ទៀត ឡើយ ។

មាត្រា ១១– អំពីការចូលដេញ, អ្នក ដែលបាន ហ៊ុន ហើយ មិនទាន់ ដេញ បាន នៅឡើយ ត្រូវសុំ ឲ្យ ការ ដល់កូនក្ខជន ឯទៀតៗ

អ្នកដេញ នោះ សុំយកខុន ដោយដាក់ ការ ចេញ តែប៉ុណ្ណោះ តាមចិត្ត ៗ នរណា ដែលដាក់ ការ ច្រើនជាង គេ អ្នកនោះ ទុក ជា អ្នក ដេញបាន ។ បើគ្មាន សន្យា គ្នា ផ្សេង ទៅទៀត ទេ កូនក្ខជន ម្នាក់ ៗ ត្រូវប្រគល់ ក្រដាស់ បិទស្រោមឲ្យជិត មួយ ចុះ ទឹកប្រាក់ ការ ដែលខ្លួន ព្រមឲ្យ នោះ ទៅ បេក្ខជន ។ បេក្ខជនត្រូវ «បើកស្រោម» នៅ ចំពោះមុខ កូនក្ខជន ទាំងអស់ ។

មាត្រា ១២– កាលបើ នៅសល់ ហ៊ុន តែ មួយ មិនទាន់ ដេញ

ទុន នោះ, អ្នក នេះ មានសិទ្ធិ បាន ទុន ចាំងបូល មិនចាំបាច់ សុំ ឲ្យ
ការ ល្មើយ; កុងទិន ក៏ត្រូវជុះ ក្រមនេះដែរ ។

ភារកិច្ច របស់មេកុងទិន

មាត្រា ១៣– មេកុងទិន ដែលជាអ្នកកណ្ដាល គេង កូនកុងទិន ចាំងអស់ ត្រូវទទួលខុសត្រូវ ក្នុងការប្រព្រឹត្តទៅ នៃកុងទិន ។ ដូច្នេះ មេកុងទិន ត្រូវពិបាង ចេញផ្សេះ កូនដែលក្សយ មិនគ្រប់ ចេញ ប្រាក់ កាមចំណែកខ្លួន ដោយហេតុ ណាមួយ ក៏ដោយ ។

មាត្រា ១៤– ដូចការ ខ្ទះ កូនកុងទិន ឈប់សង ប្រាក់ ច្រើនញា ចាំ ឲ្យមេកុងទិន រំលាយ កុងទិន មុន កាយុ កុងទិន ។

ក្នុងរឿង បែបនេះ សិទ្ធិ របស់មេ និង កូនកុងទិន ត្រូវសំរេច ដូច មានសំដែង ក្នុងមាត្រា ៦៣ និង តទៅ នៃព្រះរាជក្រមនេះ ។

មាត្រា ១៥– ត្រូវទុក ជាបានល្មើស និងបញ្ញត្តិ នៃមាត្រា ៥១០ វគ្គទី ៦ នៃក្រមព្រហ្មទណ្ឌ (នៃ ប្រាក់ ល្មើចំនុកចិត្ត), មេកុងទិន ណា បំបាត់យក ជាប្រយោជន៍ ខ្លួន ឬ ប្រយោជន៍ អ្នកដទៃ នូវប្រាក់ ដែល ប្រមូល បាន នៅពេល ដេញ ណាមួយ ហើយមិនប្រគល់ ឲ្យទៅ អ្នក ដែលដេញបាន ។ អ្នកដទៃ ដែលទទួលយក ប្រាក់ នេះ ដោយដឹងខ្លួន ត្រូវទុក ជាបានល្មើស និងបញ្ញត្តិ មាត្រា ៥៣៦ នៃក្រមព្រហ្មទណ្ឌ ។

មាត្រា ១៦– ត្រូវទុក ជាបានល្មើស និងបញ្ញត្តិ នៃមាត្រា ៥១៥

ក្ន

វគ្គ ៣ នៃក្រមព្រហ្មទណ្ឌ (ឧក្រិដ្ឋ) មេគុកទោស ណា ដែល ឲ្យអ្នកទោស ទៀតជាក់ថា, ជាកុកទោស មួយ ក្រែមក្រៅ, ក្ដុកទោស ដែលត្រូវបានដាក់ ការពារ ផ្ទាល់ខ្លួនរបស់ៈ ឬ មិនបានតួល ក្នុងកុកទោស នោះ គេៈ ។ ក្នុងរៀងដែលនេះ អ្នកដេញបាន ជាដំបូងជាងគេ គឺជាមនុស្សខ្លួនឯង សមគំនិត ក៏វិញ គុកទោស ក្នុងការប្រើ ខុសច្បាប់ ឲ្យគេ ជឿ ថា មាន កុងទោស ក្រោយ មួយវិញ, មនុស្សនោះ ត្រូវបាន ទោស, កាលបើ គំនិតខ្លួន មាន កស្តុតាង ច្បាស់ ថាមនុស្សនោះ សមគំនិត ក្នុងបទឧក្រិដ្ឋ ដោយប្រើ ខុសច្បាប់ ដែលមាន មេគុកទោស ជាដើម ។

### ភារកិច្ច របស់កូនគុកទោស

មាត្រា ១៧– កូនគុកទោស ត្រូវតាមមើល ការវែក របស់គុកទោស, ជាពិសេស ត្រូវមើល របៀបដេញ, ដាក់ការ ជាដើម ។ កូនគុកទោស មិន ដាក់ការ នៅពេល ដេញ ណាមួយ ត្រូវទុក ជាព្រះបន្ទាល់ សិទ្ធិ របស់ខ្លួន ជាអ្នកដេញ នៅពេល ដេញ នោះ ។ សេចក្ដីនេះ មិនត្រូវ ឲ្យ មានគ្រួសារកម្ម ដល់ការដេញ ក្រោយបង្អស់ ដូចមានលក្ខណ៍ ដែលមានបញ្ញត្តិ ក្នុងមាត្រា ១៦ ដែលស្ដីថា ត្រូវបាន ប្រាក់ខ្លួន តាំងពីដើម ផុតកំណត់ ខាង ការ បន្តិច នោះ ឡើយ ។

មាត្រា ១៨– កូនគុកទោស ដែលមិនយល់ ប្រាក់ ហ៊ុន តាមចំនួន ដែលខ្លួន លើស ទៅប្រគល់ ឲ្យមេគុកទោស នៅពេល ដេញ ប្អូន ។ ទ

ត្រូវទុក ជាភៀសខ្លួន ។

មាត្រា ១៩– បើអ្នក ភៀសខ្លួន មិនទាន់ដេញ បាន ទេ អ្នក នោះត្រូវបាត់ អំណាច ជាសមាជិក ក្នុងតុងទីន ព្រមទាំងគ្មាន សិទ្ធិ ទារ តបតាប្រាក់ ដែលខ្លួន បានបង់ រួចហើយ នោះ ផង ។

អ្នកជំនួស អ្នកភៀសខ្លួន, កាបរគោលការណ៍, មេតុងទីន ឬ កូនតុងទីន ណាម្នាក់ ដែលបានព្រមព្រៀង ជាមួយ នឹងមេតុងទីន ឬ អ្នកឯទៀត ដែលមេតុងទីន នាំមកចូល នោះ, អ្នកនោះ ត្រូវ ទទួល ហ៊ុន ទាំងអស់ របស់អ្នកភៀសខ្លួន បានពេញច្បាប់ ហើយត្រូវបង់ ហ៊ុន បន្ត ពីពេល ភៀសនោះទៅ ។ អ្នកជំនួស នោះ អាច ដេញ បាន គ្រប់ តែ ហ៊ុន របស់អ្នកភៀសខ្លួន ដែល មិនទាន់ដេញ ក្នុងពេលភៀសនោះ ។

មាត្រា ២០– កូនតុងទីន អាច លក់ ហ៊ុន របស់ខ្លួន មួយហ៊ុន ឬ ទាំងអស់ ឲ្យទៅ កូនតុងទីន ម្នាក់ទៀត ឬ ឲ្យទៅ ជនដទៃ បាន គ្រប់ពេល ទាំងអស់ តែត្រូវ ឲ្យមាន សេចក្ដីព្រមព្រៀង យ៉ាងជាក់ច្បាស់ ពីមេតុងទីន ផង ។

មាត្រា ២១– អ្នកភៀសខ្លួន ដែលបានដេញ រួចហើយ, ត្រូវតែ សង ទៅ មេតុងទីន ឬ ទៅ អ្នក ដែលជំនួស ខ្លួន, នូវប្រាក់ ដែល គេ បានបេញ ជំនួសខ្លួន ថែមទាំងការ ដោយដល់ជម្ងឺចិត្ត ដែលអាច មាន ឡើង បាន ផងដែរ ។

មាត្រា ២២- កូនក្ស័យធន ណា ចេញ ក្ស័យធន បាន ដោយឲ្យការ ច្រើន ហួសពេក ហើយក្រោយមក ឈប់បង់ ប្រាក់ ចំណែកខ្លួន ទៅ, កូនក្ស័យធន នោះ ត្រូវទុក ជាបាន ល្មើស នឹងមាត្រា ៥១៥ នៃក្រមព្រហ្មទណ្ឌ (ឆបោក) ។ ទោសនេះ មិនមែន ជាទោសសត្ត ឲ្យកាន់ អនុវត្ត បទបញ្ញត្តិ នៃមាត្រា ២០ ខាងលើ នេះ ទេ ។

មាត្រា ២៣- ក្នុងរឿង រំលាយ ក្ស័យធន បុគ្គលិក ដូចមាន ចែង ក្នុងមាត្រា ១៤ នៃព្រះរាជក្រម នេះ, សិទ្ធិ របស់ម្ចាស់ក្ស័យធន និង កូនក្ស័យធន ត្រូវសម្រេច ដូចមានពោល ខាងក្រោម នេះ ។

មាត្រា ២៤- សិទ្ធិ របស់ម្ចាស់ក្ស័យធន ចំពោះកូនក្ស័យធន ដែល គៀសខ្លួនចាំងច្បាស់ ត្រូវសម្រេច តាមមាត្រា ១៨ , ១៩ , ២១ ហើយ និងមាត្រា ២២ នៃព្រះរាជក្រម នេះ ផង ដែរ ។

មាត្រា ២៥- អ្នកមិនគៀសខ្លួនចាំងច្បាស់ ដែលជាអ្នកចេញ បាន ត្រូវប្រគល់ ប្រាក់ ឲ្យម្ចាស់ក្ស័យធន គប់ចំណែក របស់ខ្លួន ដែលមាន ចែង ក្នុង មាត្រា ៣ នៃព្រះរាជក្រម នេះ ក្នុងណា និងចំនួន ពេលវេលា ដែលមិនទាន់បានចេញ ។ ឯប្រាក់ នេះ គេប្រើ ឲ្យចេញ ការតាំងលោយ ក្ស័យធន មក ។

មាត្រា ២៦-ម្ចាស់ក្ស័យធន ត្រូវសង ទៅ កូនក្ស័យធន ដែលមិនគៀស ខ្លួន ហើយពុំមែន ជាអ្នកចេញបាន នូវប្រាក់ តាមចំណែក ដែលអ្នកនោះ

បានបង់ តាំងពីដើម ឲ្យគ្រប់ ចំនួន ទៀតសោតតែ បេតុងទីន បានប្តឹង ពីកូនគុណទីន ដែលជាអ្នកចេញបាន ដូចមានពោល ក្នុងមាត្រា មុន នេះ ។

មាត្រា ២៧ – ក្រៅពីក ជាបានលើស ចំនួនបញ្ញត្តិ មាត្រា ៨១៨ វគ្គទី២ នៃក្រមព្រហ្មទណ្ឌ (តែបំបាត់ លើទំនុកចិត្ត) បេតុងទីនណា តែបំបាត់ជាប្រយោជន៍ខ្លួន ឬ ប្រយោជន៍អ្នកដទៃ នូវប្រាក់ ដែលកូនគុណទីន អ្នកចេញបាន ពីលើកមុន បានប្រគល់ មកឲ្យ ខ្លួន តាមមាត្រា ២៨ នៃព្រះរាជក្រមនេះ , មិនប្រគល់ ទៅឲ្យ កូនគុណទីន ដែលមិនទាន់ចេញបាន តាមចំនួន ប្រាក់ ដែលអ្នក ទាំងនោះ បានបង់ ចំណែក រៀងៗ ខ្លួន ។

មាត្រា ២៨– ក្រៅពីក ជាបានតាមទោស ដោយប្រើ ឧបាយកលទុច្ចរិត ដែលមានបញ្ញត្តិ ក្នុងមាត្រា ៨១៨ នៃក្រមព្រហ្មទណ្ឌ, បេតុងទីនណា ក្លែង កូនគុណទីនណាម្នាក់ ដែលជាអ្នកចេញបាន ក្នុងតុងទីន ឯណាមួយ ដោយកែច្នៃ ជា តុងទីន នោះ លោយបាន មុនកាល ទៅហើយដើម្បីឲ្យ កូនគុណទីន នោះ ប្រគល់ ប្រាក់ មកឲ្យខ្លួន តាមមាត្រា ២៨ ។

មាត្រា ២៩– បេតុងទីន ដែលលោយ តុងទីន មុនកាល ហើយទារប្រាក់ សង ផល់កូនគុណទីន តាមសុំ ដោយខ្លួនឯង ឬ ក៏ កូនគុណទីនសុំឲ្យ បិទទ្វារល្បាយល្បុង ប្រសិនបើ ខ្លួន ជាអ្នកជំពាក់ ។

មាត្រា ៣០– កូនគុណទីន ជាអ្នកជំពាក់ ហើយឈប់បង់ តុងទីនណាមួយ ដែលបង្កើតឡើង ជាក្រុមក្រៅ តាមច្បាប់ ក៏ត្រូវបង់ទារ ឲ្យ យល្បុង ដែរ

មាត្រា មួយ.- បទបញ្ញត្តិ នៃព្រះរាជក្រម លេខ ៨៦៨.នស ចុះថ្ងៃទី ២៧ ឧសភា ១៩៥៦ ត្រូវបំពេញដូចតទៅ :

មាត្រា ២.- កិច្ចសន្យាកុងទីន ដែលមានចែង ក្នុងមាត្រា ៤ និង ៦ នៃព្រះរាជក្រម លេខ ៨៦៨-នស ចុះថ្ងៃទី ២៧ ឧសភា ត្រូវធ្វើជា លិខិត សរសេរជាអក្សរ មានចុះហត្ថលេខា គូសញ្ញា ហេងប៉ុង ថែម និង ប្រថាប់ត្រា លើឯកសារ ប្រធានកុងទីន ។ ចំពោះការ នេះ បើពុំបាន បំពេញ ទេ កិច្ចសន្យាត្រូវទុក ជាមោឃៈ ជាដាច់ខាត ។ ការមិនប្រតិបត្តិ តាមចំពោះការ នេះ ប្រធាន ត្រូវមានទោស ជាបង្រៀម ចាក់ទីពីរ ដោយមិន គិត ដល់ទោស ក្នុងក្រមនៃ និង ប្រថាប់ត្រា ដែលអាច ឲ្យមាន បាន ទៀត ផង ។

មាត្រា ៣.- ត្រូវកំពីបទល្មើស ឆពោក និង នៃបំពុត ដែល មានចែង ក្នុងមាត្រា ១៨-១៦-២២.២៧ និង ២៨ នៃព្រះរាជក្រម លេខ ៨៦៨.នស ចុះថ្ងៃទី ២៧ ឧសភា ១៩៥៦ :

១- ត្រូវមានទោស បង្រៀម ចាក់ទីពីរ :

ប្រធានកុងទីន ឬ អ្នកជំនួសណា ដែលប្រធាន ផ្ទេរឈ្មោះ ទៅឲ្យ ដោយហេតុអ្វី ក៏ដោយ ដែលមិនបង់ប្រាក់ ជំនួសសមាជិក ណា ដែលមិន បានបំពេញកិច្ច នេះ ឬ មិនបង់ ប្រាក់ ទៅសមាជិក ណា ដែលបានបង់

ផលចំណែក មក ខ្លួន ហើយ ។

២- ត្រូវមានទោស ដូចគ្នា ។

សមាជិក ឬ អ្នកជំនួស ណា ដែលសមាជិក នោះ ផ្ទេរឈ្មោះ ទៅឲ្យ ដែលមិនបង់ ប្រាក់ ចំណែកខ្លួន ឬ មិនសងទៅ ប្រធាន វិញ នូវប្រាក់ ដែលខ្លួន ត្រូវទៅជំពាក់ ប្រធាន ។

មាត្រា ៤ .- ការសុំអនុញ្ញាត តាមប្រកាន់ លើអក្ខរ ដែល មានបុគ្គលិក មិន ជាការចាំបាច់ ទេ វៀរលែងតែមាន បទបញ្ញត្តិ នៃផ្ទៃ បន្ទាញ ដែលផ្ទុយ នឹងច្បាប់ នេះ ។

មាត្រា ៥ .- ដោយបញ្ញត្តិផ្ទុយ នឹង មាត្រា ៦០៦ ក្រមពិការ្យ-ព្រហ្មទណ្ឌ ហើយទោះក្នុងករណីណា ក៏ដោយ ក្នុងបទកុងទីននេះ, ការដាក់ឃុំឃាំង មនុស្សត្រូវទោស ជាការចាំបាច់ ហើយការដោះឲ្យទៅ ក្រៅឃុំ ត្រូវទុកជាសិទ្ធិ របស់មនុស្សត្រូវទោស ពេលណា មនុស្សត្រូវ ទោស បានដាក់ ប្រាក់ធានា គ្រប់ចំនួន ការបង់ប្រាក់ ដែលជំពាក់ នៅ មន្ទីរក្រឡាបញ្ជី នៃសាលាសមត្ថកិច្ច ជំនុំជំរះ ហើយ ។

មាត្រា ៦.- បទបញ្ញត្តិ ទាំងឡាយ ក្នុងព្រះរាជក្រម លេខ ៨៦៨ នស ចុះថ្ងៃទី ២៧ ខែសីហា ១៩៥៦ ដែលផ្ទុយ ឬ មិន ចុះសម្រុង នឹងបទ បញ្ញត្តិ នៃច្បាប់ នេះ ត្រូវនិរាករណ៍ ។

# ឧបសម្ព័ន្ធទី២

## សេចក្តីណែនាំរួមស្តីពីការអនុវត្តមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, លេខ ០២ កយសណន/០៥, ០៨ សីហា ២០០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

◆◆◆

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ០៤៤ ក.យ.ស.ដ.ក.ស.រ.ពអ/០៥

ភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

**សេចក្តីណែនាំរួម**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ប្រធានតុលាការកំពូល**

**សូមជំរាបមក**

- **លោកប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង**
- **លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង**

<u>កម្មវត្ថុ</u> ៖ សេចក្តីណែនាំស្តីពីការអនុវត្តមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានពិនិត្យឃើញថា ការអនុវត្តមាត្រា ៤៦ ស្តីពីអំពើរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ មិនទាន់បានឯកភាពគ្នានៅឡើយ នៅតាមតុលាការទូទាំងប្រទេស ។ម្យ៉ាងវិញទៀតចំពោះការបែងចែកវិវាទរដ្ឋប្បវេណី ដែលជាការមិនបំពេញករណីយកិច្ចកើតចេញពីកិច្ចសន្យា និងអំពើដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត កំពុងស្ថិតនៅជាបញ្ហាដែលទាមទារឱ្យមានការដោះស្រាយផងដែរ ។

ការរំលោភសេចក្តីទុកចិត្ត គឺជាអំពើគេបន្លំ ឬបំបាត់ រំលោភកាន់កាប់មួយចំណែក ឬទាំងអស់នូវទ្រព្យសម្បត្តិអ្នកដទៃ ដែលគេបានប្រគល់អោយខ្លួនអាស្រ័យដោយការជឿទុកចិត្តរបស់ម្ចាស់ទ្រព្យ ឬអ្នកកាន់កាប់ទ្រព្យដែលសង្ឃឹមថា ទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬលទ្ធផលនៃការងារណាមួយពីអ្នកទទួលនូវទ្រព្យទាំងនោះ ។

ដើម្បីជាមូលដ្ឋានសំរាប់ការចោទប្រកាន់ និងការវិនិច្ឆ័យរឿងក្តី និងការបែងចែករវាងវិវាទរដ្ឋប្បវេណី និងបទល្មើសរំលោភលើសេចក្តីទុកចិត្ត ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមធ្វើការណែនាំដល់តុលាការ និងអយ្យការខេត្ត-ក្រុង យកចិត្តទុកដាក់ ពិចារណាលើសញ្ញាណគតិយុត្ត ដែលបានបញ្ញត្តិក្នុងមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចរៀបរាប់ខាងក្រោម ។

**ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមាន៖**

១. មានច្បាប់ចែង ឧទាហរណ៍ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល



ផ្លូវសម្តេចសុធារស,ខ័ណ្ឌដូនពេញ,ក្រុងភ្នំពេញ ទូរស័ព្ទ ៖ 023.212.693 . 211.038 . 215.349 . 215.364 ទូរសារ ៖ 023 364 119

២. ជនល្មើសមានចេតនាទុច្ចរិត កែបន្លំ ឬបំបាត់ទ្រព្យដែលខ្លួនបានទទួល ពោលគឺការមិនបានប្រគល់ ឬបង្វាញនូវទ្រព្យ ឬលទ្ធផលនៃការងារកើតឡើងដោយឆន្ទៈមិនប្រគល់ពិតប្រាកដ ដែលពុំមែនកើតឡើងដោយឧបសគ្គសត្យានុម័តនោះឡើយ ហើយត្រូវមានអំពើកែបន្លំ ឬបំបាត់ទ្រព្យសម្បត្តិប្រព្រឹត្តដោយអ្នកទទួលបាននូវទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ដែលស្តែងឡើងក្រោមរូបភាពជាការមិនប្រគល់ ឬប្រគល់ តែបានបន្ថំបរិមាណ ឬគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ។

៣. សំភារៈ ឬមុខសញ្ញា នៃបទរំលោភលើសេចក្តីទុកចិត្តរួមមាន :

ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ គ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រកាសអោយដកខ្លួន ក្នុងលក្ខណៈជាការជួល ការតំកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ដែលម្ចាស់ទ្រព្យបានផ្ទុកផ្តាក់ទ្រព្យរបស់ខ្លួនអោយទៅភាគីម្ខាង ហើយភាគីម្ខាងបានទទួលទ្រព្យនេះដោយស្របច្បាប់ តាមរយៈកិច្ចសន្យាប្រាំមួយប្រភេទគឺៈ កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាអោយខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬមិនមែនរវាងនិយោជក និងកម្មករ. និយោជិត ។

៤. មានការអន្តរាយ ពោលគឺខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ដែលបានប្រគល់នូវទ្រព្យទាំងនោះ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមរំលឹក និងសូមឱ្យលោកចៅក្រម ពិចារណាឱ្យបានល្អិតល្អន់ចំពោះការមិនបានបំពេញករណីយកិច្ច ដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណីផ្សេងទៀត ក្រៅពីប្រភេទកិច្ចសន្យាទាំង ៦ ដែលបានលើកឡើងខាងលើ ដូចជាកិច្ចសន្យាលក់-ទិញ កិច្ចសន្យាខ្ចីបរិភោគ(ដូចជាកិច្ចសន្យាខ្ចីប្រាក់) កិច្ចសន្យាឱ្យ ឬប្រទានកម្ម ដែលភ្ជាប់ករណីយកិច្ច.........ទោះបីដោយមូលហេតុណាក៏ដោយ ដែលអ្នកទទួលបាននូវទ្រព្យ មិនបានបំពេញករណីយកិច្ចប្រគល់ឱ្យទៅអ្នកប្រគល់វិញ នូវទ្រព្យនោះមិនមែនជាអំពើកែបន្លំ ឬបំបាត់ ដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តនោះឡើយ ។

ការធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិតាមរយៈអំពើណាមួយ ដែលមិនរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត អាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអំពើនោះត្រូវបានចែងក្នុងច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងមានវិធានការតាមផ្លូវច្បាប់ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោកចៅក្រម នឹងយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីការពារសិទ្ធិរបស់ ពលរដ្ឋ ជួយរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋ និងអ្នកវិនិយោគលើ ប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា ។

| | |
|---|---|
| **ប្រធានតុលាការកំពូល** | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** |
| ឌិត មុន្ទី | អង្គ វង្សវឌ្ឍនា |

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការ
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

## សាលក្រមសាលាដំបូងខេត្តតាកែវ, លេខ: ០៦ "ខ"

## ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

## (រឿងក្ដីរដ្ឋប្បវេណី)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងរដ្ឋប្បវេណីលេខ:៩៦
ចុះថ្ងៃទី៣០-០៤-២០១៩
**សាលក្រមលេខ: ០៦ "ខ"**
ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

-កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់៖ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០
-កាលបរិច្ឆេទប្រកាសសាលក្រម៖ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖**

-**ដើមចោទ**៖ ឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ [redacted] អាយុ៥៧ឆ្នាំ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្នភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ។

-**ចុងចម្លើយ**៖ ឈ្មោះ [redacted] ភេទប្រុស អាយុ៦៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] អាយុ៦០ឆ្នាំ ជនជាតិខ្មែរមុខរបរសំអាងការ មានទីលំនៅបច្ចុប្បន្ននៅភូមិថ្នល់បែក ឃុំរកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

### អង្គហេតុនិងចំណុចវិវាទ

**ក.ការទាមទាររបស់ដើមចោទ**

១.ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន៩៥.៣០០ USD (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ។
២.ឱ្យចុងចម្លើយសងការប្រាក់ចំនួន ២០.០០០ USD (ពីរម៉ឺនដុល្លារអាមេរិក) ។
៣.ទាមទារការខូចខាតពេលវេលា និង ជម្ងឺចិត្តចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់ដុល្លារអារិក) ។
៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។
៥.សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

**ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទ និងចុងចម្លើយ បានលេងតុងទីនប្រចាំខែចំនួន១១ឈ្មោះ ក្នុងមួយឈ្មោះ ចំនួន២០០$ ក្នុងមួយខែដេញម្តង បន្ទាប់ពីដេញរួច គឺប្រគល់ប្រាក់ឱ្យទៅចុងចម្លើយ ហើយការប្រគល់ប្រាក់រាល់ដង គឺបានធ្វើជាលិខិតលាយលក្ខណ៍អក្សរ ។ ពេលទទួលប្រាក់ម្តងៗ ឈ្មោះ [redacted] ទទួលពីរ ឬ បីដង ប៉ុន្តែភាគច្រើនឈ្មោះ [redacted] ជាអ្នកទទួលប្រាក់ ជាមួយកូន ។ ប្រាក់ដេញតុងទីនចំនួន១១ ក្បាល នេះ ខាងចុងចម្លើយបានទទួលប្រាក់គ្រប់ចំនួនហើយ ដូចមានបញ្ជាក់ក្នុងភស្តុតាង ។ តុងទីនប្រចាំថ្ងៃចំនួន ៦០ឈ្មោះក្នុងមួយឈ្មោះចំនួន១០.០០០(មួយម៉ឺនរៀល)ដែលមានកូនចំនួន៤៤០នាក់ ដេញរៀងរាល់ថ្ងៃ ។ ចុងចម្លើយបានទទួលប្រាក់ដេញគ្រប់ចំនួន៦០ក្បាលរួចរាល់ហើយ ។

ចាប់ពីថ្ងៃដែលចុងចម្លើយ បានទទួលប្រាក់រួច ចុងចម្លើយ មិនដែលបានបង់ប្រាក់មកឱ្យខ្ញុំនោះទេ សរុបចំនួន ៩៥.៣០០ USD (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ។ ការប្រាក់ទាមទារដោយហេតុថាយកប្រាក់មកបង់ជំនួនឱ្យចុងចម្លើយ ហើយខ្លួនក៏ត្រូវបង់ការប្រាក់នេះទៅធនាគារ ។ ចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ចុងចម្លើយមិនបានបង់ប្រាក់មក ឱ្យដើមចោទនោះទេ ។

**គ.ចំណុចវិវាទ៖**

-ដូចកម្មវត្ថុនៃបណ្តឹង ត្រង់ចំណុចទី២ និងទី៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ដើមចោទ ។

**ឃ.ការអះអាងរបស់គូភាគី៖**

**ការអះអាងរបស់ដើមចោទ៖**យើងខ្ញុំទាំងពីរនាក់សូមរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ព្រមទាំងសេចក្តីថ្លែងការណ៍ និងការអះអាងទាំងអស់ ដូចដែលមាននៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។ ចាប់ពីថ្ងៃដែលចុងចម្លើយ បានទទួលប្រាក់រួច ចុងចម្លើយមិនដែលបានបង់ប្រាក់មកឱ្យខ្ញុំនោះទេ សរុបចំនួន ៩៥.៣០០ USD (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ។

**ការអះអាងរបស់សហចុងចម្លើយ៖** ឈ្មោះ [redacted] និងតំណាងឱ្យប្រពន្ធឈ្មោះ [redacted] ទទួលស្គាល់ការទាមទារលើប្រាក់ដើម ប៉ុន្តែមិនទទួលស្គាល់ការប្រាក់ទេ ដោយហេតុថាខ្លួនពុំមានលទ្ធភាពសងទេ ។

## <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា:

ក-ដើមចោទ និង ចុងចម្លើយ លេងតុងទីនជាមួយគ្នា ក្រោមរូបភាពជាការខ្ចីប្រាក់ ចំនួនពីរក្បាល ដោយទទួលបានការប្រាក់តាមការកំណត់របស់កូនបំណុល នៅពេលដេញតុងទីនម្តងៗ ចំពោះក្បាលតូច ទឹកប្រាក់ចំនួន១០.០០០(មួយម៉ឺន) រៀលចំនួន៦០ក្បាល គឺក្នុងមួយថ្ងៃដេញម្តង និងចំពោះក្បាលធំដេញក្នុងមួយខែម្តង ទឹកប្រាក់ចំនួន២០០USD(ពីររយដុល្លារអាមេរិក) ក្នុងមួយក្បាល ដែលតុងទីនចំនួនពីរក្បាលនេះបានងាប់អស់ហើយ ក្នុងអំឡុងឆ្នាំ២០១៨ ហើយប្រាក់ដែលបានដេញទាំងអស់នោះ ខាងដើមចោទបានប្រគល់ទៅឱ្យចុងចម្លើយគ្រប់ចំនួន តែនៅពេលដល់កាលកំណត់បង់ប្រាក់ត្រលប់មកវិញ ចុងចម្លើយ មិនបានបង់ប្រាក់ដែលព្រមព្រៀងនោះទេ ទុកឱ្យដើមចោទ ជាអ្នកបង់ជំនួសទៅឱ្យកូនផ្សេងៗទៀតជំនួស ខ្លួនដែលមានទឹកប្រាក់សរុប ៩៥.៣០០ USD (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ហើយដើមចោទ ក៏បានទទួលស្គាល់លើប្រាក់ដើមនេះដែរ ។

តុលាការទទួលស្គាល់ អង្គហេតុលេងតុងទីនជាកិច្ចសន្យាខ្ចីប្រាក់ ហើយចុងចម្លើយក៏បានទទួលស្គាល់ការទាមទារលើប្រាក់ដើមដែលបានជំពាក់ ផ្អែកតាមមាត្រា ៥៧៨ , ៥៩១ នៃក្រមរដ្ឋប្បវេណី ភស្តុតាងជាឯកសារសេចក្តីប្រកាសអំពីបំណុល ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ និង លិខិតប្រគល់-ទទួលប្រាក់ថ្លៃដេញតុងទីន ។

ខ-ដើមចោទទាមទារអត្រាការប្រាក់ចំនួន ២០.០០០ USD (ពីរម៉ឺនដុល្លារអាមេរិក) គឺជាការទាមទារសរុបដែលមិនអាចគណនាបានដោយផ្ទុយពីច្បាប់ ហើយភាគីបានព្រមព្រៀងគ្នាពីការប្រាក់ ដូចនេះតុលាការ

កំណត់យកអត្រាការប្រាក់តាមច្បាប់កំណត់ គឺ ៥% (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ។ ការទាមទារក្រៅពីនេះច្រានចោល តាមមាត្រា៣១៨ នៃក្រមរដ្ឋប្បវេណី ។

គ-ដើមចោទទាមទារការខូចខាតពេលវេលា និង ជម្ងឺចិត្តចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល បានធ្វើឱ្យម្ចាស់បំណុលខូចខាតពេលវេលា និងផលប្រយោជន៍ស្របច្បាស់របស់ម្ចាស់បំណុល ផ្អែកតាមមាត្រា៤០០ នៃក្រមរដ្ឋប្បវេណី ។

ឃ-ការទាមទារសុំឱ្យតុលាការចេញសាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបានរបស់ដើមចោទ ដើម្បី ការពារកុំឱ្យមានការយឺតយ៉ាវ និងខូចប្រយោជន៍ ដែលនាំឱ្យរាំងស្ទះនូវការអនុវត្តសិទ្ធិរបស់ដើមចោទស្រប តាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ង-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្តីសម្រេចបញ្ចប់**

១- បង្គាប់ឱ្យចុងចម្លើយ ឈ្មោះ [redacted] និង ឈ្មោះ [redacted] រួមគ្នាសងប្រាក់ដើមចំនួន USD ៩៥.៣០០ (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ទៅឱ្យដើមចោទ ឈ្មោះ [redacted] និងឈ្មោះ[redacted] ។

២- បង្គាប់ឱ្យចុងចម្លើយរួមគ្នាសងការប្រាក់ចំនួន ៥% (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន USD ៩៥.៣០០ (ប្រាំបួនម៉ឺនប្រាំពាន់បីរយដុល្លារអាមេរិក) ទៅឱ្យដើមចោទ ។

៣- បង្គាប់ឱ្យចុងចម្លើយ រួមគ្នាសងប្រាក់សម្រាប់ការខូចខាតពេលវេលា និង ជម្ងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលានរៀល) ទៅឱ្យដើមចោទ ។

៤- សាលក្រមនេះ អនុវត្តជាបណ្តោះអាសន្ន **ត្រង់ចំណុចទី១** នៃសេចក្តីសម្រេចបញ្ចប់ ។

៥- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ចំពោះមុខភាគី ដើមចោទ ចុងចម្លើយ និងបានប្រកាសជាសាធារណៈនា ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ។

ថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំជូតឯកស័ក
ព.ស.២៥៦៣
តាកែវ,ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
**ចៅក្រម**
(ហត្ថលេខា និងត្រា) [redacted]

---

បានឃើញ
ថ្ងៃពុធ ១កើត ខែពិសា ខ ឆ្នាំជូត ឯកស័ក
ព.ស.២៥៦៣
តាកែវ,ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
**ចៅក្រម**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំជូត ឯកស័ក
ព.ស.២៥៦៣
តាកែវ,ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
**ក្រឡាបញ្ជី**



[redacted]

[redacted]

# ឧបសម្ព័ន្ធទី៤

## សាលក្រមសាលាដំបូងខេត្តតាកែវ, លេខៈ ៨៦ "ខ"

## ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨

## (រឿងក្តីព្រហ្មទណ្ឌៈ បទរំលោភលើទំនុកចិត្ត)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សាលក្រមព្រហ្មទណ្ឌ
លេខ:៨៦"ង"
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨
សំណុំរឿងព្រហ្មទណ្ឌលេខ:០៦
ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយដោយព្រះរាជក្រមលេខ: នស.រកម.០៨០៧.០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តតាកែវពីថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១៨ ដោយមានសមាសភាពដូចតទៅ:

### ចៅក្រមជំនុំជម្រះ

លោក: [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

### តំណាងអយ្យការ

លោក: [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក: [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ: ០៦ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៣ ដែលមានពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ប្តីឈ្មោះ [redacted] មានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន។

-ជាប់ចោទពីបទ: "រំលោភលើទំនុកចិត្ត" ប្រព្រឹត្តនៅភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៣៩១និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើនគរបាលខេត្តតាកែវ មានទីលំនៅសព្វថ្ងៃនៅភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

### ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ

-កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ឈ្មោះ [redacted] ភេទប្រុស អាយុ៤៧ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] បានបង្កើតសមាគមលេងតុងទីន មានសមាជិកចំនួន២៤នាក់ លេងក្បាលចំនួន ២០០$ (ពីររយដុល្លារអាមេរិក) មួយខែដេញម្តង។ លុះដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឈ្មោះ [redacted] និងប្តី

ឈ្មោះ [redacted] ដែលជាសមាជិកលេងតុងទីន បានដេញយកប្រាក់ចំនួន ៣៧៥០$ (បីពាន់ប្រាំពីររយ ប៉ែតសិបដុល្លារអាមេរិក) ពីប្រធានសមាគមឈ្មោះ [redacted] និងឈ្មោះ [redacted] ហើយបានរត់គេចខ្លួនរហូត ។

-បានឃើញសាលក្រមលេខ: ១៨៨ (ច) ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តតាកែវ ។

-បានឃើញកំណត់ហេតុស្តីពីសាលក្រមកំបាំងមុខរបស់អយ្យការសាលាអមដំបូងខេត្តតាកែវ ។

**ពេលសវនាការ**

-ពិរុទ្ធជនឈ្មោះ [redacted] បានឆ្លើយថា ៖ នាងខ្ញុំបានលេងតុងទីនដែលមានក្បាលចំនួន២០០$(ពីររយដុល្លារអាមេរិក) មានសមាជិកចំនួន២៤នាក់ ដោយមានឈ្មោះ [redacted] ជាមេតុងទីន ហើយខ្ញុំបាទដេញយកតុងទីននេះ ដោយបង់បាន០៧ នាក់រួចហើយនៅសល់តែ១៧នាក់ទៀត ប្រាក់សរុបដែលខ្ញុំទទួលបានគឺជាងបីពាន់ដុល្លារអាមេរិក។ ប្រាក់សរុបដែលខ្ញុំនៅជំពាក់មេតុងទីនចំនួន ៣២០០$ (បីពាន់ពីររយដុល្លារអាមេរិក) តែពេលនេះខ្ញុំបានសងចំនួន១៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក) ហើយនៅសល់ចំនួន១៧០០$ (មួយពាន់ប្រាំពីររយដុល្លារអាមេរិក) ទៀត។ ប្រាក់ដែលនៅសល់គឺនាងខ្ញុំសុំសងក្នុងមួយខែ ៥០$(ហាសិបដុល្លារអាមេរិក)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា៖ ជនជាប់ចោទឈ្មោះ [redacted] បានដេញយកប្រាក់តុងទីនពីខ្ញុំចំនួន៣៥០០$ (បីពាន់ប្រាំរយដុល្លារអាមេរិក) តែក្រោយមកឈ្មោះ [redacted] បានសងប្រាក់ចំនួន ១៧០០$ (មួយពាន់ប្រាំពីររយដុល្លារអាមេរិក) រួចហើយ ប្រាក់ដែលនៅសល់គឺ១៨០០$ (មួយពាន់ប្រាំបីរយដុល្លារអាមេរិក) ទៀត។ ក្នុងរឿងនេះគឺខ្ញុំទាមទារសំណងនៃការខូចខាតគឺប្រាក់ចំនួន ១៨០០$ (បីពាន់ពីររយដុល្លារអាមេរិក) តែប៉ុណ្ណោះ ចំពោះជំងឺចិត្តខ្ញុំមិនទាមទារនោះទេ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជននិងដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៦០៤ អយ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ និងស្នើសុំអោយលោកចៅក្រមជំនុំជម្រះសម្រេចទៅតាមឆន្ទានុសិទ្ធិ។

-លោកមេធាវីការពារសិទ្ធិពិរុទ្ធជនបានធ្វើសេចក្តីសន្និដ្ឋានថា៖ សុំអោយលោកចៅក្រមជំនុំជម្រះកែប្រែសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ: ១៨៨ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ។ ដោយដើមបណ្តឹងរដ្ឋប្បវេណីនិងជនជាប់ចោទបានឯកភាពគ្នាក្នុងការសងប្រាក់លេងតុងទីនរួចហើយ និងទុកឱកាសឲ្យជនជាប់ចោទរកប្រាក់ដែលនៅជំពាក់សងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀត។

-ក្រោយពីបានបើកកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តតាកែវ**

**យល់ឃើញថា**

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌនេះមកជំនុំជម្រះសារជាថ្មីដែលមានពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ បានប្តឹងទាស់ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ: ១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តតាកែវលើខ្លឹមសារទាំងមូល ដូច្នេះតុលាការយល់ឃើញថា បណ្តឹងនេះ ធ្វើឡើងត្រឹមត្រូវតាមនីតិវិធី អាចឱ្យតុលាការធ្វើការជំនុំជម្រះឡើងវិញបានតាមមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-សំណុំរឿងព្រហ្មទណ្ឌលេខ: ០៦ ចុះថ្ងៃ០២ ខែមករា ឆ្នាំ២០១៣ គឺមានសាលក្រមព្រហ្មទណ្ឌ លេខ:១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ៣០ឆ្នាំ មានពិរុទ្ធភាពពីបទ:"រំលោភលើទំនុកចិត្ត" ប្រព្រឹត្តនៅភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកត្រាំង ខេត្តតាកែវ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៣-ឆ្លងតាមការដេញដោលនាពេលសវនាការពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ បានឆ្លើយថា៖ ខ្លួនបានលេងតុងទីនជាមួយឈ្មោះ [redacted] ជាមេតុងទីន ហើយតុងទីននេះមានសមាជិកចំនួន២៤នាក់ ហើយក្នុង១ក្បាលគឺចំនួន២០០$(ពីររយដុល្លារអាមេរិក) បន្ទាប់មកខ្លួនដេញយកតុងទីននេះបានប្រាក់ជាងបីពាន់ដុល្លារអាមេរិក ដោយបង់បានចំនួនប្រាំពីរនាក់រួចហើយ នៅសល់ចំនួន១៧នាក់ទៀតគឺខ្លួនមិនបានបង់ទៅឱ្យមេតុងទីននោះទេ។ ប្រាក់សរុបដែលនាងខ្ញុំជំពាក់មេតុងទីនគឺ ៣២០០$ (បីពាន់ពីររយដុល្លារអាមេរិក) ពេលនោះខ្លួនបានសងចំនួន១៥០០$(មួយពាន់ប្រាំរយដុល្លារអាមេរិក) នៅខ្វះចំនួន ១៧០០$(មួយពាន់ប្រាំពីររយដុល្លារអាមេរិក) ទៀតប្រាក់ដែលនៅសល់គឺខ្លួនសុំសងក្នុងមួយខែ៥០$ (ហាសិបដុល្លារអាមេរិក)។ ការឆ្លើយរបស់ពិរុទ្ធជនឈ្មោះ [redacted] អាចឱ្យតុលាការជឿបានថា ពិរុទ្ធជនពិតជាបានជំពាក់ប្រាក់ឈ្មោះ [redacted] ដែលជាមេតុងទីន ហើយមានចេតនាគេចវេសពីកាតព្វកិច្ចនៃការបង់ប្រាក់នេះ ដូចនេះគប្បីតុលាការទទួលយកមកពិចារណា។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា៖ប្រាក់សរុបដែលពិរុទ្ធជនឈ្មោះ [redacted] និងឈ្មោះ [redacted] បានជំពាក់ក្នុងការលេងតុងទីនគឺចំនួន៣៥០០$(បីពាន់ប្រាំរយដុល្លារអាមេរិក) ហើយពិរុទ្ធជនបានសងប្រាក់ចំនួន១៧០០$(មួយពាន់ប្រាំពីររយដុល្លារអាមេរិក) រួចហើយ ប្រាក់ដែលនៅ

សល់គឺចំនួន១៨០០$(មួយពាន់ប្រាំបីរយដុល្លារអាមេរិក) ទៀត គឺខ្លួនទូវតែទាមទារនូវសំណងនៃការខូចខាតនេះដដែល ចំពោះសំណងជម្ងឺចិត្តនេះគឺខ្លួនមិនបានទាមទារនោះទេ។ ការឆ្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គប្បីតុលាការទទួលយកមកពិចារណានិងសម្រេច។

៥-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជននិងដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៦០៤ អយ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ និងស្នើសុំអោយលោកចៅក្រមជំនុំជម្រះមេត្តាសម្រេចទៅតាមឆន្ទានុសិទ្ធិ។

៦-លោកមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជនបានធ្វើសេចក្តីសន្និដ្ឋានថា៖ សុំអោយលោកចៅក្រមជំនុំជម្រះ កែប្រែសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ: ១៨៨ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ។ គប្បីតុលាការពិចារណានិងសម្រេច ។

៧-ពិរុទ្ធជនឈ្មោះ [redacted] បានសំណូមពរអោយតុលាការមេត្តាជួយបន្ធូបន្ថយទោសអោយរូបខ្លួនផង ។ ការសំណូមពរនេះ តុលាការទទួលយកមកពិចារណានិងសម្រេច ។

៨-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន និងសំដីចុងក្រោយរបស់ពិរុទ្ធជនក្នុងការធ្វើសំណូមពរ តុលាការគប្បីពិចារណានិងសម្រេច ។

៩-គប្បីតុលាការតម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តតាកែវទុកជាបានការដដែល ប៉ុន្តែកែប្រែចំណុច១-ខនិងចំណុច២នៃសាលក្រមនេះ។

១០-គប្បីតុលាការកែប្រែសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ: ១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ត្រង់ចំណុច១-ខ និងចំណុច២នៃខ្លឹមសារសាលក្រមនេះសារជាថ្មី ។

**ហេតុដូច្នេះទើបសម្រេច**

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តតាកែវទុកជាបានការដដែល ប៉ុន្តែកែប្រែចំណុច១-ខនិងចំណុច២នៃសាលក្រមនេះ។

២-កែប្រែសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ: ១៨៨(ច) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ត្រង់ចំណុច១-ខ និងចំណុច២នៃខ្លឹមសារសាលក្រមនេះសារជាថ្មី ។

៣-ផ្តន្ទាទោសលើឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ ដោយអនុវត្តទោសជាប់ពន្ធនាគារចាប់ពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ: "រំលោភលើទំនុកចិត្ត" ប្រព្រឹត្តនៅភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកត្រាំង ខេត្តតាកែវ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ៣៩១,៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៤-បង្គាប់អោយឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] សងសំណងនៃការខូចខាតជាប្រាក់ចំនួន ១៨០០$ (បីពាន់ប្រាំបីរយដុល្លារអាមេរិក) ទៅអោយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

៥-បង្គាប់អោយដោះលែងឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ចាប់ពីពេលនេះតទៅ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និងពិរុទ្ធជនឈ្មោះ [redacted] និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំពោះពិរុទ្ធជនឈ្មោះ [redacted] កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ទុកសិទ្ធិប្ដឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃសុក្រ ៩រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២

តាកែវ , ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៩រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២

តាកែវ, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨

ក្រឡាបញ្ជី

[redacted]

-សេចក្តីនេះ៖ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ត្រាសបង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្ត សាលក្រម អាជ្ញាធរមានសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជួយសហការ អនុវត្ត សាលក្រម នេះឲ្យបានសម្រេចកាលបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

-សាលក្រមនេះបានចូលជាសាលក្រមស្ថាពរ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ នេះតទៅ ពិព្រោះផុតរយៈពេលបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

..........................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទីចន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

តាកែវ,ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

# ឧបសម្ព័ន្ធទី៥

## សាលដីកាសាលាឧទ្ធរណ៍, លេខ៖ ១៧ "ក្រ V ទល"

## ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២0២0

## ( រឿងក្តីព្រហ្មទណ្ឌ៖ បទឆបោក )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖ ១០៩៨
ចុះថ្ងៃទី៖ ១៦-០៩-២០១៩
សាលដីកា
លេខ ៖ ១៧ -ក្រ V ១ល-
ចុះថ្ងៃទី៖ ២៨-០២-២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទីដប់បី ខែកុម្ភៈ ឆ្នាំពីរពាន់ម្ភៃ ដោយមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

កញ្ញា [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ១០៩៨ ចុះថ្ងៃទី១៦-៩-២០១៩ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគ្រូពេទ្យ ទីកន្លែងកំណើតភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកសេរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្ននៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ, ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន [redacted] នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ: ឆបោក ប្រព្រឹត្តនៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ហៅ[redacted]ភេទស្រី កើតឆ្នាំ ១៩៧៦ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិតារាងបាល់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ[redacted] មានកូន[redacted]នាក់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិសែសិន ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ[redacted] មានកូន[redacted]នាក់។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិតារាងបាល់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ[redacted]។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិដីមាន់កណ្តាល ឃុំព្រែក ស្រុកពញាព្រែក ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ [redacted] មានកូន[redacted]នាក់។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិវាលវង់ឃុំវាលវង់ ស្រុកវាលវង់ ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ[redacted] មានកូន[redacted]នាក់។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិសែសិប ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted] ប្តីឈ្មោះ[redacted] គ្មានកូន ។

## ង.រឿងហេតុមានដូចតទៅ

កាលពីឆ្នាំ ២០១៨ ឈ្មោះ [redacted] ភេទស្រី ដែលជាមេតុងទីនបានបបួល និងបោកបញ្ឆោតឲ្យជនរងគ្រោះចំនួន ០៦នាក់ មានឈ្មោះ[redacted] ហៅ[redacted] ឈ្មោះ[redacted] ហៅ [redacted] ឈ្មោះ[redacted] ហៅ[redacted] ឈ្មោះ[redacted], ឈ្មោះ [redacted] និងឈ្មោះ[redacted] ហៅ [redacted] និងសមាជិកតុងទីនផ្សេងទៀតជាមួយខ្លួនចំនួន ០៣ (បី) ខ្សែ ។ តុងទីនខ្សែទី១ មានចំនួន ៥១ (ហាសិបមួយ) ក្បាល ក្នុង ១ក្បាល តម្លៃ ២០០ (ពីររយ) ដុល្លារអាមេរិក ដោយចាប់ផ្តើមលេងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ នឹងត្រូវបញ្ចប់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដោយដេញមួយខែម្តង ។ តុងទីនខ្សែទី២ មានចំនួន ៦៦ (ហុកសិបប្រាំមួយ)ក្បាល ដោយដេញក្នុងមួយក្បាល តម្លៃ ២០០(ពីររយ) ដុល្លាអាមេរិកដោយចាប់ផ្តើមលេងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ និងត្រូវបញ្ចប់នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ដោយដេញមួយ

ខែម្តង។ តុងទីនខ្សែទី៣ មានចំនួន៥៦ (ហាសិបប្រាំមួយ)ក្បាល ដោយតុងមួយក្បាល តម្លៃ៣០០ (បីរយ) ដុល្លារអាមេរិក ដោយចាប់ផ្តើមពីថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ និងត្រូវបញ្ចប់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២១ ដោយដេញមួយខែម្តង។ ពេលចាប់ផ្តើម លេងមុនដំបូងមិនសូវមានបញ្ហាអ្វីឡើយ ។ ក្រោយមក មានពត៌មានថា សមាជិកតុងទីនខ្លួនដេញហើយ តែឈ្មោះ[redacted] មិនបានប្រគល់លុយ គ្រប់ចំនួនទៅឲ្យសមាជិកតុងទីនដែលដេញបាននោះទេ ។ លុះដល់ឆ្នាំ២០១៨ ឈ្មោះ [redacted] បានប្រកាសថា តុងទីនទាំងបីខ្សែដែលខ្លួនបានធ្វើមេតុងទីនោះខូចអស់ហើយ ដោយគ្មានមូលហេតុត្រឹមត្រូវ ។ ចំពោះ សមាជិកតុងទីនដែលមិនទាន់ងាប់នោះ ឈ្មោះ[redacted] បានបង់ឲ្យជនរងគ្រោះ បានតែ០២ ទៅ ០៣ ខែដំបូងតែប៉ុណ្ណោះ ។ ក្រោយមកឈ្មោះ[redacted] គេចស្រី មិនព្រមបង់ប្រាក់ឲ្យជនរងគ្រោះតាមការ សន្យានោះទេ ។ ដោយមានការសង្ស័យ ជនរងគ្រោះឈ្មោះ[redacted] ហៅ[redacted] បានសាកសួរ សមាជិកតុងទីនដទៃទៀត ទើបដឹងថា សមាជិកតុងទីនខ្លះមានតែឈ្មោះ ប៉ុន្តែការពិតឈ្មោះនោះជាឈ្មោះ ខ្មោច ដែលមេតុងទីនឈ្មោះ[redacted] ចេះតែដាក់ដើម្បីភូតកុហក និងបោកបញ្ឆោតសមាជិកតុងទីន ផ្សេងទៀតឲ្យលេងតុងទីនជាមួយ ។ ជាក់ស្តែងសមាជិកតុងទីន ម្នាក់ឈ្មោះ[redacted] ហៅ[redacted] ត្រូវបានឈ្មោះ សំ សាវ៉ាន់ ជាមេតុងទីនដាក់ឈ្មោះ ជាលេងតុងទីន (ក្បាល ២០០ដុល្លារ) ជាមួយ។ ហើយ ថែមទាំងដាក់ឈ្មោះ[redacted]ហៅ[redacted]ដេញរួចហើយ (តុងទីនងាប់)។ ប៉ុន្តែតាមពិតឈ្មោះ[redacted] ហៅ [redacted] មិនបានលេងតុងទីន ក្បាលនោះទេ ហើយគាត់ក៏មិនបានដេញតុងទីននោះដែរ ។ អំពើបោក បញ្ឆោតរបស់ឈ្មោះ[redacted] បានធ្វើឲ្យជនរងគ្រោះទាំង ៦នាក់ ខាងលើទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ដែលសរុបជាប្រាក់ ៥៩,២០០ (ប្រាំម៉ឺនប្រាំបួនពាន់ពីររយ)ដុល្លារអាមេរិក ។

-**បានឃើញ** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៅ[redacted]នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ មានភាពប្រហាក់ប្រហែលគ្នាថា៖ ខ្លួនស្គាល់ឈ្មោះ[redacted] រយៈពេលបួនប្រាំឆ្នាំហើយ ដោយគាត់មានមុខរបរជាគ្រូពេទ្យ ។ ឈ្មោះ[redacted] ជាមេតុងទីន ដោយលេងមួយខ្សែ មានគ្នា ៥១នាក់ មួយក្បាល ២០០ (ពីររយ) ដុល្លារអាមេរិក ដេញអស់៤៨នាក់ ចំណាយការបង់អស់ចន្លោះពី ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ទៅ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ ចំណែកមួយក្បាលទៀត ខ្លួនបានដេញងាប់បាត់ហើយ ដោយខ្លួនបានបង់ឲ្យរហូតដល់នៅសល់គ្នាប្រហែល៣នាក់ទើបឈប់បង់ ។ បន្ទាប់ពីឈ្មោះ[redacted] ដែលជាមេតុងទីន បានប្រកាសថាតុងទីនដែលពួកខ្លួនលេងជាមួយគាត់ត្រូវបានរលាយអស់ហើយ ទើបខ្លួនដឹងថាមានម្នាក់ដែលគាត់មិនបានលេងតែយកឈ្មោះគាត់មកដាក់ ចំណែកឯអ្នកផ្សេងទៀតខ្លួនមិនបានដឹងនោះទេ ។ ក្នុងរឿងនេះខ្លួនទាមទារសំណងដែលជាប្រាក់របស់ខ្លួនបានបង់នោះចំនួន ៨៦,០០០ (ប្រាំបីម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ពីឈ្មោះ[redacted]។

-**បានឃើញ** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរនិងនាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានលេងតុងទីនចំនួន ៣ក្បាល ដោយលេងតែមួយខ្សែ ហើយមួយក្បាលតម្លៃ ៣០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥៦នាក់ ដោយដេញ១ ខែម្តង ដែលមានឈ្មោះ[redacted] ជាមេតុងទីន។ ខ្លួនបានបង់ប្រាក់រាល់ខែ ប៉ុន្តែមិនទាន់បានដេញឡើយ គឺរស់

ទាំងបីខ្សែ ។ បន្ទាប់មកនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ មេតុងទីនបានប្រាប់ខ្លួនថា តុងទីនបានរំសាយហើយ ដោយគាត់ប្រាប់ថា ចាំគិតគូលុយដែលត្រូវសងមកខ្លួននោះចំនួន ២១,៦០០ (ពីរម៉ឺនមួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ហើយក្រោយមកមេតុងទីនបានទូទាត់ឲ្យខ្លួនបានខ្លះនៅសល់ចំនួន១១.៦៧៦ (មួយម៉ឺនមួយពាន់ប្រាំមួយរយចិតសិបប្រាំមួយ) ដុល្លារអាមេរិក ។ ក្នុងរឿងនេះខ្លួនទាមទារដែលនៅសល់ចំនួន ១១.៦៧៦ (មួយម៉ឺនមួយពាន់ប្រាំមួយរយចិតប្រាំមួយ) ដុល្លារអាមេរិក ពីឈ្មោះ [redacted] ។

**-បានឃើញ** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើប និងនាពេលសវនាការ ឆ្លើយមានភាពប្រហាក់ប្រហែលថា៖ ខ្លួនបានលេងតុងទីនចំនួន ០២ ក្បាល ដោយលេងតែមួយខ្សែ ហើយមួយក្បាលតម្លៃ ២៥០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥១ នាក់ ដោយដេញ ១ខែម្តង ដែលមានឈ្មោះ [redacted] ជាមេតុងទីន ។ ខ្លួនបានបង់ប្រាក់រាល់ខែ ហើយខ្លួនបានដេញងាប់អស់១ក្បាលនៅសល់ ១ក្បាលទៀត ។ បន្ទាប់មកនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ ខ្លួនបានដេញមយកមួយក្បាលទៀត ប៉ុន្តែមេតុងទីនបានប្រាប់ខ្លួនថា តុងទីនបានរំសាយហើយ ដោយមានកូនតុងទីន ៤៣ ងាប់នៅសល់ ៨ ក្បាលដោយគាត់ប្រាប់ថា ចំពោះលុយរបស់ខ្លួនគាត់ជាអ្នកទទួលខុសត្រូវ ។ លុយតុងទីនដែលខ្លួនមិនទាន់បានដេញនោះមានចំនួន ៤.៦៦២ (បួនពាន់ប្រាំមួយរយហុកសិបពីរ) ដុល្លារអាមេរិក ។

**-បានឃើញ** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]នៅដំណាក់កាលចៅក្រមស៊ើប និងនាពេលសវនាការ ឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានលេងតុងទីន ចំនួន ២ក្បាល ក្នុង ១ក្បាល តម្លៃ ២០០ ដុល្លារ រយៈពេល ១៥ ខែ ដោយដេញម្តងមួយខែ មានសមាជិក ៦៦ នាក់ ដោយឈ្មោះ [redacted] ជាមេតុងទីន ហើយចាប់ផ្តើមលេងពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ។ ចំពោះតុងទីនរបស់ខ្លួនបានដេញងាប់អស់ចំនួន ១ ក្បាល ហើយនៅសល់ ១ក្បាលទៀត។ដោយក្បាលដែលស្លាប់នេះ គឺខ្លួនត្រូវបង់ឲ្យគេចំនួន ១.៦០០ (មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិកចំណែកឯក្បាលដែលនៅរស់ទេ នបានបង់ប្រាក់របស់ខ្លួនចំនួន ៦.៦០០ (ប្រាំមួយពាន់ប្រាំមួយរយ)ដុល្លារអាមេរិក ។ ក្នុងរឿងនេះខ្លួនទាមទារសំណងដែលជាប្រាក់របស់ខ្លួនបានបង់នោះ ចំនួន១០,០០០(មួយម៉ឺន) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្ត ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ពីឈ្មោះសំ សារ៉ន ។

**-បានឃើញ** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]បញ្ជាក់ថា ៖ ខ្លួនបានលេងតុងទីនចំនួន ១ក្បាល តម្លៃ ២០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥១ នាក់ដោយដេញ ១ ខែម្តង ដែលមានឈ្មោះ [redacted] ជាមេតុងទីន ។ កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៨ ជាថ្ងៃដេញលើកទី៤៤ ហើយខ្លួនបានទៅដេញយកដល់ផ្ទះរបស់មេតុងទីន ប៉ុន្តែមេតុងទីនបានប្រាប់ថារំសាយហើយ ។ ចំនួនទឹកប្រាក់ដែលខ្លួនត្រូវដេញបាននោះ ចំនួន ៨,៦០០ (ប្រាំបីពាន់ប្រាំមួយរយ) ដុល្លារ ។ ក្នុងរឿងនេះខ្លួនទាមទារប្រាក់ចំនួន ៨,៦០០ ប្រាំបីពាន់ប្រាំមួយរយ) ដុល្លារ និងទាមទារសំណងជំងឺចិត្តចំនួន ៥,០០០ (ប្រាំពាន់)ដុល្លារអាមេរិក ពីឈ្មោះ[redacted] ។

**-បានឃើញ** អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ជាក់ថា ៖ ខ្លួនបានលេងតុងទីនចំនួន ១ក្បាល ដោយមានក្បាល តម្លៃ ២០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៦៦ នាក់

ដោយផ្ញើ ១ខែម្តង ដែលមានឈ្មោះ [redacted] ជាមេតុងទីន ហើយខ្លួនបានបង់ប្រាក់រាល់ខែ។ បន្ទាប់មកនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានផ្ញើតុងទីនដែលខ្លួនលេងនោះ ដោយទឹកប្រាក់ដែលផ្ញើបាននោះចំនួន ១១,៨០០ (មួយម៉ឺនមួយពាន់បួនរយ) ដុល្លារអាមេរិក ប៉ុន្តែមេតុងទីនបានឲ្យប្រាក់មកខ្លួនតែ ៤,០០០ (បួនពាន់) ដុល្លារ តែប៉ុណ្ណោះ ចំណែកប្រាក់ដែលនៅសល់នោះមេតុងទីនមិនព្រមសងទេ ។

-**បានឃើញ** ចម្លើយសាក្សីឈ្មោះ [redacted] ហៅ [redacted] នៅដំណាក់កាលស៊ើបសួរ បានឆ្លើយថា ចំពោះឈ្មោះ [redacted] ដែលបានដាក់ឈ្មោះខ្លួន [redacted] ជាអ្នកលេងតុងទីន(ក្បាលពីររយដុល្លារ)ជាមួយគាត់នោះ ខ្លួនសូមបដិសេធចោល ខ្លួនមិនបានលេងតុងទីន (ក្បាលពីររយដុល្លារ)ជាមួយមេតុងទីនឈ្មោះ [redacted] នោះទេ ។ កន្លងមកនាងខ្ញុំធ្លាប់បានលេងតុងទីន (ក្បាលបីរយដុល្លារអាមេរិក) ជាមួយឈ្មោះ [redacted] ពិតប្រាកដមែន ។ ប៉ុន្តែខ្លួនមិនបានលេងតុងទីន(ក្បាលពីររយដុល្លារអាមេរិក)ជាមួយមេតុងទីនឈ្មោះ [redacted] នោះទេ។ លុះមកដល់អំឡុង ខែសីហា ឆ្នាំ២០១៨ មេតុងទីនឈ្មោះ [redacted] បានប្រកាសថារំសាយតុងទីនចោលទាំងអស់ ។ ទើបឈ្មោះ [redacted] បានមកសួរខ្លួនថាមានលេង (តុងទីនក្បាលពីររយដុល្លារអាមេរិក)ជាមួយពួកគាត់ទេ? ព្រោះគេឃើញមានឈ្មោះខ្លួនលេងនៅក្នុងបញ្ជីតុងទីន (ក្បាលពីររយដុល្លារអាមេរិក) នោះដែរពេលបានដឹងដូច្នេះខ្លួនមានអារម្មណ៍ខ្លាំងឈ្មោះ [redacted] ព្រោះថាខ្លួនមិនបានលេងតុង (ក្បាលពីររយដុល្លារអាមេរិក) ជាមួយគាត់។ បែរជាឈ្មោះ [redacted] ដាក់ឈ្មោះនាងខ្ញុំលេងតុទីនជាមួយគាត់ទៅវិញ។ ខ្លួនមិនធ្លាប់មានទំនាស់ជាមួយឈ្មោះ [redacted] ពីមុនមកឡើយ ហើយឈ្មោះ [redacted] និងអ្នកដាក់ពាក្យបណ្តឹងផ្សេងទៀត ខ្លួនមិនមានជាប់សាច់ញាតិបងប្អូនពួកគាត់ឡើយ ។

-**បានឃើញ** រឿងក្តីនេះ សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ:២២ (ឋ) ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៩ ដែលមានខ្លឹមសារដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ៣៦ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគ្រូពេទ្យ ទីកន្លែងកំណើតភូមិឬស្សីក្រោក ឃុំឬស្សីក្រោក ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្ន ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted] មានកូន [redacted] នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន ដាក់ពន្ធនាគារកំណត់រយៈពេល ៨(ប្រាំបី)ខែ ពីបទ "ឆបោក" ប្រព្រឹត្តនៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ តែទោសនេះត្រូវព្យួរធម្មតា តាមបញ្ញត្តិមាត្រា១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ សងប្រាក់ និងសំណងជម្ងឺចិត្តឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី៖

២.១.ឈ្មោះ [redacted] ហៅ ធុំ ភេទស្រី កើតឆ្នាំ១៩៧៦ សញ្ជាតិខ្មែរ ចំនួន ៥.៥០០$ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០៛ (ប្រាំលានរៀល)

២.២.ឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ចំនួន ១២.០០០$ (ដប់ពីរពាន់ដុល្លារអាមេរិក)

២.៣.ឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ ចំនួន ៦.០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០៛ (ប្រាំលានរៀល)

២.៤.ឈ្មោះ [redacted] ភេទស្រី អាយុ ៣៩ឆ្នាំ សញ្ជាតិខ្មែរ ចំនួន ៥.៥០០$ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០៛ (ប្រាំលានរៀល)

២.៥.ឈ្មោះ [redacted] ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ ចំនួន ៦.០០០ $(ប្រាំមួយដុល្លារអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០៛ (ប្រាំលានរៀល)

២.៦.ឈ្មោះ [redacted] ភេទស្រី អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ ចំនួន ៨.០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០៛ (ប្រាំលានរៀល)

ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

៣.បញ្ឈប់ការចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទស្រី ។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៅ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted]។

បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៩ របស់ មេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted] របស់ឈ្មោះ [redacted], [redacted], [redacted], [redacted], [redacted] និងឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ២២ "" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ "" ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី២, ២.១, ២.២, ២.៣, ២.៤, ។

-**បានឃើញ** សេចក្តីបណ្តឹងឧទ្ធរណ៍លេខ៤៩ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ២២ "" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទី១ សេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍

-បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ

ណះពេលសវនាការ

ប្រធានក្រុមប្រឹក្សាសាងបអង្គហេតុ

-បានឃើញអំណានកំណត់ហេតុចម្លើយរបស់ជនជាប់ចោទ

-បានឃើញអំណានកំណត់ហេតុចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន ៖ ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តអំពើឆបោក ទើបអគ្គព្រះរាជអាជ្ញាធ្វើការប្តឹងឧទ្ធរណ៍លើសាលក្រមនេះ ដូច្នេះតំណាងមហាអយ្យការ ស្នើសុំឱ្យក្រុមប្រឹក្សាបន្ថែមទោស និងចេញដីកាចាប់ខ្លួន ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ២៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៖ ២២ (ឋ) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៥ ត្រង់ចំណុចចំណុចទី ២, ២.១, ២.២, ២.៣, ២.៤,២.៥,២.៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បណ្តឹងធ្វើឡើងក្នុងកំណត់ច្បាប់មាត្រា៣៧៥ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-ពាក្យបណ្តឹងឧទ្ធរណ៍លេខ២២ (ឋ) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted], [redacted], [redacted], [redacted] និងឈ្មោះ [redacted] ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ (ឋ) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល បណ្តឹងឧទ្ធរណ៍ត្រង់ចំណុចសំណងរដ្ឋប្បវេណី នៃសេចក្តីសម្រេចធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។ តែចំពោះបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធចំណុចទណ្ឌកម្ម នៃសេចក្តីសម្រេចឃើញថា ធ្វើឡើងត្រឹមត្រូវតាមទម្រង់ ដោយហេតុថា ក្នុងរឿងនេះក្រុមប្រឹក្សាពិនិត្យឃើញមានបណ្តឹងឧទ្ធរណ៍លេខ៤៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្តឹងឧទ្ធរណ៍ ត្រង់ចំណុចទី១ នៃសេចក្តីសម្រេចហើយ បណ្តឹងរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាធ្វើឡើងក្នុងកំណត់ច្បាប់ ដូច្នេះយោងតាមបញ្ញត្តិមាត្រា៣៧៥ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

៣-តាមការពិភាក្សាដេញដោលនាពេលសវនាការនៅសាលាឧទ្ធរណ៍លើជនជាប់ចោទឈ្មោះ [redacted] មិនមានវត្តមានគ្រប់ដំណាក់កាលរហូតមកដល់សាលាឧទ្ធរណ៍ ក្រុមប្រឹក្សាយល់ឃើញថា តាមចម្លើយ

របស់ដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងឯកសារពាក់ព័ន្ធនៅក្នុងសំណុំរឿង ហើយមានសាក្សីឈ្មោះ [redacted] ហៅ [redacted] នៅដំណាក់កាលអយ្យការមកបញ្ជាក់យ៉ាងច្បាស់ថា ចំពោះឈ្មោះ [redacted] ដែលបានដាក់ឈ្មោះខ្លួន ([redacted]) ជាអ្នកលេងតុងទីន(ក្បាលពីររយដុល្លារ)ជាមួយគាត់នោះ ខ្លួនសូមបដិសេធចោល ខ្លួនមិនបានលេងតុងទីន (ក្បាលពីររយដុល្លារ)ជាមួយមេតុងទីនឈ្មោះ [redacted] នោះទេ ។ កន្លងមកខ្លួនធ្លាប់បានលេងតុងទីន (ក្បាលបីរយដុល្លារអាមេរិក) ជាមួយឈ្មោះ [redacted] ពិតប្រាកដមែន ។ ប៉ុន្តែខ្លួនមិនបានលេងតុងទីន(ក្បាលពីររយដុល្លារអាមេរិក)ជាមួយមេតុងទីនឈ្មោះ [redacted] នោះទេ ។ លុះមកដល់អំឡុង ខែសីហា ឆ្នាំ២០១៨ មេតុងទីនឈ្មោះ [redacted] បានប្រកាសថាស៊ោយតុងទីនចោលទាំងអស់ ។ ទើបឈ្មោះ [redacted] បានមកសួរខ្លួនថាមានលេង (តុងទីនក្បាលពីររយដុល្លារអាមេរិក)ជាមួយពួកគាត់ទេ? ព្រោះគេឃើញមានឈ្មោះខ្លួនលេងនៅក្នុងបញ្ជីតុងទីន (ក្បាលពីររយដុល្លារអាមេរិក) នោះដែរពេលបានដឹងដូច្នេះខ្លួនមានអារម្មណ៍ខ្លាំងឈ្មោះ [redacted] ព្រោះថាខ្លួនមិនបានលេងតុង (ក្បាលពីររយដុល្លារអាមេរិក) ជាមួយគាត់។ បែរជាឈ្មោះ [redacted] ដាក់ឈ្មោះខ្លួនលេងតុទីនជាមួយគាត់ទៅវិញ ។ ខ្លួនមិនធ្លាប់មានទំនាស់ជាមួយឈ្មោះ [redacted] ពីមុនមកឡើយ ហើយឈ្មោះ [redacted] និងអ្នកដាក់ពាក្យបណ្តឹងផ្សេងទៀត ខ្លួនមិនមានជាប់សាច់ញាតិបងប្អូនពួកគាត់ឡើយ ហើយដែលចម្លើយទាំងអស់នេះមានភាពស៊ីចង្វាក់គ្នាទៅនឹងលិខិតឯកសារតុងទីនមួយក្បាល២០០ (ពីររយដុល្លារអាមេរិក)ដែលចាប់ផ្តើមប្រមូលថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងចាប់ផ្តើមដេញថ្ងៃទី០១ ខែកុម្ភៈ ដែលមានគ្នាលេងចំនួន៥១នាក់ ហើយពិតជាមានឈ្មោះ [redacted] ពិតប្រាកដមែន ហើយការដែលជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍មកនេះគឺប្តឹងតែចំណុចពាក់ព័ន្ធទៅនឹងសំណង និងជម្ងឺចិត្តទៅអោយដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ សបញ្ជាក់អោយឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាមានអំពើចេតនាទុច្ចរិតក្លែងបន្លំដាក់ឈ្មោះអ្នកដទៃ ដើម្បីការប្រមូលលុយពីជនរងគ្រោះ ដែលនាំអោយមានការខូចខាតប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដមែន ដូច្នេះគប្បីពិនិត្យ និងសម្រេចតាមច្បាប់ ។

៥-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] ហៅ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ មានភាពប្រហាក់ប្រហែលគ្នាថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] រយៈពេលបួនប្រាំឆ្នាំហើយ ដោយគាត់មានមុខរបរជាគ្រូពេទ្យ ។ ឈ្មោះ [redacted] ជាមេតុងទីន ដោយលេងមួយខ្សែមានគ្នា ៥១នាក់ មួយក្បាល ២០០ (ពីររយ) ដុល្លារអាមេរិក ដេញអស់៤៨នាក់ ចំណាយការបង់អស់ចន្លោះពី ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ទៅ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ ចំណែកមួយក្បាលទៀតខ្លួនបានដេញងាប់បាត់ហើយ ដោយខ្លួនបានបង់ឲ្យរហូតដល់នៅសល់គ្នាប្រហែលពាក់នាក់ទើបឈប់បង់។ បន្ទាប់ពីឈ្មោះ [redacted] ដែលជាមេតុងទីន បានប្រកាសថាតុងទីនដែលពួកខ្លួនលេងជាមួយគាត់ត្រូវបានស៊ោយអស់ហើយ ទើបខ្លួនដឹងថាមានម្នាក់ដែលគាត់មិនបានលេងតែយកឈ្មោះគាត់មកដាក់ ចំណែកឯអ្នកផ្សេងទៀតខ្លួនមិនបានដឹងនោះទេ។ ក្នុងរឿងនេះខ្លួនទាមទារសំណងដែលជាប្រាក់របស់ខ្លួនបានបង់នោះចំនួន ៨៦,០០០ (ប្រាំបីម៉ឺនប្រាំមួយពាន់) ដុល្លាររអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ពីឈ្មោះ [redacted] ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានលេងតុងទីនចំនួន

៣ក្បាល ដោយលេងតែមួយខ្សែ ហើយមួយក្បាលតម្លៃ ៣០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥៦នាក់ ដោយដេញ១ ខែម្តង ដែលមានឈ្មោះ [redacted] ជាមេតុងទីន ។ ខ្លួនបានបង់ប្រាក់រាល់ខែ ប៉ុន្តែមិនទាន់បានដេញឡើយ គឺរស់ទាំងបីខ្សែ ។ បន្ទាប់មកនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ មេតុងទីនបានប្រាប់ខ្លួនថា តុងទីនបានរំសាយហើយ ដោយគាត់ប្រាប់ថា ចាំគិតលុយដែលត្រូវសងមកខ្លួននោះចំនួន ២១,៦០០ (ពីរម៉ឺនមួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ហើយក្រោយមកមេតុងទីនបានខ្ទាត់ឲ្យខ្លួនបានខ្លះនៅសល់ចំនួន១១.៦៧៦ (មួយម៉ឺនមួយពាន់ប្រាំមួយរយចិតសិបប្រាំមួយ) ដុល្លារអាមេរិក។ ក្នុងរឿងនេះខ្លួនទាមទារដែលនៅសល់ចំនួន ១១.៦៧៦ (មួយម៉ឺនមួយពាន់ប្រាំមួយរយចិតប្រាំមួយ) ដុល្លារអាមេរិក ពីឈ្មោះ [redacted] ។

-តាមរំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ ឆ្លើយមានភាពប្រហាក់ប្រហែលថា៖ ខ្លួនបានលេងតុងទីនចំនួន ០២ ក្បាល ដោយលេងតែមួយខ្សែរ ហើយមួយក្បាលតម្លៃ ២០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥១ នាក់ ដោយដេញ ១ខែម្តង ដែលមានឈ្មោះ[redacted]ជាមេតុងទីន ។ ខ្លួនបានបង់ប្រាក់រាល់ខែ ហើយខ្លួនបានដេញងាប់អស់១ក្បាលនៅសល់ ១ក្បាលទៀត ។ បន្ទាប់មកនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ ខ្លួនបានដេញមយកមួយក្បាលទៀត ប៉ុន្តែមេតុងទីនបានប្រាប់ខ្លួនថា តុងទីនបានរំសាយហើយ ដោយមានកូនតុងទីន ៤៣ ងាប់នៅសល់ ៨ ក្បាលដោយគាត់ប្រាប់ថា ចំពោះលុយរបស់ខ្លួនគាត់ជាអ្នកទទួលខុសត្រូវ។ លុយតុងទីនដែលខ្លួនមិនទាន់បានដេញនោះមានចំនួន ៤.៦៦២ (បួនពាន់ប្រាំមួយរយហុកសិបពីរ) ដុល្លារអាមេរិក ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើប និងនាពេលសវនាការ ឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានលេងតុងទីន ចំនួន ២ក្បាលក្នុង ១ក្បាល តម្លៃ២០០ ដលារ រយៈពេល ១៥ ខែ ដោយដេញម្តងមួយខែ មានសមាជិក ៦៦ នាក់ ដោយឈ្មោះ[redacted]ជាមេតុងទីន ហើយចាប់ផ្តើមលេងពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ ។ ចំពោះតុងទីនរបស់ខ្លួនបានដេញងាប់អស់ចំនួន ១ ក្បាល ហើយនៅសល់ ១ក្បាលទៀត ។ ដោយក្បាលដែលងាប់នេះ គឺខ្លួនត្រូវបង់ឲ្យគេចំនួន ១.៦០០ (មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ចំណែកឯក្បាលដែលនៅរស់ទេ នបានបង់ប្រាក់របស់ខ្លួនចំនួន ៦.៦០០ (ប្រាំមួយពាន់ប្រាំមួយរយ)ដុល្លារអាមេរិក ។ ក្នុងរឿងនេះខ្លួនទាមទារសំណងដែលជាប្រាក់របស់ខ្លួនបានបង់នោះ ចំនួន១០,០០០(មួយម៉ឺន) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្ត ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ពីឈ្មោះ[redacted] ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted]បញ្ជាក់ថា ៖ ខ្លួនបានលេងតុងទីនចំនួន ១ក្បាល តម្លៃ ២០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៥១ នាក់ដោយដេញ ១ ខែម្តង ដែលមានឈ្មោះ[redacted] ជាមេតុងទីន ។ កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៨ ជាថ្ងៃដេញលើកទី៤៤ ហើយខ្លួនបានទៅដេញយកដល់ផ្ទះរបស់មេតុងទីន ប៉ុន្តែមេតុងទីនបានប្រាប់ថារំសាយហើយ ។ ចំនួនទឹកប្រាក់ដែលខ្លួនត្រូវដេញបាននោះ ចំនួន៨,៦០០ (ប្រាំបីពាន់ប្រាំមួយរយ) ដុល្លារ។ ក្នុងរឿងនេះខ្លួនទាមទារប្រាក់ចំនួន ៨,៦០០ ប្រាំបីពាន់ប្រាំមួយរយ) ដុល្លារ និងទាមទារសំណងជំងឺចិត្តចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិកពីឈ្មោះ [redacted] ។

-តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] បញ្ជាក់ថា ៖ ខ្លួនបានលេងតុងទីនចំនួន ១ក្បាល ដោយមានក្បាល តម្លៃ ២០០ ដុល្លារអាមេរិក មានសមាជិកចំនួន ៦៦ នាក់ ដោយដេញ ១ខែម្ដង ដែលមានឈ្មោះ [redacted] ជាមេតុងទីន ហើយខ្លួនបានបង់ប្រាក់រាល់ខែ។ បន្ទាប់មកនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានដេញតុងទីនដែលខ្លួនលេងនោះ ដោយទឹកប្រាក់ដែលដេញបាននោះចំនួន ១១,៤០០ (មួយម៉ឺនមួយពាន់បួនរយ) ដុល្លារអាមេរិក ប៉ុន្តែមេតុងទីនបានឲ្យប្រាក់មកខ្លួនតែ ៤,០០០ (បួនពាន់) ដុល្លារ តែប៉ុណ្ណោះ ចំណែកប្រាក់ដែលនៅសល់នោះមេតុងទីនមិនព្រមសងទេ ។

ក្រុមប្រឹក្សាយល់ឃើញថា តាមអំណានចម្លើយរបស់ដើមបណ្ដឹងទាំង៦នាក់នេះមានលក្ខណៈសមហេតុផល ហើយមានភាពស៊ីចង្វាក់គ្នាទៅនឹងអង្គហេតុដែលអាចអោយក្រុមប្រឹក្សាជឿជាក់បាន ដោយហេតុថា មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] ពិតជាមានគំនិតអំពើទុច្ចរិតក្នុងការប្រព្រឹត្តអំពើឆបោកប្រាកដមែន ។ ហើយការដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំង៦នាក់នេះបានបណ្ដឹងឧទ្ធរណ៍គ្រប់នៃសេចក្ដីទាំងមូលនេះ ក្រុមប្រឹក្សាជំនុំជម្រះរកចពិចារណាតែចំណុចសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ យោងតាមបញ្ញត្តិមាត្រា៤០២ និងមាត្រា៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះគប្បីក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមទំហំទឹកប្រាក់បាត់បង់ជាក់ស្ដែង ។

៦-សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការតាមការពិភាក្សាដេញដោលតំណាងមហាអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តអំពើឆបោក ដូច្នេះទើបតំណាងមហាអយ្យការ អគ្គព្រះរាជអាជ្ញាធ្វើការប្ដឹងឧទ្ធរណ៍លើសាលក្រមនេះ ស្នើសុំក្រុមប្រឹក្សាសុំបន្ថែមទោស និងចេញដីកាចាប់ខ្លួន ។ ក្រុមប្រឹក្សាយល់ឃើញថា ការស្នើសុំរបស់តំណាងមហាអយ្យការមានលក្ខណៈត្រឹមត្រូវ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទ ៖ ឆបោក ប្រព្រឹត្តនៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៨-សាលក្រមព្រហ្មទណ្ឌលេខ ២២ "ជ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចសេចក្ដី ពុំមានលក្ខណៈត្រឹមត្រូវ ដោយហេតុថាចំណុចការផ្ដន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទកំណត់រយៈ៨(ប្រាំបី)ខែហើយទោសនេះត្រូវព្យួរធម្មតា ក្រុមប្រឹក្សាពិនិត្យឃើញថា មានលក្ខណៈស្រាលពេក ហើយឧត្ដមអគ្គព្រះរាជអាជ្ញាក៏បានធ្វើការប្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងចំណុចនេះ ព្រោះជនជាប់ចោទរូបនេះមានចេតនាគេចវេសក្នុងការទទួលខុសត្រូវដែលខ្លួនបានប្រព្រឹត្តនិងព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំង៦នាក់បានទទួលរង ហើយជនជាប់ចោទរូបនេះអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធីរហូតដល់សាលាឧទ្ធរណ៍មិនបានចូលបំភ្លឺ ដូច្នេះគប្បីក្រុមប្រឹក្សាបន្ថែមទណ្ឌកម្ម និងចេញដីកាបង្គាប់អោយចាប់ខ្លួនឈ្មោះ [redacted] ដើម្បីមកទទួលខុសត្រូវចំពោះមុខច្បាប់ ហើយចំពោះការបង្គាប់ឱ្យជនជាប់ចោទរូបនេះសងប្រាក់ និងសំណងជម្ងឺចិត្តទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំង៦នាក់នេះ ក្រុមប្រឹក្សាពិនិត្យ ឃើញថាមានលក្ខណៈត្រឹមត្រូវហើយ សមស្របទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលរងហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ២៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ: [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ២២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ: [redacted] [redacted], [redacted], [redacted], [redacted] និងឈ្មោះ: [redacted] ត្រង់ចំណុចទី២, ២.១, ២.២, ២.៣, ២.៤,២.៥,និង២.៦ នៃសេចក្តីសម្រេចក្នុងសាលក្រមលេខ ២២ (ប) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-ទទួលសេចក្តីប្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៤-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ (ប) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងត្រង់ចំណុចទី១ នៃសេចក្តីសម្រេចត្រង់ការផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់រយៈពេល៨(ប្រាំបី)ខែ ព្យួរធម្មតា ត្រូវកែប្រែមកជាដាក់ពន្ធនាគារកំណត់០១(មួយ)ឆ្នាំវិញ តាមបញ្ញត្តិមាត្រា៣៧៧ មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៥-ចេញដីកាបង្គាប់អោយចាប់ខ្លួនឈ្មោះ: [redacted] ដែលមានសវតាជាតិដូចខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ កំបាំងមុខ ជនជាប់ចោទឈ្មោះ: [redacted] និងដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៦កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

# ឧបសម្ព័ន្ធទី៦

## ដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួន, លេខ២៨ ដកឧ/២០
## ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សភាព្រហ្មទណ្ឌ
លេខ ២៨ ដកខ / ២០

# ដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួន

យើង [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះទី V នៃសាលាឧទ្ធរណ៍

-បានឃើញបញ្ញត្តិមាត្រា ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌ ១០៩៨ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រvខល" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២០ របស់សាលាឧទ្ធរណ៍ ។

## យល់ឃើញថា:

១-តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រvខល" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២០ របស់សាលាឧទ្ធរណ៍ បានសម្រេច ៖

+ ចំណុចទី៤ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ (ហ) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងត្រង់ចំណុចទី១ នៃសេចក្តីសម្រេចត្រង់ការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល៨(ប្រាំបី)ខែ ព្យួរធម្មតា ត្រូវកែប្រែមកជាដាក់ពន្ធនាគារកំណត់០១(មួយ)ឆ្នាំវិញ តាមបញ្ញត្តិមាត្រា៣៧៧ មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

+ ចំណុចទី៥ ចេញដីកាបង្គាប់អោយចាប់ខ្លួនឈ្មោះ [redacted] ដែលមានសវតាជាតិដូចខាងលើតាមនីតិវិធី ។

២-តាមបញ្ញត្តិមាត្រា ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះសាលាឧទ្ធរណ៍ អាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទអវត្តមានបាន ប្រសិនបើសាលាឧទ្ធរណ៍សម្រេចដាក់ទោសពន្ធនាគារយ៉ាងតិច ០១ ( មួយ ) ឆ្នាំ ដោយគ្មានការព្យួរទោស ។

## ហេតុដូច្នេះ

## សម្រេច

-បង្គាប់ឱ្យភ្នាក់ងារមានសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគ្រូពេទ្យ ទីកន្លែងកំណើតភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកសេរីសោភ័ណ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្ននៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ,

ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ប្ដីឈ្មោះ [redacted] មានកូន [redacted] នាក់ ជានីតិជន
ប្រវត្តិនៃការផ្ដន្ទាទោសពីមុន គ្មាន។

ទៅឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រ.ខ.ល" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២០ របស់សាលាឧទ្ធរណ៍ ។

ថ្ងៃច័ន្ទ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

# ឧបសម្ព័ន្ធទី៧

## លិខិតផ្ទេរសិទ្ធិ ( គំរូទី៨ )

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### លិខិតផ្ទេរសិទ្ធិ

ខ្ញុំបាទឈ្មោះ [redacted] អាយុ៤៦ឆ្នាំ និងភរិយា ឈ្មោះ [redacted] អាយុ៤៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិ ព្រៃសណ្តែក ឃុំ ព្រៃស្លឹក ស្រុក ទ្រាំង ខេត្ត តាកែវ ជាសមាជិកតុងទីនក្បាល ២០០$ (ពីររយដុល្លាអាមេរិក) ចាប់ផ្តើមប្រមូលកាលពីថ្ងៃទី០១ ខែ០៥ ឆ្នាំ២០១៥ ដែលមានសមាជិកចំនួន ៨១នាក់ ក្នុងនោះមានរូបខ្ញុំបាទ/នាងខ្ញុំផងដែរ ។

**សូមជម្រាបជូនមក**

**លោកស្រី [redacted] ប្រធានសមាគមតុងទីន**

**មេត្តាជ្រាប ។**

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោកស្រី ប្រធានសមាគម មេត្តាជ្រាបថា: ដោយខ្ញុំបាទ/នាងខ្ញុំ មិនអាចបន្តការបង់តុងទីននេះបានទៀតទេ ដោយបញ្ហាខ្វះថវិកា ខ្ញុំបាទ/នាងខ្ញុំ សម្រេចចិត្តផ្ទេរសិទ្ធិបេក្ខភាពសមាជិកខ្ញុំបាទ/នាងខ្ញុំ មួយឈ្មោះទៅអោយលោក [redacted] អាយុ ៣២ឆ្នាំ និងលោកស្រី [redacted] អាយុ៥០ ឆ្នាំ ត្រូវជាម្តាយក្មេក បច្ចុប្បន្នរស់នៅភូមិ សំប៊ូរ សង្កាត់ ដង្កោ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ដើម្បីមានកាតព្វកិច្ចបង់បន្តរហូតដល់អស់សមាជិកចំនួន ៨១នាក់ ដោយគិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ។

ចំពោះមួយឈ្មោះទៀតដែលមានភាគហ៊ុនចូលគ្នាជាមួយអ្នកគ្រូ [redacted] បានដេញរួចហើយនោះ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ [redacted] និងអ្នកស្រី [redacted] មានកាតព្វកិច្ចបង់មួយខែ ១០០ដុល្លា បន្ថែមទៀត រហូតដល់អស់សមាជិកចំនួន ៨១នាក់ ។

ការផ្ទេរសិទ្ធិបេក្ខភាព ខ្ញុំបាទ/នាងខ្ញុំ អោយទៅភាគីម្ខាងទៀតមានឈ្មោះ ដូចរៀបរាប់ខាងលើធ្វើឡើងដោយមិនមានការបង្ខិតបង្ខំពីភាគីម្ខាងណាទៀតឡើយ។

ក្រែងពុំប្រាកដ ខ្ញុំបាទ/នាងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់ ។

| ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៨ | ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៨ | ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៨ |
|---|---|---|
| សាក្សីដឹងឮ | ភាគីទទួលសិទ្ធិបន្ត | ភាគីផ្ទេរសិទ្ធិ |
| [redacted] [redacted] [redacted] | [redacted] [redacted] | [redacted] [redacted] [redacted] |

ឈ្មោះប្តី ប្រពន្ធ ដែលជាមេតុងទីន

(បញ្ជាក់:) ឈ្មោះ [redacted] មានភាគហ៊ុនមួយ ... ឈ្មោះ [redacted]

... លោកស្រី [redacted] ...

100$ ...

... សមាជិក ...

[redacted]